ធនាគារ ARDB
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

រាយការណ៍ថីរភាព និងរាយការណ៍ប្រចំឆ្នាំ

២០២៥



មាតិកា

១. អំពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)

អំពីរបាយការណ៍.....១
អារម្ភកថាប្រធានក្រុមប្រឹក្សាភិបាល.....៣-៤
អារម្ភកថាអគ្គនាយក.....៥-៦
២៦ ឆ្នាំនៃការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍នៅកម្ពុជា.....៧

២.អតិថាលកិច្ចសាជីវកម្ម

រចនាសម្ព័ន្ធ.....៨
ក្រុមប្រឹក្សាភិបាល.....៩-១៥
គណៈគ្រប់គ្រង.....១៦-១៧
គណៈកម្មការ.....១៨-២០

៣. សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៥

វិសាលភាពប្រតិបត្តិការរបស់ធនាគារ ARDB នៅក្នុងប្រទេសកម្ពុជា.....២០
ដៃគូរសហការនៃធនាគារ ARDB.....២១-២២
ទិន្នន័យហិរញ្ញវត្ថុសង្ខេប.....២៣
សំរៀតឥណទាន និងចំនួនអតិថិជនឆ្នាំ២០២៥.....២៤-២៧
ផលិតផលនិងសេវាកម្ម.....២៩-៣៤
ទូរទស្សន៍អនឡាញនៃធនាគារ ARDB.....៣៥
ការវាយតម្លៃដោយចីរភាព.....៣៦
ប្រព័ន្ធវដ្តករសាស្ត្របៃតងនៃធនាគារ ARDB.....៣៧

៤. សកម្មភាពសំខាន់ៗនៃគណៈគ្រប់គ្រង

វេទិកាថ្នាក់អន្តរជាតិ.....៣៨-៤០
វេទិកាថ្នាក់ជាតិ.....៤១-៤៣
ការចុះអនុស្សរណៈនៃការយោគយល់គ្នា.....៤៤-៤៦

៥.គោលនយោបាយចីរភាពរបស់ធនាគារ អភិវឌ្ឍន៍ជនបទ និងកសិកម្ម

គោលនយោបាយប្រកបដោយចីរភាព.....៤៧
គោលនយោបាយគាំពារសង្គម និងបរិស្ថាន.....៤៨
គោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពប្រទេសកម្ពុជា.....៤៩
ឥណទានបៃតងរបស់ធនាគារARDB និងផលជះផ្នែកសេដ្ឋកិច្ច-សង្គម.....៥០-៥១
ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មគាំទ្រ.....៥២-៥៣
ហិរញ្ញប្បទានរាជរដ្ឋាភិបាល.....៥៤
វត្តមានរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម នៅលើទីផ្សារ.....៥៥

៦.សកម្មភាពទំនួលខុសត្រូវសង្គមរបស់ធនាគារ ARDB

មូលនិធិគន្ធបុប្ផាកម្ពុជា.....៥៦
ការចូលរួមរបស់ ធនាគារ ARDB ក្នុងការគាំទ្រវប្បធម៌.....៥៦-៥៧
ធនាគារ ARDB បានបង្កើតបណ្ណាល័យមួយនៅទីស្នាក់ការកណ្តាល.....៥៧
មជ្ឈមណ្ឌលអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន.....៥៨
មជ្ឈមណ្ឌលឧត្តមភាព ARDB ACE-GFA.....៥៩

៧. ទំនួលខុសត្រូវផ្នែកបរិស្ថាន

ថាមពល.....៦០-៦១
ការប្រើប្រាស់ទឹក.....៦១
ការបំភាយឧស្ម័នផ្ទះកញ្ចក់.....៦២
កាកសំណល់/ សំរាម.....៦២
ការកាត់បន្ថយការប្រើប្រាស់ក្រដាស.....៦៣
ការប្រើប្រាស់ថ្មស្តិកឡើងវិញ.....៦៤
ការកែច្នៃថាមពលកកើតឡើងវិញ.....៦៤
ការវាយតម្លៃបរិស្ថានរបស់អ្នកផ្គត់ផ្គង់.....៦៥

៨. អតិថាលកិច្ច និងតាមដាម

វិធីសាស្ត្រនៃការគ្រប់គ្រង.....៦៦
ក្រមសីលធម៌ និងសុចរិតភាព.....៦៧-៦៨
ភាពចម្រុះ និងឱកាសស្មើគ្នា.....៦៩-៧០
សុខភាព និងសុវត្ថិភាពការងារ.....៧១-៧៤
ទំនួលខុសត្រូវផ្នែកសង្គម.....៧៥
ការងារ.....៧៥-៧៦
អត្ថប្រយោជន៍ការងារ.....៧៧-៧៩
ការបណ្តុះបណ្តាល និងការអប់រំ.....៨០-៨៥
សន្ទស្សន៍មាតិកGRI.....៨៦-៨៨

៩. រឿយការណ៍ហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួចរបស់ធនាគារ ARDB

១. អំពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)

អំពីរបាយការណ៍.....១
អារម្ភកថាប្រធានក្រុមប្រឹក្សាភិបាល..... ៣-៤
អារម្ភកថាអគ្គនាយក ៥-៦
២៦ ឆ្នាំនៃការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍នៅកម្ពុជា ៧

១.អំពីធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)

អំពីរបាយការណ៍

វិសាលភាពនៃរបាយការណ៍

របាយការណ៍ចីរភាពនិងរបាយការណ៍ប្រចាំឆ្នាំ ២០២៥ របស់ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម(ARDB) បានឆ្លងកាត់ការធ្វើសវនកម្ម និងរាយការណ៍គិតចាប់ពី **ថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥។**
របាយការណ៍នេះគ្របដណ្តប់លើការទទួលខុសត្រូវនៃប្រតិបត្តិការប្រចាំឆ្នាំនៃការិយាល័យកណ្តាលនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ដែលស្ថិតនៅទីក្រុងភ្នំពេញ, លើផ្នែក សេដ្ឋកិច្ច, បរិស្ថាន, សង្គម, និងអភិបាលកិច្ច ព្រមទាំងផលជះវិជ្ជមានទៅលើការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈប្រតិបត្តិការទាំងមូលរបស់អង្គភាពនៅទូទាំងបណ្តាខេត្តក្នុងប្រទេសកម្ពុជា។

រចនាសម្ព័ន្ធនៃរបាយការណ៍

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានកំណត់ស្តង់ដារប្រតិបត្តិការប្រកបដោយចីរភាពរបស់ខ្លួនស្របទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ និង Global Reporting Initiative (GRI) សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំរចនាសម្ព័ន្ធ និង និងវិធីសាស្ត្រក្នុងការរាយការណ៍។

ការវាយតម្លៃទៅលើប្រធានបទអាទិភាព និងសារវន្ត

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានធ្វើការវាយតម្លៃលើប្រធានបទអាទិភាព ដោយផ្អែកលើឥទ្ធិពល សារៈសំខាន់ និងភាពពាក់ព័ន្ធនៃប្រធានបទទៅនឹងប្រតិបត្តិការរបស់ធនាគារ។ ប្រធានបទសំខាន់ៗទាំងនេះបានឈរលើសសរស្តម្ភសំខាន់ៗទាំងបួននៃទិដ្ឋភាពចីរភាព រួមមាន សេដ្ឋកិច្ច, បរិស្ថាន, សង្គម, និងអភិបាលកិច្ច (Economic, Environment, Social, Governance - EESG)។

ការផ្ទៀងផ្ទាត់ និងការធានាអំពីរបាយការណ៍

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម មានក្រុមការងារបច្ចេកទេស សម្រាប់ដំណើរការរៀបចំរបាយការណ៍ចីរភាព(T.W.G.S) ដែលមានសមាជិកចូលរួមពីនាយកដ្ឋានសំខាន់ៗរបស់ធនាគារ ក្នុងការត្រួតពិនិត្យ និងតាមដានលើដំណើរការចីរភាពរបស់ធនាគារ។ លើសពីនេះ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ក៏ទទួលបានការណែនាំផ្នែកបច្ចេកទេស និងការគាំទ្រផ្នែកប្រឹក្សាយោបល់ ពីសមាគមគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (Association of Development Financing Institutions in Asia and the Pacific - ADFIAP) នៅក្នុងដំណើរការរៀបចំរបាយការណ៍ចីរភាព និងរបាយការណ៍ប្រចាំឆ្នាំ ២០២៥ នេះផងដែរ។

សម្រាប់ការសាកសួរបន្ថែម

លោក គុយ បញ្ញា
ប្រធានក្រុមការងារបច្ចេកទេសសម្រាប់ដំណើរការរៀបចំរបាយការណ៍ចីរភាព និងរបាការណ៍ប្រចាំឆ្នាំ២០២៥ នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
“ប្រធាននាយកដ្ឋានអភិវឌ្ឍន៍យុទ្ធសាស្ត្រអាជីវកម្ម”
អ៊ីមែល÷ k.panha@ardb.com.kh

លោក ថៃ ហ្សឺឌី
អនុប្រធានក្រុមការងារបច្ចេកទេសសម្រាប់ដំណើរការរៀបចំរបាយការណ៍ចីរភាព និងរបាការណ៍ប្រចាំឆ្នាំ២០២៥ នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
“ប្រធាននាយកដ្ឋានហិរញ្ញប្បទានបៃតង”
អ៊ីមែល÷ t.jeudi@ardb.com.kh

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB)
អាគារលេខ១៦៨ ផ្លូវបេតុងលេខ០៧ ភូមិព្រែកលាប សង្កាត់ព្រែកលាប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា។
ទូរស័ព្ទ÷ +855 (0)23 220 810/(0)23 220 811 អ៊ីមែល÷ info@ardb.com.kh គេហទំព័រ÷ www.ardb.com.kh
ហ្វេសប៊ុក÷ ARDB Bank

ចក្ខុវិស័យ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ជាគ្រឹះស្ថានផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាពឈានមុខគេ ដែលផ្តោតលើការអភិវឌ្ឍវិស័យកសិកម្ម វិស័យជនបទ និងវិស័យបៃតងនៅក្នុងប្រទេសកម្ពុជា។

បេសកកម្ម

១. ការអភិវឌ្ឍទំនាក់ទំនងដ៏រឹងមាំ និងប្រកបដោយចីរភាពគ្រប់តួអង្គក្នុងខ្សែច្រវាក់តម្លៃកសិកម្ម វិស័យអភិវឌ្ឍន៍ជនបទ និងវិស័យបៃតង តាមរយៈការផ្តល់សេវាកម្មហិរញ្ញវត្ថុពេញលេញប្រកបដោយបរិយាបន្ន។

២. ការកំណត់អត្តសញ្ញាណ, ការសម្របសម្រួល, និងការដោះស្រាយ គម្លាតទីផ្សារ ក្នុងវិស័យកសិកម្ម វិស័យអភិវឌ្ឍន៍ជនបទ និងវិស័យបៃតង តាមរយៈភាពជាដៃគូយុទ្ធសាស្ត្រ ការផ្តល់ដំណោះស្រាយហិរញ្ញវត្ថុដោយប្រើប្រាស់បច្ចេកវិទ្យា និងហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាព។

៣. ការធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទ តាមរយៈការផ្តល់សេវាកម្មហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាពដល់សហគ្រាសធុនតូច និងមធ្យម ក្នុងវិស័យអភិវឌ្ឍន៍ជនបទ។

៤. ការលើកកម្ពស់ ការសន្សំប្រកបដោយចីរភាព ក្នុងវិស័យអភិវឌ្ឍន៍ជនបទ និងអក្ខរកម្មហិរញ្ញវត្ថុ។

គោលដៅ

១. ធ្វើបរិវត្តកម្មធនាគារឱ្យទៅជាធនាគារឌីជីថលពេញលេញផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាព តាមរយៈការប្រើប្រាស់បញ្ញាសិប្បនិម្មិត

២. ប្រែក្លាយប្រជាកសិករឱ្យទៅជាកសិករសហគ្រិន តាមរយៈការផ្តល់ជំនួយបច្ចេកទេស និងលើកកម្ពស់ការយល់ដឹងដើម្បីជំរុញការនាំចេញ និងចូលរួមរក្សាសុវត្ថិភាពស្បៀងអាហារកម្ពុជា

៣. លើកកម្ពស់ចង្កោមសហគ្រាសធុនមីក្រូ តូច និងមធ្យមសម្រាប់ធុរកិច្ចកសិ-ឧស្សាហកម្ម សំដៅកសាងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្មប្រកបដោយចីរភាព

៤. លើកកម្ពស់វិស័យបៃតង និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាព។

គុណតម្លៃ

១. សុចរិតភាព÷ គឺជាគុណតម្លៃស្នូលមួយ ដែលផ្សារភ្ជាប់រវាងភាពស្មោះត្រង់ និងមនសិការវិជ្ជាជីវៈ។

២. កិច្ចសហការ÷ គឺជាគុណតម្លៃស្នូលមួយដែលបង្ហាញអំពីសកម្មភាពនៃការទំនាក់ទំនង និងការបំពេញការងាររួមគ្នា ដើម្បីសម្រេចបានទស្សវគោលដៅរួម។

៣. នវានុវត្តន៍÷ គឺជាគុណតម្លៃស្នូលមួយ ដែលបង្ហាញអំពីការអនុវត្តការងារ ដែលមានលក្ខណៈទំនើបកម្ម និងភាពឆ្នៃប្រឌិត។

តួនាទី

ធនាគារ ARDB បានដើរតួនាទីជាធនាគារគោលនយោបាយរបស់រាជរដ្ឋាភិបាលបំពេញកង្វះចន្លោះផ្នែកហិរញ្ញវត្ថុក្នុងគម្រោងអភិវឌ្ឍន៍នានា ដែលគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុឯកជនមិនអាចបំពេញបាន។ ធនាគារ ARDB មានមហិច្ឆតា ក្នុងការផ្តល់សេវាធនាគារពេញលេញប្រសិទ្ធភាព និងមានចីរភាពដើម្បីគាំទ្រការអភិវឌ្ឍវិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទ ដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

អារម្ភកថាប្រធានក្រុមប្រឹក្សាភិបាល



"ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយចីរភាព គឺជាវត្ថុបំណងចម្បងរបស់ធនាគារ ARDB ក្នុងការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងប្រែក្លាយកសិករលក្ខណៈប្រពៃណីជាកសិករសហគ្រិន សំដៅលើកកម្ពស់ស្តង់ដារ នៃការរស់នៅរបស់កសិករ នៅតាមទីជនបទឱ្យមានភាពប្រសើរឡើង។"

រស់ សីលវ៉ា

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ខណៈពេលដែលពិភពលោកបន្តប្រឈមមុខនឹងបញ្ហាកាន់តែធ្ងន់ធ្ងររួមមាន÷ ការប្រែប្រួលអាកាសធាតុ ភាពមិនប្រាកដប្រជាផ្នែកសេដ្ឋកិច្ច ការបំផ្លាញបរិស្ថាន និងបញ្ហាសន្តិសុខស្បៀងអាហារ ធនាគារ ARDB ទទួលស្គាល់ថា ការអភិវឌ្ឍប្រកបដោយចីរភាព មិនមែនគ្រាន់តែជាជម្រើសទៀត ទេប៉ុន្តែគឺជាកាតព្វកិច្ចយុទ្ធសាស្ត្រចាំបាច់ចំពោះធនាគារ។ បញ្ហាប្រឈមទាំងនេះឆ្លុះបញ្ចាំងភាពងាយរងគ្រោះនៃប្រព័ន្ធសេដ្ឋកិច្ចសង្គមជាសកល និងបានអំពាវនាវឱ្យមានវិធានការបន្ទាន់សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពបន្ថែមទៀត ដើម្បីធានាស្ថិរភាព និងវិបុលភាពសម្រាប់អនាគត។

ធនាគារ ARDB បានសម្របសម្រួលយុទ្ធសាស្ត្ររបស់ខ្លួនឱ្យស្របតាម យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា (CSDGs)។ ក្រោមការណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារ ARDB យល់ឃើញថា វិស័យកសិកម្មគឺជាសសរស្តម្ភសំខាន់មួយសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងការពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ កិច្ចខិតខំប្រឹងប្រែងរបស់ធនាគារ បានគាំទ្ររបៀបវារៈនៃការអភិវឌ្ឍន៍ជាតិដោយរយៈពេលវែង និង CSDGs ដូចជា÷ គ្រោះអត់ឃ្លានស្មើសូន្យ (Zero Hunger), សន្តិសុខស្បៀង (Food Security), ពុំមានភាពក្រីក្រ (No Poverty), និងការងារសមរម្យ និងកំណើនសេដ្ឋកិច្ច (Decent Work & Economic Growth)។ លើសពីនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ធនាគារ ARDB ផ្តោតលើការគាំទ្រហិរញ្ញប្បទានប្រកបដោយទំនួលខុសត្រូវ និងមានគោលដៅច្បាស់លាស់ ដើម្បីបង្កើនផលិតភាពកសិកម្ម ពង្រឹងប្រព័ន្ធស្បៀងអាហារ និងលើកកម្ពស់ការអនុវត្តប្រកបដោយចីរភាពដល់វិស័យផលិតកម្មដំណាំ ការចិញ្ចឹមសត្វ និងវារីវប្បកម្ម។

ARDB ប្តេជ្ញាបញ្ចូលគោលការណ៍ចីរភាពទៅក្នុងយុទ្ធសាស្ត្រអាជីវកម្មស្នូលរបស់ខ្លួន ដោយពង្រឹងខ្សែច្រវាក់តម្លៃកសិកម្ម គាំទ្រកសិកម្មឆ្លាតវៃ ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពព្រមទាំងពង្រីកការទទួលបានហិរញ្ញវត្ថុសម្រាប់កសិករខ្នាតតូចអាជីវកម្មកសិកម្ម និងសហគ្រាសជនបទ។ តាមរយៈកិច្ចខិតខំទាំងនេះ យើងមានគោលបំណងបង្កើតតម្លៃសេដ្ឋកិច្ចសង្គមរយៈពេលវែង ពង្រឹងភាពធន់របស់សហគមន៍ជនបទ និងរួមចំណែកយ៉ាងមានអត្ថន័យដល់ការកាត់បន្ថយភាពក្រីក្រ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ

ធនាគារ ARDB ប្តេជ្ញាចិត្តបញ្ចូលគោលការណ៍ចីរភាពទៅក្នុងយុទ្ធសាស្ត្រអាជីវកម្មស្នូល តាមរយៈការពង្រឹងខ្សែច្រវាក់តម្លៃកសិកម្ម គាំទ្រកសិកម្មឆ្លាតវៃ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព ព្រមទាំងបង្កើនលទ្ធភាពទទួលបានឥណទានសម្រាប់កសិករខ្នាតតូច អាជីវកម្មកសិកម្ម និងសហគ្រាសជនបទ។ តាមរយៈកិច្ចខិតខំប្រឹងប្រែងទាំងនេះ យើងមានគោលបំណងបង្កើនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរយៈពេលវែង ពង្រឹងសហគមន៍ជនបទឱ្យធន់នឹងការប្រែប្រួលអាកាសធាតុ និងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ និងការធ្វើពិពិធកម្មសេដ្ឋកិច្ចជាតិ។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB ខ្ញុំសូមបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាល ទៅលើការត្រួតពិនិត្យ និងការដឹកនាំបែបយុទ្ធសាស្ត្រ ដើម្បីធានាថាគោលដៅអភិវឌ្ឍន៍ និងការអភិវឌ្ឍន៍ជាតិប្រកបដោយចីរភាព នៅតែជាផ្នែកសំខាន់នៃចក្ខុវិស័យ បេសកកម្ម និងដំណើរការសម្រេចចិត្តរបស់ធនាគារ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះសមាជិកក្រុមប្រឹក្សាភិបាល គណៈគ្រប់គ្រងគ្រប់ជាន់ថ្នាក់ និងបុគ្គលិករបស់ធនាគារARDB ចំពោះការប្តេជ្ញាចិត្តនិងការអនុវត្តការងារប្រកបដោយវិជ្ជាជីវៈក្នុងការជំរុញគោលនយោបាយរបស់រដ្ឋាភិបាលនិងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ធនាគារ ARDB។

ជាមួយគ្នានេះយើងប្តេជ្ញាចិត្តកសាងវិស័យកសិកម្មឱ្យមានភាពធន់នឹងការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាពនិងវិបុលភាពដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាជន បរិស្ថាន និងគាំទ្រគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់កម្ពុជា។

វស់ សីលវ៉ា

រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

អារម្ភកថាអគ្គនាយក



សមិទ្ធផលក្នុងឆ្នាំ២០២៥

នៅក្នុងឆ្នាំ២០២៥ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានស្ថិតនៅលើគន្លងមួយគួរឱ្យកត់សម្គាល់ប្រកបដោយវឌ្ឍនភាព ព្រមទាំងមានសន្ទនីយភាពខ្ពស់ប្រកបដោយចីរភាព។ ធនាគារ ARDB បានបន្តស្ថិរភាពដោយបានអភិវឌ្ឍខ្លួនលើការពង្រីកប្រតិបត្តិកាតាមបណ្តាលខេត្ត ការផ្លាស់ប្តូរប្រព័ន្ធបច្ចេកវិទ្យាទំនើបនៃប្រព័ន្ធធនាគាស្នូលថ្មី និងធ្វើឱ្យប្រសើរឡើងនូវមុខងារស្វ័យប្រតិបត្តិការ ARDB Mobile App ស្របតាមតម្រូវការរបស់អតិថិជន និងអភិវឌ្ឍន៍នូវបច្ចេកវិទ្យាឌីជីថលដើម្បីងាយស្រួលក្នុងការធ្វើប្រតិបត្តិការ។ ក្រៅពីសមិទ្ធផលទាំងនេះធនាគារ ARDB ប្រឈមនឹងបញ្ហាបន្តិចបន្តួច ដោយមានការធ្លាក់ចុះនៃកំណើនសេដ្ឋកិច្ច សម្ពាធអតិផរណា ភាពមិនប្រាកដប្រជានៃទីផ្សារកសិកម្ម ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៃបញ្ហាជម្លោះព្រំដែនកម្ពុជាថៃ។ តែទោះបីជាយ៉ាងណាក៏ដោយ ធនាគារ ARDB នៅតែបន្តមានជំហរវិងមុាំ និងបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយ ទំនួលខុសត្រូវ និងចក្ខុវិស័យវែងឆ្ងាយ ។

ចំណុចសំខាន់ៗក្នុងឆ្នាំ ២០២៥

- ១ សំពៀតឥណទានសរុបបានកើនឡើងដល់ ៥៤៣ លានដុល្លារអាមេរិក គឺកើនត្រឹម ១០.៣៧% បើធៀបនឹងផែនការឆ្នាំ ២០២៤
- ២ ចំនួនគណនីប្រាក់បញ្ញើបានកើនឡើងដល់ ៧,៦៧៣ គណនី ដែលមានកំណើនរហូតដល់ ៤៨.៣៥% បើធៀបនឹងឆ្នាំ ២០២៤
- ៣ ការអភិវឌ្ឍបច្ចេកវិទ្យាថ្មីនៃប្រព័ន្ធធនាគាស្នូល ដើម្បីបង្កើនភាពងាយស្រួលក្នុងការធ្វើប្រតិបត្តិការ
- ៤ បានពង្រីកបណ្តាញប្រតិបត្តិការតាមបណ្តាលខេត្ត និងបម្លែងការិយាល័យចល័តទៅជាកម្រិតសាខា។

ទស្សនវិស័យក្នុងឆ្នាំ២០២៦ របស់ធនាគារ ARDB

ក្នុងគោលដៅបន្តបេសកកម្ម ធនាគារ ARDB បានដាក់ចេញនូវគោលដៅអាទិភាពសម្រាប់ឆ្នាំ២០២៦ ចំនួន៤ចំណុចដូចខាងក្រោម ÷

១	បន្តធ្វើបដិវត្តកម្មធនាគារឱ្យទៅជាធនាគារឌីជីថលពេញលេញ ផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាព តាមរយៈការប្រើប្រាស់បញ្ញាសិប្បនិម្មិត។
២	បន្តប្រែក្លាយប្រជាកសិករ ឱ្យទៅជាកសិករសហគ្រិន តាមរយៈការផ្តល់ ជំនួយបច្ចេកទេស និងលើកកម្ពស់ការយល់ដឹង ដើម្បីជំរុញការ នាំចេញ និងចូលរួមរក្សាសុវត្ថិភាពស្បៀងអាហារកម្ពុជា។
៣	បន្តលើកកម្ពស់ចង្កោមសហគ្រាសធុនមីក្រូ តូច និងមធ្យម សម្រាប់ធុរកិច្ច កសិ-ឧស្សាហកម្ម សំដៅកសាងខ្សែច្រវាក់តម្លៃផលិតកម្មកសិកម្មប្រកបដោយចីរភាព។
៤	បន្តលើកកម្ពស់វិស័យបៃតង និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ តាមរយៈការផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាព។

ឆ្លៀតក្នុងឱកាសដ៏ពិសេសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាលកម្ពុជា, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារជាតិនៃកម្ពុជា ដែលតែងតែគាំទ្រ និងផ្តល់ទំនុកចិត្តមកលើធនាគារ ARDB។ ខ្ញុំបាទ ក៏សូមថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ ដែលតែងតែគាំទ្រ និងផ្តល់អនុសាសន៍ល្អៗ ដល់ធនាគារ ARDB និងសូមអរគុណដល់ ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អង្គការដៃគូអភិវឌ្ឍន៍នានា ព្រមទាំងអរគុណដល់អតិថិជន និងបុគ្គលិកធនាគារទាំងអស់ដែលបានខិតខំបំពេញការងារអស់ពីកម្លាំងកាយចិត្ត បានចូលរួមសហការជាមួយធនាគារ ARDB លើការលើកស្ទួយការអភិវឌ្ឍវិស័យកសិកម្មនៅប្រទេសកម្ពុជា។

បណ្ឌិត កៅ ថាច

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម



រយៈពេល ២៦ឆ្នាំ ដែលធនាគារ ARDB បានចូលរួមក្នុងការជំរុញដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម សម្រាប់ប្រជាកសិករខ្មែរ, ខ្សែច្រវាក់តម្លៃកសិកម្មនៅក្នុងប្រទេសទទួលបានការរីកចម្រើនគួរឱ្យកត់សម្គាល់។ ធនាគារ ARDB ក៏នឹងបន្តជំរុញតម្លៃសេដ្ឋកិច្ចសង្គម, អភិវឌ្ឍខ្សែច្រវាក់តម្លៃកសិកម្មបន្ថែម និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជាផងដែរ។

ធនាគារ ARDB ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៨ ដោយមានឈ្មោះថា ធនាគារអភិវឌ្ឍន៍ជនបទ (ធ.អ.ជ) ជាធនាគារឯកទេស ក្រោមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ១៩៩៨។ នៅឆ្នាំ២០១៤, រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចេញអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធរបស់ធនាគារអភិវឌ្ឍន៍ជនបទ។ បន្ទាប់មក, ធនាគារបានផ្លាស់ប្តូរពីធនាគារឯកទេស ទៅជាធនាគារពាណិជ្ជ និងបានប្តូរឈ្មោះទៅជា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ធ.អ.ជ.ក) តាមអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩។

ធនាគារ ARDB ជាសហគ្រាសសាធារណៈ ដែលមានឧបនិស្ស័យជាធនាគារពាណិជ្ជ និងមានស្វ័យភាពប្តូរប្តូរណ៍ក្នុងការដឹកនាំ និងគ្រប់គ្រងសកម្មភាពរបស់ខ្លួន។ ធនាគារ ARDB ស្ថិតក្រោមអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា។

គួរបញ្ជាក់ថា ការបន្តគាំទ្រដល់ការលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនៅកម្ពុជា ក៏បានលើកទឹកចិត្តឱ្យ ធនាគារ ARDB យកចិត្តទុកដាក់ចំពោះសារៈសំខាន់ក្នុងការដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុដែលជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវភាព និងការរស់នៅរបស់ប្រជាកសិករ។ ជាលទ្ធផល ធនាគារ ARDB បានបង្កើនការធ្វើប្រតិបត្តិការរបស់ខ្លួនតាមរយៈការកែសម្រួលឡើងវិញនូវចក្ខុវិស័យ បេសកកម្ម គោលដៅរបស់ខ្លួន និងបានបំពេញតួនាទីទៅជា ធនាគារពាណិជ្ជប្រកបដោយចីរភាព។

ធនាគារ ARDB បានកំណត់នូវចក្ខុវិស័យថ្មី “ក្លាយទៅជាគ្រឹះស្ថានផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាពឈានមុខគេ” តាមរយៈការបញ្ចូលនូវគោលគំនិតហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាព ទៅក្នុងយុទ្ធសាស្ត្រអាជីវកម្ម និងប្រតិបត្តិការរបស់ធនាគារ។ លើសពីនេះ ធនាគារ ARDB បានជើរតួនាទីយ៉ាងសកម្មក្នុងការអភិវឌ្ឍនិងផ្តល់ហិរញ្ញប្បទានបៃតងក្នុងប្រទេស ជាមួយនឹងការអនុវត្តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា ចាប់តាំងពីឆ្នាំ២០១៨ និងបានបង្កើតនាយកដ្ឋានហិរញ្ញប្បទានបៃតងនៅឆ្នាំ២០២២ ជាដើម។

ធនាគារ ARDB ក៏មានគោលដៅក្លាយជា ស្ថាប័នដែលទទួលបានមូលនិធិដោយផ្ទាល់ (Accredited Entity) ពីមូលនិធិអាកាសធាតុបៃតង និងស្ថាប័នដែលផ្តល់ការគាំទ្រហិរញ្ញវត្ថុជាបន្តបន្ទាប់សម្រាប់ប្រទេសកម្ពុជាក្នុងនាមជាធនាគារបៃតងនៅកម្ពុជាផងដែរ។

២.អតិថាលកិច្ចសាជីវកម្ម

រចនាសម្ព័ន្ធ ៨
ក្រុមប្រឹក្សាភិបាល ៩-១៥
គណៈគ្រប់គ្រង ១៦-១៧
គណៈកម្មការ ១៨-២០

រចនាសម្ព័ន្ធ


មន្ត្រីត្រួតពិនិត្យរដ្ឋ
ក្រុមប្រឹក្សាភិបាល
គណៈកម្មការសវនកម្ម
គណៈកម្មការ
គ្រប់គ្រងហានិភ័យ
អគ្គនាយក
ទីប្រឹក្សា
លេខាធិការដ្ឋាន
ក្រុមប្រឹក្សាវិន័យ
គណៈកម្មការ
បញ្ជីសារពើភណ្ឌ
ទ្រព្យសម្បត្តិរដ្ឋ
គណៈកម្មការ
គ្រប់គ្រង និងចាត់ចែង
ទ្រព្យសកម្ម និងទ្រព្យអកម្ម
គណៈកម្មាធិការផ្សេងៗ៖
1. គណៈកម្មាធិការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា
2. គណៈកម្មាធិការតម្រង់ទិសព័ត៌មានវិទ្យា
3. គណៈកម្មាធិការយុទ្ធសាស្ត្រព័ត៌មានវិទ្យា
អគ្គនាយករង
អគ្គនាយករង
អគ្គនាយករង
នាយកដ្ឋាន
សវនកម្មផ្ទៃក្នុង
នាយកដ្ឋាន
កិច្ចការគតិយុត្ត
និងប្រតិបត្តិតាម
នាយកដ្ឋាន
ធនធានមនុស្ស
នាយកដ្ឋាន
រដ្ឋបាលទូទៅ និង
ទំនាក់ទំនងសាធារណៈ
នាយកដ្ឋាន
គ្រប់គ្រងសាខា និង
ប្រតិបត្តិការចល័ត
អង្គភាព
លទ្ធកម្ម
នាយកដ្ឋាន
ហិរញ្ញប្បទានបៃតង
នាយកដ្ឋាន
ស្រាវជ្រាវ
និងអភិវឌ្ឍន៍
នាយកដ្ឋាន
ផ្នែកលក់ និងទីផ្សារ
នាយកដ្ឋាន
អភិវឌ្ឍន៍យុទ្ធសាស្ត្រ
អាជីវកម្ម
នាយកដ្ឋានតាមដាន
ការប្រើប្រាស់ឥណទាន
និងការប្រមូលបំណុល
នាយកដ្ឋាន
ឥណទាន
នាយកដ្ឋាន
ព័ត៌មានវិទ្យា
នាយកដ្ឋាន
គ្រប់គ្រងសេវា
ធនាគារឌីជីថល
អង្គភាព
សម្របសម្រួល
គម្រោង
នាយកដ្ឋាន
គ្រប់គ្រងហានិភ័យ
នាយកដ្ឋាន
ប្រតិបត្តិការ
និងកិច្ចការរតនាគារ
នាយកដ្ឋាន
គណនេយ្យ
និងហិរញ្ញវត្ថុ
នាយកដ្ឋានគាំទ្រ
គោលនយោបាយ
របស់រាជរដ្ឋាភិបាល

ក្រុមប្រឹក្សាភិបាល



ឯកឧត្តម រស់ សីលវ៉ា បច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ប្រធានក្រុមប្រឹក្សាភិបាលនៃសាជីវកម្មធានាឥណទានកម្ពុជា, ប្រធានគណៈកម្មការប្រតិបត្តិ នៃក្រុមប្រឹក្សាជាតិគាំពារសង្គម, សមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ, ប្រធានក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB, អនុប្រធានក្រុមប្រឹក្សាបរធនបាល នៃមូលនិធិគន្ធបុប្ផាកម្ពុជា, នាយកប្រតិបត្តិ នៃមូលនិធិគន្ធបុប្ផាកម្ពុជា, ទេសាភិបាលតំណាងកម្ពុជាប្រចាំវិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងអាស៊ីបូពាំ (Economic Research Institute for ASEAN and East AsiaèERIA), អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុតំណាងប្រទេសកម្ពុជានៅក្នុងកិច្ចប្រជុំអនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ាន, សមាជិកនៃក្រុមប្រឹក្សាភិបាលនៃកម្មវិធីសម្ព័ន្ធភាពប្រៃប្រួលអាកាសធាតុកម្ពុជា, អ្នកសម្របសម្រួលជាតិនៃកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ, និងប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី"។

ឯកឧត្តមបានចាប់ផ្តើមបម្រើតួនាទីក្នុងជួររាជរដ្ឋាភិបាលចាប់តាំងពីឆ្នាំ១៩៨៥ នៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។ នៅឆ្នាំ១៩៩៤ ឯកឧត្តមបានបម្រើការងារនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានតួនាទីជាអ្នកត្រួតពិនិត្យហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៥ ឯកឧត្តមត្រូវបានតែងតាំងជាអនុប្រធានអង្គភាពរៀបចំ និងតាមដានការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ រវាងឆ្នាំ២០០៥ និងឆ្នាំ២០០៦ ឯកឧត្តមមានតួនាទីជាប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ។ បន្ថែមពីនេះទៀត ឯកឧត្តមធ្លាប់បំពេញការងារជាទីប្រឹក្សានាយកប្រតិបត្តិ នៃក្រុមប្រឹក្សានាយកប្រតិបត្តិរបស់ធនាគារពិភពលោកចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០០៨។ បន្ទាប់ពីឯកឧត្តមបានវិលត្រលប់ពីបំពេញការងារជាទីប្រឹក្សានាយកប្រតិបត្តិនេះ ឯកឧត្តមត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឆ្នាំ២០១៣ និងត្រូវបានតែងតាំងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឆ្នាំ២០២០។

ទន្ទឹមនេះឯកឧត្តមបាននឹងកំពុងរួមចំណែកក្នុងដំណើរការនៃការតាក់តែងគោលនយោបាយជាច្រើនរបស់រាជរដ្ឋាភិបាលព្រមទាំងធ្លាប់មានតួនាទីជាសាស្ត្រាចារ្យនៅវិទ្យាស្ថានបច្ចេកវិទ្យាភ្នំពេញនៃក្រសួងអប់រំយុវជននិងកីឡាថែមទៀត។គួរបញ្ជាក់ដែរថាឯកឧត្តមទទួលបានបរិញ្ញាបត្រផ្នែកសិក្សាសង្គមពី Penza"s Institute of Pedagogy នៃអតីតសហភាពសូវៀតនៅឆ្នាំ១៩៩២។ នៅឆ្នាំ២០០២ ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកកិច្ចការអន្តរជាតិដោយផ្តោតលើការគ្រប់គ្រងគោលនយោបាយសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Columbia University នៃសហរដ្ឋអាមេរិក។



ឯកឧត្តមបណ្ឌិត កៅ ថាច មានតួនាទីជាប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃធនាគារ ARDB។ នៅថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១៤ ឯកឧត្តមត្រូវបានតែងតាំងជានាយកប្រតិបត្តិនៃធនាគារអភិវឌ្ឍន៍ជនបទ (Rural Development Bank-RDB) ដែលក្រោយមកត្រូវបានប្តូរឈ្មោះទៅជាធនាគារ ARDB ព្រមទាំងត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ RDB នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤។ បច្ចុប្បន្ន, ឯកឧត្តមមានតួនាទីជាប្រធានសមាគមគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក (Association of Development Financing Institutions in Asia and the Pacificè ADFIAP) និងជាសមាជិកឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលមានឋានៈស្មើរដ្ឋលេខាធិការ និងជាមជ្ឈត្តករនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលតាំងពីឆ្នាំ២០០៣។ ឯកឧត្តមបានក្លាយជាមេធាវីពេញសិទ្ធិនៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ និងជាសមាជិកសមាគមគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៦។ មុនចូលបំពេញតួនាទីនៅធនាគារ ARDB, ឯកឧត្តមធ្លាប់ជាអគ្គនាយករងនៃគណៈកម្មការមូលបត្រកម្ពុជា ដែលមានឋានៈនិងបុព្វសិទ្ធិស្មើអនុរដ្ឋលេខាធិការ និងធ្លាប់ជាប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុក្រោមនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ជាងនេះទៅទៀត ឯកឧត្តមក៏ធ្លាប់ជាមន្ត្រីផ្នែកច្បាប់នៅក្រសួងយុត្តិធម៌ និងក្នុងតុលាការផងដែរ។ លើសពីនេះ, ឯកឧត្តមស្ថិតក្នុងចំណោមបុគ្គលសំខាន់ៗ ដែលបានចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងបង្កើតគណៈកម្មការមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា។ ចាប់តាំងពីចូលបំពេញការងារក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៅឆ្នាំ២០០៣, ឯកឧត្តមបានចូលរួមក្នុងកិច្ចការសំខាន់ៗជាច្រើនដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជា។ កិច្ចការទាំងនេះរួមមាន ការចូលរួមជាសមាជិកក្រុមការងារនានាដែលបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីមូលបត្ររដ្ឋ និងច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន ព្រមទាំងក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ និងឆ្នាំ២០១១-២០២០។ ជាងនេះទៅទៀត, តាងនាមតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមបានចូលរួមក្នុងក្រុមការងារថ្នាក់អាស៊ានជាច្រើនដែលធ្វើការពាក់ព័ន្ធនឹងការអភិវឌ្ឍទីផ្សារមូលធន ដូចជា ក្រុមការងារ ABMI, ACMF, និងសេរីភាវូបនីយកម្មសេវាកម្មហិរញ្ញវត្ថុ ជាដើម។

ជាការគួរកត់សម្គាល់ ឯកឧត្តមទទួលបានបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ(LLB-Faculty of Law and Economics) នៅឆ្នាំ១៩៩៨ និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រពីសាកលវិទ្យាល័យ Bond University នៃប្រទេសអូស្ត្រាលីនៅឆ្នាំ២០០២ ដែលផ្តោតសំខាន់លើប្រព័ន្ធច្បាប់ពាណិជ្ជកម្មអន្តរជាតិ, ក្របខណ្ឌច្បាប់នៃអង្គការពាណិជ្ជកម្មពិភពលោក, នីតិវិធីដោះស្រាយវិវាទនានា, និងការរៀបចំប្រព័ន្ធដោះស្រាយវិវាទ។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៩ ឯកឧត្តមទទួលបានបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ចពី EU Business School ដោយបានសរសេរនិក្ខេបបទក្រោមប្រធានបទ÷ “The Rural Development Bank“s Transformation: The Case of Cambodia”។ នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ឯកឧត្តមទទួលបានបណ្ឌិតផ្នែកគោលនយោបាយសាធារណៈពីសាកលវិទ្យាល័យកម្ពុជា ដោយឯកឧត្តមបានសរសេរនិក្ខេបបទក្រោមប្រធានបទ÷ “The role of Securities regulators in Efficient Su-pervision and Regulations of the Securities Market in Cambodia”។

ចំពោះការស្រាវជ្រាវ និងការបោះពុម្ពផ្សាយ, ឯកឧត្តមបានបោះផ្សាយការសិក្សាស្រាវជ្រាវមួយនៅខែសីហា ឆ្នាំ២០២២ ក្រោមប្រធានបទ÷ “Does the Role of Securities Regulators Matter for The Development of Securities Market in Cam-bodia? An Exploratory Study” ជាមួយមជ្ឈមណ្ឌល Centre for ASEAN Studies និង Centre for International Man-agement and Development Antwerp នៅប្រទេសបែលហ្សិក។ កាលពីឆ្នាំ២០០២ ឯកឧត្តមបានបោះផ្សាយសៀវភៅមួយក្បាលក្រោមចំណងជើង÷ “Dispute Settlement System of the World Trade Organization and Theories and Princi-ple of Dispute System Design” ជាមួយ UTPP Press នៅប្រទេសកម្ពុជា។



ឯកឧត្តម សាន ឥសាល បច្ចុប្បន្នជារដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB។

ឯកឧត្តមបានចូលបម្រើការងារក្នុងវិស័យកសិកម្មចាប់តាំងពីឆ្នាំ១៩៩០ ដល់ឆ្នាំ២០០៣ ដែលក្នុងអំឡុងពេលនោះ ឯកឧត្តមបានចូលរួមក្នុងសកម្មភាពជាច្រើនក្នុងការអភិវឌ្ឍវិស័យកសិកម្ម។ ឯកឧត្តមធ្លាប់បម្រើការងារជាមន្ត្រីបច្ចេកទេសក្នុងនាយកដ្ឋានមួយចំនួននៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទដូចជានាយកដ្ឋានគ្រឿងយន្តកសិកម្ម, នាយកដ្ឋានក្សេត្រសាស្ត្រ, និងនាយកដ្ឋានបមាណីយនិងសម្ភារៈកសិកម្ម។ចាប់ពីឆ្នាំ២០០៣ដល់ឆ្នាំ២០០៨ឯកឧត្តមបានបម្រើការងារជានាយករដ្ឋបាលសាលាខណ្ឌមានជ័យនៃរាជធានីភ្នំពេញ មុននឹងត្រូវបានតែងតាំងជាអនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៩។

ក្រៅពីបំពេញការងារក្នុងជួររាជរដ្ឋាភិបាលឯកឧត្តមក៏មានបទពិសោធបម្រើការងារក្នុងវិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាលផងដែរ។ ចាប់តាំងពីឆ្នាំ១៩៩៤ ឯកឧត្តមមានតួនាទីជាអគ្គលេខាធិការនៃសហព័ន្ធនិស្សិតបញ្ញវន្តប្រជាធិបតេយ្យកម្ពុជា (ក្រុម២២)។ ចំពោះការអប់រំ ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ពីសាកលវិទ្យាល័យចម្រើនពហុបច្ចេកវិទ្យានៅឆ្នាំ២០០៥ និងកំពុងបន្តការសិក្សាថ្នាក់បណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយនៅសាកលវិទ្យាល័យអាស៊ី-អ៊ឺរ៉ុប។ ក្នុងអំឡុងពេលបំពេញការងារអស់ជាច្រើនឆ្នាំកន្លងមកនេះ ឯកឧត្តមក៏បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលសំខាន់ៗជាច្រើនទៀតផងដែរ។



ឯកឧត្តម ឈាង វណ្ណារិទ្ធ មានតួនាទីជាអនុរដ្ឋលេខាធិការរដ្ឋសភា, រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី, អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១, អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលស្ថិតក្រោមទីស្តីការគណៈរដ្ឋមន្ត្រី, និងជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB។

លើសពីនេះ ឯកឧត្តមក៏មានតួនាទីជាប្រធានផ្នែកសិក្សា និងវិភាគគោលនយោបាយសេដ្ឋកិច្ចនៃឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលឯកឧត្តមស្ថិតក្នុងក្រុមការងារស្នូលទទួលបន្ទុករៀបចំចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០, គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម, យុទ្ធសាស្ត្រចតុកោណ, យុទ្ធសាស្ត្របញ្ចកោណ, ក៏ដូចជាគោលនយោបាយសំខាន់ៗដទៃទៀតដែរ។ ក្រៅពីនេះឯកឧត្តមគឺជាអតីតអគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអតីតអគ្គលេខាធិការរងនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលចូលរួមដឹកនាំរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ, គោលនយោបាយហិរញ្ញវត្ថុសាធារណៈ, ពាណិជ្ជកម្មអន្តរជាតិ, កិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ, និងគោលនយោបាយសំដៅជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ជាដើម។

ឯកឧត្តម ឈាង វណ្ណារិទ្ធ បានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកសេដ្ឋកិច្ច និងគោលនយោបាយសាធារណៈ ពីសាកលវិទ្យាល័យ Georgetown សហរដ្ឋអាមេរិក, ហើយលោកទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Georgia សហរដ្ឋអាមេរិក។



ឯកឧត្តម ឃី កុសល ជាអនុរដ្ឋលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃធនាគារ ARDB។ ឯកឧត្តមបានចូលបម្រើការងារជាមន្ត្រីរាជការតាំងពីឆ្នាំ២០១២ បន្ទាប់ពីបញ្ចប់ការសិក្សានៅប្រទេសអង់គ្លេស។ ក្នុងនោះ ឯកឧត្តមបានចូលរួមបំពេញ និងបង្កើតស្នាដៃជូននាយកដ្ឋាននៃក្រសួងចំនួនពីរ រួមមាន÷ ក្រសួងធនធានទឹក និងឧតុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឯកឧត្តមត្រូវបានតែងតាំងតួនាទីជាបន្តបន្ទាប់ ចាប់ពីតួនាទីជាមន្ត្រីរដ្ឋបាល និងធនធានមនុស្ស ដល់អនុរដ្ឋលេខាលេខាធិការ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ឯកឧត្តម ឃី កុសល បានបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលពាណិជ្ជកម្មពីសាកលវិទ្យាល័យ UWIC ពីទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ឆ្នាំ២០១២ បន្ទាប់ពីបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនៅក្នុងប្រទេសជិនាញសំណង់ស៊ីវិល និងរដ្ឋបាលពាណិជ្ជកម្ម។



លោក ប៉ាក សេរីវឌ្ឍនា បច្ចុប្បន្ន ជាអ្នកប្រឹក្សាយោបល់នៃក្រុមហ៊ុន Axis Investment Consulting ដែលបាននឹងកំពុងគាំទ្រគម្រោងអភិវឌ្ឍន៍អាជីវកម្មពាក់ព័ន្ធនឹងវិស័យកសិកម្ម និងហិរញ្ញវត្ថុជាច្រើនសម្រាប់ស្ថាប័នអង្គការអន្តរជាតិ និងឯកជនក្នុងស្រុក។ បន្ថែមពីការងារប្រឹក្សាយោបល់ លោកធ្លាប់បានបម្រើការងារក្នុងស្ថាប័នអន្តរជាតិInternational Finance Corporation (IFC) និងបំពេញការងារពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុជិត ២០ឆ្នាំ។ ក្នុងនោះលោកបានចូលរួម និងសម្រេចបាននូវគម្រោង និងទិសដៅសំខាន់ៗជូនដល់ស្ថាប័នពាក់ព័ន្ធ រួមមាន÷ គម្រោងអភិបាលកិច្ចសាជីវកម្ម (Corporate Governance Project) សម្រាប់ធនាគារជាតិ នៃកម្ពុជា, គណៈកម្មការមូលបត្រកម្ពុជា, គម្រោងពិពិធកម្មវិស័យកសិកម្មនៅប្រទេសកម្ពុជា, គម្រោងអភិវឌ្ឍន៍ការិយាល័យឥណទានកម្ពុជា (CBC) និងគម្រោងពាក់ព័ន្ធនឹងកំណែទម្រង់ច្បាប់ និងការអន្តរាគមន៍ផ្សេងៗក្នុងវិស័យហិរញ្ញវត្ថុជាមួយក្រុមការងារ IFC។ លើសពីនេះ លោកធ្លាប់បំពេញតួនាទីជាមន្ត្រីបច្ចេកទេសនៅស្ថាប័នរដ្ឋផងដែរ ពោលគឺក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមានបទពិសោធន៍ក្នុងក្រុមហ៊ុនឯកជនផ្សេងៗទៀតផងដែរ។ លោក ប៉ាក សេរីវឌ្ឍនា បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងហិរញ្ញវត្ថុពី Central Queensland University ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៩៧។ ក្រោយបញ្ចប់ការសិក្សានេះ លោកបានកសាងជំនាញផ្នែកវិភាគលើការវិនិយោគ និងហិរញ្ញវត្ថុ, វាយតម្លៃលទ្ធភាព និងការអភិវឌ្ឍផែនការអាជីវកម្ម, វាយតម្លៃឥណទាន និងអភិវឌ្ឍគម្រោង និងការគ្រប់គ្រងគម្រោង។



ឯកឧត្តម ចាន់ សីហា ជាសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារARDB និងជាតំណាងបុគ្គលិក។ ឯកឧត្តមបានបំពេញការងារនៅធនាគារ ARDB ចាប់ពីខែមករា ឆ្នាំ**១៩៩៩** ជាប្រធាននាយកដ្ឋានប្រតិបត្តិការ និងត្រូវបានតែងតាំងជាអគ្គនាយករងទទួល បន្ទុកនាយកដ្ឋានប្រតិបត្តិការ នៅខែកក្កដា ឆ្នាំ២០១២។ ចាប់ពីឆ្នាំ**១៩៩១** ដល់ឆ្នាំ**១៩៩៩** ឯកឧត្តមបានបម្រើការងារជាអនុប្រធានការិយាល័យគ្រប់គ្រងគណនី និងជាប្រធានផ្នែកនៃការិយាល័យសភាជាត់ទាត់នៃនាយកដ្ឋានប្រតិបត្តិការ និងជាបុគ្គលិកគណនេយ្យនៃនាយកដ្ឋានគណនេយ្យនៃធនាគារជាតិនៃកម្ពុជា។

ឯកឧត្តមបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៤ និងបរិញ្ញាបត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារ ប្រទេសវៀតណាម ក្នុងឆ្នាំ**១៩៩១**។

គណៈគ្រប់គ្រង

ធនាគារ ARDB ត្រូវបានដឹកនាំដោយគណៈគ្រប់គ្រង ដែលមានសមាសភាពចំនួន ៤រូបដូចខាងក្រោម÷

១. ឯកឧត្តមបណ្ឌិត កៅ ថាច អគ្គនាយក

២.ឯកឧត្តម ចាន់ សីហា អគ្គនាយករង

៣.ឯកឧត្តម ប៊ិច សានី អគ្គនាយករង

៤.ឯកឧត្តម បាន លឹម អគ្គនាយករង





ឯកឧត្តម ប៊ុច សានី ជាអគ្គនាយករងនៃធនាគារ ARDB។ ឯកឧត្តមមានបទពិសោធន៍ការងារក្នុងវិស័យធនាគារជាង ២០ឆ្នាំមកហើយ។ មុននឹងចូលបម្រើការងារនៅធនាគារARDB ក្នុងឆ្នាំ២០០១ ឯកឧត្តមបានបម្រើការងារ និងមានបទពិសោធន៍ការងារជាច្រើននៅធនាគារជាតិ នៃកម្ពុជា និងនៅធនាគារពាណិជ្ជ។ ឯកឧត្តម ប៊ុច សានី ត្រូវបានតែងតាំងជាអគ្គនាយករងនៃ ធនាគារ ARDB នៅខែតុលា ឆ្នាំ២០០៨។ ឯកឧត្តមបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០៤ និងបរិញ្ញាបត្រផ្នែកធនាគារពីសាកលវិទ្យាល័យបច្ចេកទេសធនាគារ នៅប្រទេសវៀតណាមក្នុងឆ្នាំ១៩៩១។

ឯកឧត្តម ចាន លីម បានចូលបម្រើការងារក្នុងតួនាទីជាអគ្គ-នាយករង នៃធនាគារ ARDB នៅឆ្នាំ២០២១។ ឯកឧត្តមធ្លាប់បានបម្រើការងារជាទីប្រឹក្សាផ្នែកច្បាប់និងមានបទពិសោធន៍ក្នុងវិស័យធនាគាររយៈពេល ២០ឆ្នាំ ក្នុងតួនាទីជាសវនករផ្ទៃក្នុង និងជាមន្ត្រីត្រួតពិនិត្យធនាគារនៅធនាគារជាតិនៃកម្ពុជា។ ឯកឧត្តមទទួលបានបរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលធុរកិច្ច នៅសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅឆ្នាំ២០០៥ និងបានបញ្ចប់បរិញ្ញាបត្រផ្នែកច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចកម្ពុជា នៅឆ្នាំ១៩៩៨។ ក្រៅពីនេះ បច្ចុប្បន្នឯកឧត្តមជាសាស្ត្រាចារ្យក្រៅម៉ោងផ្នែកច្បាប់នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈមេធាវី (LTC) ហើយឯកឧត្តមក៏ធ្លាប់ជាសាស្ត្រាចារ្យផ្នែកច្បាប់ និងបទប្បញ្ញត្តិធនាគារ នៅមជ្ឈមណ្ឌលសម្រាប់ការសិក្សាធនាគារ (CBS) នៃធនាគារជាតិនៃកម្ពុជា និងនៅវិទ្យាស្ថានធនាគារនិងហិរញ្ញវត្ថុ (IBF) របស់សមាគមធនាគារនៅកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំ។



គណៈកម្មាធិការ

គណៈកម្មការសវនកម្ម

គណៈកម្មាការសវនកម្មគឺជាអង្គភាពឯករាជ្យមួយដែលស្ថិតនៅក្រោមក្រុមប្រឹក្សាភិបាល។ គណៈកម្មាការ នេះមានតួនាទីសំខាន់ក្នុងការពង្រឹងអភិបាលកិច្ចសាជីវកម្ម និងការគ្រប់គ្រងហានិភ័យ ដូចខាងក្រោម÷

- ពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃរបាយការណ៍ប្រចាំឆ្នាំរបស់ស្នងការគណនេយ្យឯករាជ្យដើម្បីធានាថាព័ត៌មានដែលផ្តល់ជូនទៅសាធារណៈជន និងធនាគារជាតិនៃកម្ពុជា គឺមានភាពត្រឹមត្រូវ និងច្បាស់លាស់
- ពិនិត្យផ្ទៀងផ្ទាត់ និងផ្តល់អនុសាសន៍ដល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ទៅលើចំណុចខ្វះខាតដែលរកឃើញដោយស្នងការគណនេយ្យឯករាជ្យ ក្រុមអធិការកិច្ចត្រួតពិនិត្យរបស់បញ្ជាត្តិករ និងក្រសួងអាណាព្យាបាល
- វាយតម្លៃភាពសមស្របនៃវិធីសាស្ត្រគណនេយ្យដែលប្រើសម្រាប់រៀបចំគណនីដាច់ដោយឡែក និងគណនីរួម
- ពិនិត្យប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង និងប្រតិបត្តិការរបស់ធនាគារ ARDB តាមរយៈរបាយការណ៍ហិរញ្ញវត្ថុ និងគោលនយោបាយនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ជាពិសេសវាយតម្លៃប្រព័ន្ធសម្រាប់វាស់វែង តាមដាន និងត្រួតពិនិត្យទៅនឹងទម្រង់ការសម្រាប់ការកំណត់នូវអត្តសញ្ញាណកម្មវាយតម្លៃការធ្វើរបាយការណ៍ និងកិច្ចប្រតិបត្តិការ ដើម្បីឱ្យមានសង្គតិភាពតាមគោលនយោបាយ ផែនការ នីតិវិធី និងបទប្បញ្ញត្តិនានាជាធរមាន
- អនុម័តលើរបាយការណ៍សវនកម្មផ្ទៃក្នុងដល់ក្រុមប្រឹក្សាភិបាលធនាគារ
- វាយតម្លៃប្រសិទ្ធភាពការងារបុគ្គលិកលក្ខណៈនិងឯករាជ្យភាពការងាររបស់សវនករផ្ទៃក្នុងនិងពិនិត្យអនុម័តផែនការប្រចាំឆ្នាំរបស់សវនកម្មផ្ទៃក្នុង ដើម្បីធានាបាននូវការគ្រប់គ្រងហានិភ័យរបស់ធនាគារ។

គណៈកម្មការគ្រប់គ្រងហានិភ័យ

គណៈកម្មាការគ្រប់គ្រងហានិភ័យគឺជាគណៈកម្មការស្ថិតនៅក្រោមក្រុមប្រឹក្សាភិបាលផ្ទាល់។ គណៈកម្មាការនេះមានតួនាទីទទួលខុសត្រូវ លើការគ្រប់គ្រងហានិភ័យដូចខាងក្រោម÷

- ពិនិត្យ និងអនុម័តយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ក្របខណ្ឌការងារហានិភ័យ និងការកំណត់ហានិភ័យ
- ពិនិត្យ និងវាយតម្លៃភាពសមស្របនៃគោលនយោបាយ និងក្របខណ្ឌការងារហានិភ័យ ក្នុងការកំណត់អត្តសញ្ញាណ វាស់វែង តាមដាន និងគ្រប់គ្រងហានិភ័យ
- ធានារាល់ដំណើរការចនាសម្ព័ន្ធ ធនធាន និងប្រព័ន្ធគ្រប់គ្រងហានិភ័យ
- ពិនិត្យ និងតាមដានការវិវឌ្ឍទីផ្សារហិរញ្ញវត្ថុក្នុងប្រទេស និងទីផ្សារអន្តរជាតិ ព្រមទាំងស្ថានភាពនយោបាយ
- ធ្វើបច្ចុប្បន្នកម្មគោលនយោបាយ និងនីតិវិធីគ្រប់គ្រងហានិភ័យរបស់ធនាគារ ARDB
- កំណត់នូវបញ្ហាប្រឈមក្នុងការអនុវត្តដែលអាចមានហានិភ័យទៅក្រុមប្រឹក្សាភិបាល ដើម្បីសុំការណែនាំ។

គណៈកម្មការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ

គណៈកម្មាការបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- ដឹកនាំ និងសម្របសម្រួលការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌរបស់ធនាគារ ARDB
- ពិនិត្យនិងតាមដានការរៀបចំ និងនីតិវិធីដើម្បីទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ
- បូកសរុប និងរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនអគ្គនាយកនៃធនាគារ ARDB ពិនិត្យ និងសម្រេច
- ពិនិត្យ និងផ្តល់យោបល់សំណើសុំជម្រះបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ របស់អង្គភាពប្រើប្រាស់ ដើម្បីដាក់ជូនអគ្គនាយកនៃធនាគារ ARDB ពិនិត្យ និងសម្រេច

- ពិនិត្យ និងលើកសំណើសុំលក់ ជួល ផ្ទេរ និងដោះដូរទីតាំងជីធ្លី អគារ ព្រមទាំងជម្រះអចលនទ្រព្យចេញពីបញ្ជីសារពើភណ្ឌរបស់ធនាគារ ARDB
- ចាត់វិធានការជាក់ស្តែងដើម្បីធានាភាពត្រឹមត្រូវ ភាពគ្រប់ជ្រុងជ្រោយ និងភាពទាន់ពេលនៃការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រង ថែរក្សា និងតាមដានការប្រើប្រាស់យានយន្តគ្រប់ប្រភេទរបស់ធនាគារ ARDB
- ពិនិត្យរបាយការណ៍ស្តីពីលទ្ធផលនៃការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ និងលើកសំណើដំណោះស្រាយលើបញ្ហាប្រឈមនានាពាក់ព័ន្ធគណនេយ្យភាព និងបូរណភាពនៃការរៀបចំ និងកត់ត្រាបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ព្រមទាំងការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជូនអគ្គនាយក នៃធនាគារ ARDB ពិនិត្យ និងសម្រេច
- លើកសំណើត្រួតពិនិត្យនិងធ្វើសវនកម្មលើការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពប្រើប្រាស់ព្រមទាំងការជម្រះបញ្ជីទ្រព្យសម្បត្តិរដ្ឋ ចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ជូនអគ្គនាយក នៃធនគារ ARDB ពិនិត្យ និងសម្រេច។

ក្រុមប្រឹក្សាវិន័យ

ក្រុមប្រឹក្សាវិន័យគឺជាគណៈកម្មការពិសេសមួយស្ថិតនៅក្រោមសមត្ថកិច្ចរបស់ថ្នាក់ដឹកនាំប្រតិបត្តិ។ គណៈកម្មការនេះមានតួនាទីដូចខាងក្រោម ÷

- ពិនិត្យ និងវាយតម្លៃលើសំណើសុំតែងតាំង និងដំឡើងឋានៈ និងប្រាក់បៀវត្សរ៍ដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ ដែលបំពេញការងារក្នុងក្របខណ្ឌពេញសិទ្ធិ និងកិច្ចសន្យាការងារ
- ពិនិត្យអំពីកម្រិតប្រាក់បៀវត្សរ៍ និងលាភការផ្សេងៗរបស់បុគ្គលិក
- ពិនិត្យ និងវាយតម្លៃលើសមត្ថភាពការងាររបស់បុគ្គលិកជាប់កិច្ចសន្យាការងារសាកល្បង ដើម្បីបញ្ចូលជាបុគ្គលិកក្របខណ្ឌពេញសិទ្ធិ
- ពិនិត្យនិងវាយតម្លៃបុគ្គលិកគ្រប់ជាន់ថ្នាក់ដើម្បីលើកទឹកចិត្តនិងផ្តល់រង្វាន់សរសើរចំពោះបុគ្គលិកដែលមានគុណសម្បត្តិក្នុងការបំពេញការងារដូចបានចែងក្នុងលក្ខន្តិក:បុគ្គលិក
- ពិនិត្យ និងវាយតម្លៃលើការដាក់ទណ្ឌកម្មចំពោះបុគ្គលិកដែលមិនគោរពវិន័យ ដូចបានចែងក្នុងលក្ខន្តិក:បុគ្គលិក
- ពិនិត្យ និងសិក្សាស្រាវជ្រាវអំពីករណីកំហុសឆ្គងរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់

គណៈកម្មការគាំទ្រនយោបាយរដ្ឋាភិបាល

គណៈកម្មាការគាំទ្រនយោបាយរដ្ឋាភិបាលត្រូវបំពេញតួនាទីនិងភារកិច្ចស្របតាមគោលការណ៍ស្តីពីតួនាទីនិងភារកិច្ចរបស់គណៈកម្មាការគាំទ្រនយោបាយរដ្ឋាភិបាល ដូចខាងក្រោម ÷

- ទំនាក់ទំនង សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍វិស័យកសិកម្ម និងសេដ្ឋកិច្ចជនបទតាមរយៈផ្តល់ការគាំទ្រលើផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស
- សិក្សាគម្រោងនានារបស់រាជរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងបេសកកម្មរបស់ធនាគារ ARDB
- លើកសំណើគាំទ្រផ្នែកបច្ចេកទេស និង/ឬហិរញ្ញវត្ថុដែលធនាគារ ARDB អាចផ្តល់សម្រាប់អនុវត្តគម្រោង
- សិក្សាអំពីតម្រូវការហិរញ្ញវត្ថុរបស់គម្រោងកំណត់ការគាំទ្រផ្នែកហិរញ្ញវត្ថុនិងគោលការណ៍នៃការផ្តល់ហិរញ្ញប្បទានប្រកបដោយប្រសិទ្ធិភាព
- រៀបចំឯកសារគម្រោងអភិវឌ្ឍន៍អាជីវកម្មគំរូដែលអាចជួយកាត់បន្ថយការចំណាយលើផលិតកម្ម
- វាយតម្លៃលទ្ធផលនៃការចូលរួមរបស់ធនាគារ ARDB ក្នុងគម្រោងនានា
- តាមដាន និងវិភាគការប្រើប្រាស់ហិរញ្ញប្បទានដែលធនាគារ ARDB បានផ្តល់
- ទំនាក់ទំនងជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលដើម្បីវិភាគអំពីប្រសិទ្ធិភាពនៃការគាំទ្រផ្នែកហិរញ្ញវត្ថុដល់អ្នកអនុវត្តគម្រោង។

គណៈកម្មការគ្រប់គ្រង និងចាត់ចែងទ្រព្យសកម្ម និងទ្រព្យអកម្ម

គណៈកម្មាការគាំទ្រនយោបាយរដ្ឋាភិបាល មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- រៀបចំក្របខណ្ឌគោលនយោបាយនានា និងកំណត់សិទ្ធអំណាចស្តីពីការកំណត់កម្រិតនៃការទទួលយកហានិភ័យហិរញ្ញវត្ថុ ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងតារាងតុល្យការរបស់ធនាគារ ARDB ដាក់ជូនក្រុមប្រឹក្សាភិបាល នៃធនាគារ ARDB ពិនិត្យ និងអនុម័ត
- ពិនិត្យ និងតាមដានកម្រិតហានិភ័យរបស់ធនាគារ ARDB ដែលអាចប៉ះពាល់ដល់តម្លៃទ្រព្យសកម្ម ទ្រព្យអកម្ម និងមូលនិធិភាគទុនិករបស់ធនាគារ ARDB ដើម្បីសម្រេចចាត់វិធានការសមស្របនឹង កម្រិតនៃការទទួលយកហានិភ័យរបស់ធនាគារ ARDB
- ពិនិត្យ តាមដាន និងវិភាគលើរាល់ការប្រែប្រួល និងការផ្លាស់ប្តូរនៃនិន្នាការអាជីវកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាពិសេសសន្ទនីយភាពអត្រាការប្រាក់និងអត្រាប្តូរប្រាក់ដែលអាចប៉ះពាល់ដល់តម្លៃទ្រព្យសកម្មទ្រព្យអកម្មនិងមូលនិធិភាគទុនិករបស់ធនាគារ ARDB ដើម្បីចាត់វិធានការសមស្រប
- តាមដាននិងត្រួតពិនិត្យលើបទប្បញ្ញត្តិបទដ្ឋានគតិយុត្តគោលនយោបាយនិងនីតិវិធីនានាដែលអាចប៉ះពាល់ដល់ការគ្រប់គ្រងទ្រព្យសកម្ម ទ្រព្យអកម្ម និងមូលនិធិភាគទុនិក របស់ធនាគារ ARDB រួមមានជាអាទិ៍ ការតម្កល់ទុនបម្រុងកាតព្វកិច្ច កម្រិតសន្ទនីយភាពការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្ម និងទ្រព្យអកម្ម ការធ្វើសំវិធានធន និងការលុបចោលទ្រព្យសកម្ម
- ពិនិត្យ និងលើកសំណើលើការវិនិយោគលើបុត្រសម្ព័ន្ធ និង/ឬការចូលភាគកម្មជាមួយដៃគូអាជីវកម្មផ្សេងៗ
- ពិនិត្យ និងលើកសំណើលើផែនការចរិកាប្រចាំឆ្នាំថ្មី ពាក់ព័ន្ធនឹងភាពសមស្របនៃទ្រព្យសកម្ម ទ្រព្យអកម្ម និងមូលនិធិភាគទុនិក ដោយផ្អែកលើផែនការយុទ្ធសាស្ត្រអាជីវកម្មរបស់ធនាគារ ARDB។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា

គណៈកម្មាធិការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- លើកកម្ពស់សមត្ថភាពគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យារបស់ធនាគារARDB ដោយរួមទាំងការសម្របសម្រួលក្នុងការអភិវឌ្ឍជំនាញគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យារបស់ធនាគារ ARDB
- បង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ឱ្យមានប្រសិទ្ធភាព ដើម្បីធានាឱ្យបាននូវភាពសម្ងាត់នៃទិន្នន័យ សន្តិសុខនៃប្រព័ន្ធព័ត៌មានវិទ្យា និងភាពអាចស្តារឡើងវិញបាននូវប្រព័ន្ធព័ត៌មានវិទ្យានៅក្នុងស្ថាប័ន។
- បង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យារួមដែលរួមមានការវាស់វែងកម្រិតហានិភ័យផលប៉ះពាល់និងប្រភេទហានិភ័យ ដោយដាក់បញ្ចូលផងដែរនូវប្រព័ន្ធគ្រប់គ្រង ហានិភ័យដែលមានភាពរឹងមាំ និងនីតិវិធីនៃការអនុវត្តដើម្បីគ្រប់គ្រងហានិភ័យ
- ដាក់ឱ្យអនុវត្តនូវការប្រតិបត្តិនិងត្រួតពិនិត្យឱ្យបានសមស្របដើម្បីកាត់បន្ថយហានិភ័យនិងធ្វើបច្ចុប្បន្នភាពជាទៀងទាត់និងការត្រួតពិនិត្យលើការវាយតម្លៃហានិភ័យទៅតាមកាលកំណត់ ដើម្បីរួមបញ្ចូល និងការផ្លាស់ប្តូរក្នុងលក្ខខណ្ឌប្រព័ន្ធព័ត៌មានវិទ្យា លក្ខខណ្ឌបរិស្ថាន ឬលក្ខខណ្ឌប្រតិបត្តិការ ដែលអាចប៉ះពាល់ដល់ការវិភាគហានិភ័យ
- ធានាឱ្យបាននូវការអនុវត្តគោលនយោបាយ និងនីតិវិធីដូចដែលបានកំណត់ដោយធនាគារ ARDB។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យព័ត៌មានវិទ្យា

គណៈកម្មាធិការយុទ្ធសាស្ត្រព័ត៌មានវិទ្យាមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

- បំពេញការងារស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារ ARDB
- ត្រួតពិនិត្យសកម្មភាពការងាររបស់គណៈកម្មាធិការតម្រង់ទិសព័ទ៌មានវិទ្យានៃធនាគារ ARDB
- ធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រព័ត៌មានវិទ្យា ដើម្បីឆ្លើយតបជាមួយនឹងតម្រូវការ ឬផែនការអាជីវកម្មរបស់ ធនាគារ ARDB
- ធានាឱ្យបាននូវរចនាសម្ព័ន្ធនៃអង្គភាពព័ត៌មានវិទ្យាដែលអាចជួយបំពេញបន្ថែមដល់តម្រូវការអាជីវកម្ម
- ធានាឱ្យបាននូវបច្ចេកវិទ្យាព័ត៌មានវិទ្យាឱ្យបានគ្រប់គ្រាន់សម្រាប់ការធ្វើប្រតិបត្តិការនិងការគ្រប់គ្រងហានិភ័យផ្នែកព័ត៌មានវិទ្យា។

៣. សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៥

វិសាលភាពប្រតិបត្តិការរបស់ធនាគារ ARDB នៅក្នុងប្រទេសកម្ពុជា..... ២០
ដៃគូរសហការនៃធនាគារ ARDB..... ២១-២២
ទិន្នន័យហិរញ្ញវត្ថុសង្ខេប ២៣
សំពៀតឥណទាន និងចំនួនអតិថិជនឆ្នាំ២០២៥..... ២៤-២៧
ផលិតផលនិងសេវាកម្ម..... ២៩-៣៤
ទូរទស្សន៍អនឡាញនៃធនាគារ ARDB..... ៣៥
ការវាយតម្លៃដោយចីរភាព ៣៦
ប្រព័ន្ធវដ្តកសាស្ត្របៃតងនៃធនាគារ ARDB ៣៧

៣. សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០២៥

វិសាលភាពទីតាំងប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្មនៅក្នុងប្រទេសកម្ពុជា



បច្ចុប្បន្ន, ធនាគារARDB មានទីស្នាក់ការកណ្តាលចំនួន ១ កន្លែង, សាខាចំនួន ២ កន្លែង, និង ការិយាល័យចល័តចំនួន ១៦។ ក្នុងនោះរួមមាន ទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញចំនួន ១, សាខាចំនួន ២ ដែលមានទីតាំងនៅខេត្តបាត់ដំបង និង រាជធានីភ្នំពេញ, ព្រមទាំងការិយាល័យចល័តចំនួន ១៦ នៅខេត្តមួយចំនួន ដូចជា ខេត្ត បន្ទាយមានជ័យ, ឧត្តរមានជ័យ, ពោធិ៍សាត់, កំពង់ធំ, ព្រះវិហារ, ព្រៃវែង, ត្បូងឃ្មុំ, ស្វាយរៀង, កំពង់ស្ពឺ, តាកែវ, ស្ទឹងត្រែង, សៀមរាប, កំពង់ចាម, កំពង់ឆ្នាំង, ក្រចេះ, និង រតនគីរី។

ការិយាល័យចល័តនីមួយៗបានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួន តាមរយៈការជំរុញនូវការផ្តល់កម្ចីឱ្យកាន់តែមានភាពទូលំទូលាយជាងមុន ស្របតាមផែនទីចង្អុលផ្លូវរយៈពេល ១០ឆ្នាំ របស់ ធនាគារARDB ដែលសំដៅពង្រីកទីតាំងនិងបណ្តាញផ្តល់សេវា ព្រមទាំងការិយាល័យចល័តរបស់ធនាគារឱ្យឈានដល់គ្រប់ខេត្ត និងក្រុង ជាមួយនឹងការផ្តល់សេវាធនាគារឌីជីថល, បង្កើនការផ្តល់សេវារបស់ធនាគារARDB ដល់អតិថិជនគោលដៅ, ក៏ដូចជារួមចំណែកដល់ការលើកកម្ពស់បរិយាប័ន្ធហិរញ្ញវត្ថុជាពិសេសនៅតំបន់ជនបទ។

ដៃគូរសហការនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ធនាគារ ARDB បានក្លាយជាសមាជិករបស់ស្ថាប័នអភិវឌ្ឍន៍តំបន់ចំនួន ២ ដែលរួមមាន សមាគមឥណទានជនបទ និងកសិកម្មតំបន់អាស៊ីប៉ាស៊ីហ្វិក (APRACA) និងសមាគមគ្រឹះស្ថានហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍តំបន់អាស៊ី និងប៉ាស៊ីហ្វិក (ADFIAP)។



ធនាគារARDB បានសហការជាមួយដៃគូអភិវឌ្ឍន៍ជាតិ និងអន្តរជាតិមួយចំនួន ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ផ្សេងៗ របស់ ធនាគារARDB ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ធនាគារARDB មានដៃគូអភិវឌ្ឍន៍ជាតិដូចជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF), សមាគមធនាគារនៅកម្ពុជា (ABC), ក្រសួងពាណិជ្ជកម្ម (MoC), ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF), ក្រសួងបរិស្ថាន (MoE), ក្រសួងធនធានទឹក និងឧតុនិយម (MOWRAM), អគ្គិសនីកម្ពុជា (EDC) , សហព័ន្ធស្រូវអង្ករកម្ពុជា (CRF), គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD), ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD), សមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា (CVP), គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ (OVOP National Committee), និង Cambodia-China Councils Association for Economic Development, Youth Development Department (CICC-CAFED, YDD).

ធនាគារ ARDB មានដៃគូអភិវឌ្ឍន៍អន្តរជាតិដូចជា ធនាគារពិភពលោក (WB), មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD), ធនាគារអភិវឌ្ឍន៍តំបន់អាស៊ី (ADB), ទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD), ធនាគារអភិវឌ្ឍន៍កូរ៉េ (KDB), មូលនិធិអាកាសធាតុបៃតង (GCF), ធនាគារអភិវឌ្ឍន៍កសិកម្មចិន (ADCB), ធនាគារឧស្សាហកម្ម និងពាណិជ្ជកម្មចិន (ICBC Phnom Penh), ប្រព័ន្ធទូទាត់អន្តរធនាគារឆ្លងព្រំដែន (CIPS), ធនាគារជាតិសម្រាប់កសិកម្ម និងអភិវឌ្ឍន៍ជនបទ (NABARD), ធនាគារសម្រាប់កសិកម្ម និងសហករណ៍កសិកម្ម (BAAC), and Guangxi Beibu Gulf Bank (BGB).

ធនាគារ ARDB បានសហការជាមួយគ្រឹះស្ថានហិរញ្ញវត្ថុជាច្រើននៅក្នុងប្រទេស។ ក្នុងនោះរួមមាន ធនាគារប្រៃសណីយ៍កម្ពុជា (CP Bank) និងអង្គរមីក្រូហិរញ្ញវត្ថុ (AMK) ជាដៃគូគម្រោង, ធនាគារ វីង ជាដៃគូទូទាត់ឥណទាន, ធនាគារកាណាឌីយ៉ា ជាដៃគូក្នុងការសម្របសម្រួលចេញផ្សាយមូលប្បទានបត្រ, ធនាគារ CIMB of Thailand និងធនាគារ អេស៊ីលីដា ភីអិលស៊ី កម្ពុជា ជាដៃគូក្នុងការបង្កើនទំហំសហហិរញ្ញប្បទានដែលអាចចែករំលែកហានិភ័យ, ធនាគារសហករណ៍ និងកសិកម្មថៃ (BAAC) និងជាដៃគូសហការបន្ថែមលើគម្រោងហិរញ្ញប្បទានពិសេសរបស់រាជរដ្ឋាភិបាលដែលសំដៅគាំទ្រដល់វិស័យកសិកម្ម។

និន្នាំយហិរញ្ញវត្ថុសង្ខេប

ចំណូល: ២៥ ៦៥៩ ៦៧៨ (គិតជា ដុល្លារអាម៉េរិក)



ចំណេញ/ខាត: (១,៧៥៦,៤៩៦) (គិតជា ដុល្លារអាម៉េរិក)



ទ្រព្យសកម្មសរុប (គិតជា លានដុល្លារអាម៉េរិក)



ប្រាក់បញ្ញើសរុប (គិតជា លានដុល្លារអាម៉េរិក)



តំណទាន និងបុរេប្រទាន (គិតជា លានដុល្លារអាម៉េរិក)



គណនីប្រាក់បញ្ញើសរុប



សំពៀតឥណទាន និងចំនួនអតិថិជន ឆ្នាំ២០២៥

ចំនួនសំពៀតឥណទានសរុប



ចំនួនអតិថិជនឥណទានសរុប



សំពៀតឥណទាន និងចំនួនអតិថិជន បែងចែកតាមវិស័យ



GRI 2-6: សកម្មភាព ខ្សែសង្វាក់ផលិតកម្មផ្សេងៗ និងទំនាក់ទំនងអាជីវកម្ម
GRI 201-1: ផលវិជ្ជមានទៅលើសេដ្ឋកិច្ចដោយផ្ទាល់ ដែលទទួលបាននិងចែកចាយ



ទំហំឥណទានបែងចែកតាមភូមិសាស្ត្រ



សំឡៀតឥណទានបៃតងបែងចែកតាមវិស័យ



ចំនួនអតិថិជនបៃតងតាមវិស័យ



GRI 2-6: សកម្មភាព ខ្សែសង្វាក់ផលិតកម្មផ្សេងៗ និងទំនាក់ទំនងអាជីវកម្ម
GRI 201-1: ផលវិជ្ជមានទៅលើសេដ្ឋកិច្ចដោយផ្ទាល់ ដែលទទួលបាននិងចែកចាយ

ប្រាក់បញ្ញើ

សមតុល្យប្រាក់បញ្ញើតាមប្រភេទគណនី (គិតជា លានដុល្លារអាម៉េរិក)



ចំនួនគណនីតាមប្រភេទប្រាក់បញ្ញើ



GRI 2-6: សកម្មភាព ខ្សែសង្វាក់ផលិតកម្មផ្សេងៗ និងទំនាក់ទំនងអាជីវកម្ម
GRI 201-1: ផលវិជ្ជមានទៅលើសេដ្ឋកិច្ចដោយផ្ទាល់ ដែលទទួលបាននិងចែកចាយ

ផលិតផល និងសេវាកម្ម

ឥណទាន

ធនាគារ ARDB ផ្តល់សេវាហិរញ្ញប្បទាន និងសេវាធនាគារដល់ភាគីពាក់ព័ន្ធសំខាន់ៗនៅក្នុងខ្សែច្រវាក់តម្លៃកសិកម្មរួមមាន កសិករ សហគមន៍កសិកម្ម សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSMEs) ព្រមទាំងអតិថិជននៅតំបន់ជនបទផ្សេងៗទៀត។ ផលិតផលឥណទាន និងសេវាឥណទានរបស់យើង ត្រូវបានរៀបចំឡើងដើម្បីបង្កើនលទ្ធភាពទទួលបានទុន និងលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពនៅតំបន់ជនបទ និងវិស័យកសិកម្ម។ យើងផ្តល់ទុនបង្វិល និងទុនវិនិយោគ ដែលត្រូវបានរៀបចំសមស្របតាមតម្រូវការរបស់អាជីវកម្ម និងអ្នកផលិត ដែលចូលរួមក្នុងការដាំដុះ កែច្នៃ ស្តុកទុក ចែកចាយ និងនាំចេញផលិតផលកសិកម្ម។



ឥណទានសហគ្រាសធនតូច និងមធ្យមក្នុងវិស័យកសិកម្ម

ឥណទាននេះត្រូវបានផ្តល់ជូនទាំងរូបវន្តបុគ្គល និងនីតិបុគ្គលដែលចូលរួមក្នុងខ្សែច្រវាក់តម្លៃកសិកម្ម។ អ្នកខ្ចីដែលមានសិទ្ធិរួមមាន ភាគីពាក់ព័ន្ធដែលចូលរួមក្នុងការ ផលិត កែច្នៃ ស្តុកទុក ចែកចាយ និងនាំចេញផលិតផលកសិកម្ម ជាពិសេសក្នុងវិស័យស្រូវអង្ករ និងអនុវិស័យអាទិភាពផ្សេងៗ ដែលរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ឥណទាននេះត្រូវបានផ្តល់ជូនក្នុងអត្រាការប្រាក់អនុគ្រោះស្របតាមគោលបំណងនៃហិរញ្ញប្បទានអភិវឌ្ឍន៍។



ឥណទានសហគមន៍កសិកម្ម

ឥណទាននេះត្រូវបានផ្តល់ជូនដើម្បីគាំទ្រការពង្រឹង និងពង្រីកសកម្មភាពអាជីវកម្មរបស់សហគមន៍កសិកម្ម ក្រុមផលិតករ និងសហគមន៍ផ្សេងៗទៀត ដើម្បីបង្កើនប្រាក់ចំណូលរបស់សមាជិកសហគមន៍ ឬក្រុមផលិតកររឲ្យមានចីរភាព។ អត្រាការប្រាក់អាស្រ័យលើប្រភពមូលនិធិ។



ឥណទានកសិកម្មខ្នាតតូច

ឥណទាននេះត្រូវបានផ្តល់ជូនដល់បុគ្គល ដែលមានអាជីវកម្ម ពាក់ព័ន្ធនឹងវិស័យកសិកម្ម ដើម្បីពង្រឹងសមត្ថភាពកសិករឱ្យអាច ដាំដុះ កែច្នៃ និងផ្គត់ផ្គង់ផលិតផលកសិកម្មក្នុងបរិមាណច្រើន និង គុណភាពខ្ពស់ ដើម្បីបង្កើនប្រាក់ចំណូលឱ្យបានអតិបរមា។



ឥណទានសម្រាប់គ្រឹះស្ថានហិរញ្ញវត្ថុ (ឥណទានបោះដុំ)

ឥណទាននេះត្រូវបានផ្តល់ជូនដល់ស្ថាប័នហិរញ្ញវត្ថុ ដែលមាន អាជ្ញាប័ណ្ណ (MFIs) ដែលគាំទ្រវិស័យកសិកម្ម រួមធនាគារពាណិជ្ជ ស្ថាប័នមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ (MDIs) ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFIs) និងក្រុមហ៊ុនជួលហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ ពីធនាគារជាតិកម្ពុជា និងអនុលោមតាមលក្ខខណ្ឌបទប្បញ្ញត្តិ ដែលពាក់ព័ន្ធ។ លើសពីនេះ ធនាគារ ARDB ក៏ផ្តល់ឥណទាន បោះដុំដល់ស្ថាប័នហិរញ្ញវត្ថុចូលរួម (PFIs) ក្រោមគម្រោងពិពិធ-កម្មកសិកម្មកម្ពុជា (CASDP) ស្របតាមក្របខណ្ឌហិរញ្ញប្បទាន របស់គម្រោង។



ឥណទានវិស័យស្រូវអង្ករ

ឥណទាននេះ ត្រូវបានផ្តល់ជូនដល់ក្រុមហ៊ុន ប្រមូលទិញលក់ ស្រូវអង្ករ រោងម៉ាស៊ីនកិនស្រូវ ឃ្លាំងស្តុកទុក ពាណិជ្ជករស្រូវ ដែល មានអាជ្ញាប័ណ្ណ អ្នកប្រតិបត្តិការម៉ាស៊ីនសម្ងួតគ្រាប់ធញ្ញជាតិ។ ឥណទាននេះ ត្រូវបានផ្តល់ជូនក្នុងអត្រាការប្រាក់អនុគ្រោះស្រប តាមក្របខណ្ឌគោលនយោបាយដែលអនុវត្ត។



ឥណទានបៃតង

ឥណទានបៃតង គឺជាយន្តការហិរញ្ញប្បទានដែលបានរៀបចំឡើង សម្រាប់ការផ្តល់មូលនិធិគាំទ្រដល់ការវិនិយោគក្នុងវិស័យកសិកម្ម ប្រកបដោយចីរភាព និងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ សកម្មភាពសំខាន់ក្រោមយន្តការហិរញ្ញប្បទាននេះ មានដូចជា ការដាំបន្លែសុវត្ថិភាព, ការដាំដុះក្នុងផ្ទះសំណាញ់, ប្រព័ន្ធធារាសាស្ត្រ, ការប្រើប្រាស់ថាមពលសូឡា និងថាមពលកកើតឡើងវិញ, ការរៀបចំ ជីវឧស្ម័ន ការដាំដុះបែបអ៊ីដ្រូប៉ូនិក (គ្មានដី), ប្រព័ន្ធអាក្វាប៉ូនិក និងការអនុវត្តកសិកម្មបែបឆ្លាតវៃផ្សេងៗ។ ផលិតផលនេះផ្តល់ការគាំទ្រដល់អតិថិជនក្នុងការអនុវត្តកសិកម្មបៃតងនៅក្នុងអត្រាការប្រាក់ទាបស្របតាមគោលការណ៍ឥណទានហិរញ្ញប្បទានបៃតង ដែលបានដាក់ចេញឱ្យអនុវត្តក្នុងក្របខ័ណ្ឌរបស់ធនាគារ។



ឥណទានសម្រាប់សហគ្រិនស្ត្រីក្នុងវិស័យកសិកម្ម

ឥណទានថ្មីនេះ ត្រូវបានរៀបចំឡើងដើម្បីផ្តល់ការគាំទ្រហិរញ្ញវត្ថុជាក់លាក់ដល់សហគ្រិនស្ត្រី ដែលចូលរួមក្នុងខ្សែច្រវាក់តម្លៃកសិកម្ម និងឧស្សាហកម្មកសិកម្ម។ កម្មវិធីនេះមានគោលបំណងពង្រឹងសមត្ថភាពផលិត និងនវានុវត្តន៍របស់ពួកគេ ដើម្បីបំពេញតម្រូវការទីផ្សារបានប្រកបដោយប្រសិទ្ធភាព។ តាមរយៈការសម្រួលការទទួលបានហិរញ្ញប្បទាន ឥណទាននេះមានបំណងពង្រីកឱកាសការងារ បង្កើនប្រាក់ចំណូល និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមទូលំទូលាយរបស់ប្រទេសកម្ពុជា។



ប្រាក់បញ្ញើ

ប្រាក់បញ្ញើសន្សំ

គឺជាគណនីដែលអាចដក ដាក់ប្រាក់តាមតំរូវការ គ្មានកាលកំណត់ និងអាចប្រើប្រាស់ជាមួយ សៀវភៅគណនី សេវាធនាគារឌីជីថល ARDB Mobile App សេវាបាគង បំណុ្ត អេធីអឹម ម៉ាស៊ីនស្កាត POS ជាដើម។



គណនីប្រាក់បញ្ញើរចរន្ត

គឺជាគណនីប្រាក់បញ្ញើ ដែលអនុញ្ញាតឱ្យអតិថិជនដក និងដាក់ប្រាក់បានតាមតម្រូវការ។ គណនីនេះផ្តល់សិទ្ធិឱ្យម្ចាស់គណនីអាចចេញមូលប្បទានប័ត្រ ហើយប្រតិបត្តិការដកប្រាក់ពីក្នុងគណនីចរន្តអាចប្រព្រឹត្តទៅបានដោយផ្អែកលើសមតុល្យ ដែលមានៅក្នុងគណនី។



គណនីប្រាក់បញ្ញើមានកាលកំណត់

គណនីប្រាក់បញ្ញើមានកាលកំណត់ គឺជាគណនីដែលអតិថិជនអាចជ្រើសរើសរយៈពេលកំណត់ជាក់លាក់ សម្រាប់ការដាក់ប្រាក់សន្សំ និងទទួលបានអត្រាការប្រាក់ខ្ពស់ពីធនាគារ ARDB ដោយមានរយៈពេលសន្សំដែលមានរយៈរហូតដល់ 24 ខែ។



សេវាធនាគារឌីជីថល

កម្មវិធី ARDB Mobile Application

ដោយសារតែធនាគារ ARDB បានទទួលឃើញពីឱកាស នៃសេវាធនាគារតាមទូរស័ព្ទចល័តដែលកំពុងមានការរីកចម្រើនដែលកំពុងខិតខំអភិវឌ្ឍបង្កើនគុណភាព និងបន្ថែមមុខងារថ្មីៗនៅក្នុងកម្មវិធី ARDB Mobile Application ដើម្បីបង្កើតកម្មវិធីដែលមានគុណភាព និងសមត្ថភាពប្រកួតប្រជែងបានយ៉ាងមានប្រសិទ្ធភាព។ ក្រៅពីនេះកម្មវិធី ARDB Mobile Application ក៏មានមុខងារច្រើនដូចជា÷ ការពិនិត្យសមតុល្យក្នុងគណនី ការពិនិត្យសមតុល្យឥណទាន ការផ្ទេរប្រាក់ ការទូទាត់វិក្កយបត្រ ការផ្តល់សេវាផ្អែកលើទូរស័ព្ទ ការដាក់ពាក្យស្នើសុំឥណទាន ព័ត៌មានអត្រាប្តូរប្រាក់ និងសមត្ថភាពក្នុងការស្វែងរកឯកសារ និងព័ត៌មានដែលពាក់ព័ន្ធនឹងវិស័យកសិកម្មតាមរយៈការតភ្ជាប់ទៅកាន់គេហទំព័ររបស់ធនាគារ ARDB ដោយមានភាពងាយស្រួល ល្បឿនលឿន និងសុវត្ថិភាព។



ប្រព័ន្ធបាគង និង KHQR

ធនាគារ ARDB បានក្លាយជាសមាជិកជោគជ័យនៃប្រព័ន្ធបាគងរបស់ធនាគារជាតិនៃកម្ពុជា ដែលមានគោលបំណងផ្តល់សេវាធនាគារឌីជីថលដ៏ងាយស្រួល និងរហ័សដល់អតិថិជនទាំងអស់ដោយអាចប្រើប្រាស់ និងប្រតិបត្តិការបានពីធនាគារក្នុងស្រុកទាំងអស់ដែលជាសមាជិកនៃប្រព័ន្ធបាគង។ សេវាបង់ប្រាក់តាមប្រព័ន្ធបាគងគឺជាប្រព័ន្ធបង់ប្រាក់លក់រាយ (Retail Payment System) ដែលមានគោលបំណងជំរុញការប្រើប្រាស់ប្រាក់ឌីជីថល និងធ្វើឱ្យប្រតិបត្តិការហិរញ្ញវត្ថុកាន់តែងាយស្រួល សុវត្ថិភាព និងមានប្រសិទ្ធភាព។



ម៉ាស៊ីនឌូទាត់ប្រាក់ (ATM) និងកាត Debit

ធនាគារ ARDB បានដាក់ឱ្យប្រើប្រាស់ម៉ាស៊ីនទូទាត់ប្រាក់ស្វ័យប្រវត្តិ (ATM) សម្រាប់បុគ្គលិក និងអតិថិជនរបស់ខ្លួន រួមទាំងបុគ្គលដែលមានបំណងប្រើប្រាស់សេវាស្នើសុំដកប្រាក់ និងដាក់ប្រាក់ស្វ័យប្រវត្តិ។ អតិថិជន និងបុគ្គលិកអាចប្រតិបត្តិការបានគ្រប់ពេលវេលា និងគ្រប់ទីកន្លែងដែលមានម៉ាស៊ីន ATM នៅក្នុងប្រព័ន្ធ ដោយមានជម្រើសបីប្រភេទនៃកាត ATM រួមមាន÷ កាតឌិបីតប្រភេទ Classic, Gold និង VIP។



ពាណិជ្ជករ

សម្រាប់ពាណិជ្ជករ និងអ្នកជួញដូរទាំងអស់ ដែលមានបំណងប្រើប្រាស់សេវាបង់ប្រាក់របស់ធនាគារ ARDB សម្រាប់ប្រតិបត្តិការអាជីវកម្ម អ្នកអាចដាក់ពាក្យស្នើសុំប្រើសេវាបង់ប្រាក់របស់ ធនាគារ ARDB ហើយបើបំពេញតាមលក្ខខណ្ឌ ដែលបានកំណត់ អ្នកនឹងទទួលបានសិទ្ធិប្រើប្រាស់សេវាការបង់ប្រាក់នោះភ្លាមៗ។



ហិរញ្ញវត្ថុពាណិជ្ជកម្ម

ឧបករណ៍ និងផលិតផលហិរញ្ញវត្ថុពាណិជ្ជកម្មរបស់ធនាគារ ARDB រួមមាន÷

- ការផ្ទេរប្រាក់អន្តរជាតិ
- សេវាកម្មប្រមូលឯកសារទូទាត់
- សេវាកម្មលិខិតឥណទាន
- សេវាកម្មលិខិតធានា
- ការចរចារវិក្កយបត្រផ្លាស់ប្តូរសម្រាប់ការនាំចេញក្រោមលិខិតឥណទាន (LC-SIGHT)



គណនេយ្យអនឡាញ

គណនីអនឡាញគឺជាប្រភេទគណនីប្រាក់បញ្ញើសន្សំដែលអនុញ្ញាតឱ្យអតិថិជនថ្មី ដែលមិនទាន់មានគណនីជាមួយធនាគារ ARDB អាចបើកគណនីដោយខ្លួនឯង និងចាប់ផ្តើមប្រើប្រាស់បានភ្លាមៗ តាមរយៈកម្មវិធី ARDB Mobile App។



ទូរទស្សន៍អនឡាញនៃធនាគារ ARDB



កម្មវិធីទូរទស្សន៍ (ARDB TV) បានបន្តការផ្សាយតាមរយៈផ្កាយរណប DTH (24/7) ដោយផលិតកម្មវិធីប្រចាំឆ្នាំសរុបចំនួន ២ ៥២២ កម្មវិធី និងទទួលបានការទស្សនាសរុបចំនួន ៦ ១៦៤ ២៩២ដង។ កម្មវិធីទាំងនេះរួមមានព័ត៌មានកសិកម្មក្នុងស្រុកចំនួន ៥៦៥ កម្មវិធី, ព័ត៌មានអន្តរជាតិចំនួន ៥០៣ កម្មវិធី, វីដេអូសង្ខេបព័ត៌មានចំនួន ៤៨ ព័ត៌មានគ្រប់គ្រងចំនួន២១៧ គោលនយោបាយកសិកម្មចំនួន ៨៤ បច្ចេកវិទ្យា និងនវានុវត្តន៍ចំនួន ៩៣ អត្ថប្រយោជន៍នៃបន្លែ និងផ្លែឈើចំនួន ៨៥ វឌ្ឍនភាពកសិករចំនួន ៩៧ កម្មវិធីអំពីសត្វចិញ្ចឹម និងវារីវប្បកម្មចំនួន ១៥ សារពិសេសចំនួន ២៨ បច្ចេកទេស និងនវានុវត្តន៍កសិកម្មចំនួន ៩ ចំណេះដឹងហិរញ្ញវត្ថុចំនួន ៩ កម្មវិធីកម្សាន្តចំនួន ២១ កិច្ចសម្ភាសន៍ពិសេសចំនួន ៣៦ តម្លៃទំនិញប្រចាំថ្ងៃចំនួន ១៤៨ ព្រឹត្តិការណ៍ធនាគារចំនួន ១៥ ព័ត៌មានផ្សេងៗចំនួន ៥១៨ និងកម្មវិធីបុណ្យជាតិ កម្មវិធីតន្ត្រី និងកម្មវិធី TVC ចំនួន ៣១។

ការគាំទ្រផ្នែកបច្ចេកទេសដល់សហគមន៍មូលដ្ឋាន





ក្នុងឆ្នាំ ២០២៥ ធនាគារ ARDB បានបន្តគាំទ្រការបណ្តុះបណ្តាលបច្ចេកទេសកសិកម្ម និងចំណេះដឹងហិរញ្ញវត្ថុដល់សហគមន៍មូលដ្ឋាននៅទូទាំង ២៣ រាជធានី-ខេត្តក្នុងប្រទេសកម្ពុជា។ ធនាគារបានរៀបចំ និងផ្សព្វផ្សាយឯកសារណែនាំបច្ចេកទេសកសិកម្មចំនួន ១៨ ឯកសារ និងព្រឹត្តិប័ត្រកសិកម្មចំនួន ១៣ ដែលផ្តោតលើជំងឺដំណាំ ការគ្រប់គ្រងសត្វល្អិត និងវិធានការការពារ។ ដើម្បីគាំទ្រសកម្មភាពអភិវឌ្ឍវិស័យកសិកម្មរបស់ធនាគារ ARDB បានរៀបចំឯកសារវិភាគចំនួន ១៥ ស្តីពីថ្លៃដើមផលិតកម្មកសិកម្ម និងការគ្រប់គ្រងហានិភ័យ។ បន្ថែមពីនេះ ក្រុមបច្ចេកទេសកសិកម្មរបស់ ធនាគារ ARDB បានចុះផ្តល់ ជំនួយបច្ចេកទេសកសិកម្ម នៅទូទាំង ២៣ រាជធានី ខេត្ត ដើម្បីគាំទ្រកសិករ សហគមន៍កសិកម្ម និងក្រុមផលិត តាមរយៈការផ្តល់ការណែនាំអំពីបច្ចេកទេសផលិតកម្មកសិកម្ម និងការពង្រឹងសមត្ថភាពកសិករដល់គ្រួសារកសិករចំនួន ៧៦ គ្រួសារ។ លើសពីនេះ ក្រុមការងារបច្ចេកទេសបានផ្តល់ វគ្គបណ្តុះបណ្តាលចំនួន ១០វគ្គ ផ្តោតលើបច្ចេកទេសកសិកម្ម និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដល់គ្រួសារកសិករចំនួន ៦៦ គ្រួសារ ដើម្បីពង្រឹងការយល់ដឹងរបស់កសិករ លើការគ្រប់គ្រងហិរញ្ញវត្ថុ និងការអនុវត្តកសិកម្មប្រកបដោយចីរភាព។ តាមរយៈសកម្មភាពទាំងនេះ ធនាគារ ARDB តែងតែបង្ហាញពីការប្តេជ្ញាចិត្តក្នុងការលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្ម និងការលើកស្ទួយជីវភាពប្រជាពលរដ្ឋនៅតំបន់ជនបទ។

ការវាយតម្លៃបឋមនៃការអនុវត្តក្នុងការក្លាយជាធនាគារផ្តល់ហិរញ្ញប្បទានបៃតងប្រកបដោយចីរភាព (Sustainability Assessment)

ក្នុងឆ្នាំ ២០២៥ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានបញ្ចប់ការវាយតម្លៃគោលនយោបាយចីរភាពផ្ទៃក្នុង ដើម្បីឆ្ពោះទៅសម្រេចចក្ខុវិស័យឆ្នាំ ២០៣៣ របស់ធនាគារ ក្នុងការក្លាយជាគ្រឹះស្ថានផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាពឈានមុខគេនៅកម្ពុជា។ ការវាយតម្លៃនេះមានគោលបំណងពិនិត្យ និងស្វែងយល់ពីសមត្ថភាពរបស់ធនាគារ ARDB ក្នុងការបញ្ចូលគោលការណ៍បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ទៅក្នុងយុទ្ធសាស្ត្រ អភិបាលកិច្ច ការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិការ។ គំនិតផ្តួចផ្តើមនេះឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់ ARDB ក្នុងការអនុវត្តសកម្មភាពសំខាន់ៗនៃវិស័យធនាគារប្រកបដោយចីរភាពកម្រិតអន្តរជាតិ និងការពង្រឹងភាពធន់រយៈពេលវែងរបស់ស្ថាប័ន។

ក្របខណ្ឌនៃការវាយតម្លៃរបស់ ARDB បានបង្ហាញតាមរយៈមុំយុទ្ធសាស្ត្រសំខាន់ៗចំនួន ៥ នៃការអនុវត្តធនាគារប្រកបដោយចីរភាពរួមមាន÷(១) គោលនយោបាយនិរន្តរភាពផ្ទៃក្នុង និងការប្តេជ្ញាចិត្តក្នុងការអនុវត្តយុទ្ធសាស្ត្រ(២) អភិបាលកិច្ច សាជីវកម្ម (៣) តម្លាភាព និងការទំនាក់ទំនង (៤) ការគ្រប់គ្រងហានិភ័យ និង (៥) ផលិតផល និងសេវាកម្ម ។

ក្របខណ្ឌមុំយុទ្ធសាស្ត្រទាំង ៥ នេះធានាថា ការវាយតម្លៃចីរភាពត្រូវបានពិនិត្យយ៉ាងពេញលេញ ចាប់ពីយុទ្ធសាស្ត្រ និងអភិបាលកិច្ច រហូតដល់ការគ្រប់គ្រងហានិភ័យ និងការអនុវត្តជាក់ស្តែង។

ជាលទ្ធផលបានបង្ហាញថា ARDB ស្ថិតនៅក្នុង “ដំណាក់កាលកំពុងរៀបចំគោលនយោបាយ” នៃការផ្លាស់ប្តូរទៅជាធនាគារប្រកបដោយចីរភាព។ នៅក្នុងដំណាក់កាលនេះ ធនាគារបង្ហាញពីផែនការយុទ្ធសាស្ត្រសំខាន់ៗ និងការចូលរួមយ៉ាងសកម្មនូវគំនិតផ្តួចផ្តើមហិរញ្ញប្បទានបៃតង ប៉ុន្តែទាមទារឱ្យមានការពង្រឹងសមត្ថភាពស្ថាប័នបន្ថែមទៀត ដើម្បីរៀបចំរចនាសម្ព័ន្ធអភិបាលកិច្ចឱ្យមានលក្ខណៈជាផ្លូវការ ព្រមទាំងបញ្ចូលគោលការណ៍ ESG ឱ្យបានពេញលេញក្នុងដំណើរការសំខាន់ៗទាំងអស់នេះ។

អាស្រ័យហេតុនេះ ការវាយតម្លៃដោយចីរភាព គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ក្នុងការឆ្លុះបញ្ចាំងការប្តេជ្ញាចិត្តរបស់ធនាគារ ARDB រួមមាន÷

- ការបង្កើតមូលដ្ឋានគ្រឹះប្រកបដោយចីរភាព
- រៀបចំស្ថាប័នឱ្យស្របទៅនឹងបទដ្ឋាន និងការអនុវត្តតាមស្តង់ដារកម្រិតអន្តរជាតិ
- ផ្លាស់ប្តូរពីការអនុវត្តដោយឡែកទៅជាសមាហរណកម្ម
- ពង្រឹងភាពធន់របស់ស្ថាប័ន
- បម្លែងពីយុទ្ធសាស្ត្រទៅការអនុវត្តជាក់ស្តែង

តាមរយៈការវាយតម្លៃចីរភាពផ្ទៃក្នុងនេះ ធនាគារ ARDB រំពឹងថានឹងបង្កើតបាននូវរចនាសម្ព័ន្ធអភិបាលកិច្ចប្រកបដោយចីរភាពមួយ ដែលមានលក្ខណៈប្រមូលផ្តុំ និងមានការបែងចែកការទទួលខុសត្រូវច្បាស់លាស់។ ទន្ទឹមនឹងនេះ កត្តា ESG នឹងត្រូវបញ្ចូលបន្ថែមទៅក្នុងដំណើរការផ្តល់ឥណទាន ការវាយតម្លៃហានិភ័យ និងការគ្រប់គ្រងប្រតិបត្តិការ ដោយរក្សានូវគោលការណ៍សំខាន់ៗនៃអាជីវកម្មរបស់ធនាគារ ARDB ប្រកបដោយចីរភាព។ តាមរយៈការពង្រឹងអភិបាលកិច្ច និងការរួមបញ្ចូលកត្តា ESG ធនាគារ ARDB ក៏មានគោលបំណងពង្រឹងអភិបាលកិច្ចប្រកបដោយតម្លាភាព បង្កើនទំនុកចិត្តដល់ភាគីពាក់ព័ន្ធ ពង្រីកលទ្ធភាពទទួលបានហិរញ្ញប្បទានបៃតង និងទទួលបានហិរញ្ញប្បទានពីដៃគូរអភិវឌ្ឍន៍អន្តរជាតិ។ ជាយុទ្ធសាស្ត្ររយៈពេលវែង ការវាស់វែងរបស់ធនាគារ ARDB ពីហានិភ័យបម្រែបម្រួលអាកាសធាតុ បរិស្ថាន សង្គម និងអភិបាលកិច្ច ធនាគារនឹងចូលរួមចំណែកក្នុងការបង្កើនភាពធន់លើសម្ភាធឥណទាន ស្ថិរភាពហិរញ្ញវត្ថុ ជាពិសេសនៅក្នុងវិស័យកសិកម្មដែលងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុរបស់កម្ពុជា ។

ជាជំហានបន្ទាប់ ធនាគារនឹងផ្តោតលើការបង្កើតគណៈកម្មការចីរភាពជាផ្លូវការ និងការអនុវត្តក្របខណ្ឌសមាហរណកម្ម ESG ដើម្បីបំប្លែងលទ្ធផលនៃការវាយតម្លៃនេះ ទៅជាសកម្មភាពជាក់ស្តែងដែលអាចវាស់វែងបាន ។ ការវាយតម្លៃគោលនយោបាយចីរភាពនេះ បានពង្រឹងសមត្ថភាពរបស់ ធនាគារ ARDB ក្នុងការបំពេញបេសកកម្មអភិវឌ្ឍន៍ជាតិ ព្រមទាំងធានាបាននូវភាពធន់ និងចីរភាពរបស់ស្ថាប័ន នៅក្នុងបរិបទហិរញ្ញវត្ថុសកលដែលកំពុងផ្លាស់ប្តូរយ៉ាងឆាប់រហ័ស។

ប្រព័ន្ធវដ្តករសាស្ត្របៃតងនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB Green Taxonomy)

ក្នុងឆ្នាំ ២០២៥, ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានបង្កើតប្រព័ន្ធវដ្តករសាស្ត្របៃតងក្នុងគោលបំណង នៃការប្រើប្រាស់ផ្ទៃក្នុង ក្នុងគោលដៅបង្កើនសំពៀតឥណទាន ដើម្បីទ្រទ្រង់ដល់ការអនុវត្តកសិកម្មប្រកបដោយចីរភាព, ការអភិវឌ្ឍជនបទ, និងការបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ស្របតាមចក្ខុវិស័យនៃផែនទីបង្ហាញផ្លូវរយៈពេល ១០ ឆ្នាំរបស់ ធនាគារ ARDB។ ប្រព័ន្ធវដ្តករសាស្ត្របៃតងរបស់ ធនាគារ ARDB ផ្តល់នូវនិយមន័យជាក់លាក់ក្នុងការកំណត់សកម្មភាព និងការអនុវត្តដែលនឹងត្រូវបានចាត់ថ្នាក់ជា "បៃតង (Green)" "អន្តរកាល (Transitional)" និង "ប្រពៃណី (Conventional)" ដែលស្របតាមស្តង់ដារជាតិ និងអន្តរជាតិ។

ប្រព័ន្ធវដ្តករសាស្ត្របៃតងរបស់ ធនាគារ ARDB បានរៀបចំដោយអនុលោមតាមគោលការណ៍ Green Bond Principle (GBP) របស់សមាគមទីផ្សារមូលធនអន្តរជាតិ ដែលមានធាតុសំខាន់ចំនួន ៤ រួមមាន÷ការប្រើប្រាស់មូលនិធិ ដំណើរការវាយតម្លៃ និងជ្រើសរើសគម្រោង ការគ្រប់គ្រងមូលនិធិ ការរៀបចំរបាយការណ៍។ បន្ថែមពីនេះ, នៅក្នុងដំណើរការរៀបចំ ក៏បានរួមបញ្ចូលធាតុសំខាន់ៗបន្ថែមទៀតដូចជា យន្តការនៃការអនុវត្តហិរញ្ញប្បទានដែលស្របតាមស្តង់ដារ GBP ព្រមទាំងដាក់ផ្សព្វផ្សាយជាសាធារណៈ ដែលអាចអនុញ្ញាតឱ្យភាគីពាក់ព័ន្ធពិនិត្យលើអនុលោមភាព ហើយអាចតាមដានលើការប្រើប្រាស់មូលនិធិ។

ប្រព័ន្ធវដ្តករសាស្ត្របៃតងរបស់ ធនាគារ ARDB មានយន្តការដែលគ្របដណ្តប់លើវិសាលភាព ២ សំខាន់ៗ រួមមាន÷

- ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ដោយផ្អែកលើសមាសធាតុគន្លឹះ ៣ រួមមាន÷ ការចៀសវាង, ការកាត់បន្ថយ, និងការដកចេញ។
- ការបង្កើនភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុដែលផ្តោតលើការបង្កើនសមត្ថភាពសម្របខ្លួន និងភាពធន់ ។

៤. សកម្មភាពសំខាន់ៗនៃគណៈគ្រប់គ្រង

វេទិកាថ្នាក់អន្តរជាតិ ៣៨-៤០
វេទិកាថ្នាក់ជាតិ ៤១-៤៣
ការចុះអនុស្សរណៈនៃការយោគយល់គ្នា..... ៤៤-៤៦

វេទិកាថ្នាក់អន្តរជាតិ

ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងជាប្រធានសមាគមគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍ក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក រួមទាំងជាតំណាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានអញ្ជើញចូលរួមកម្មវិធីថ្នាក់អន្តរជាតិសំខាន់ៗ រួមមាន÷

ទីក្រុងមូស្កាត ប្រទេសអូម៉ង់

- **កិច្ចប្រជុំក្រុមប្រឹក្សាភិបាល នៃសមាគមគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍ក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក (ADFIAP) លើកទី៩៨ និងកិច្ចប្រជុំប្រចាំឆ្នាំលើកទី៤៨ក្រោមប្រធានបទ÷ យុទ្ធសាស្ត្រជំរុញកំណើនខាងក្នុងនៃសហគ្រាស និងឥទ្ធិពលទៅលើការអភិវឌ្ឍ (Economic Gardening and Development Impact)÷** លើការជំរុញកំណើនសេដ្ឋកិច្ចមូលដ្ឋាន ការកសាងប្រព័ន្ធអេកូឡូស៊ីសម្រាប់សហគ្រិន ការផ្តល់ហិរញ្ញប្បទានលើគោលដៅអភិវឌ្ឍន៍ជាក់លាក់ និងការដើរតួជាស្ពានតភ្ជាប់គម្លាតហិរញ្ញប្បទាន ជាពិសេសហិរញ្ញប្បទានបៃតង និង ហិរញ្ញប្បទានប្រកបដោយចីរភាព។
- **កិច្ចពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍របស់ប្រទេសអូម៉ង់÷** ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងគាំទ្រការរៀបចំកិច្ចប្រជុំប្រចាំឆ្នាំ ADFIAP លើកទី៤៨ និងបានធ្វើទស្សនកិច្ចសិក្សាកសិដ្ឋាន ចញ្ចឹមត្រី ក្រោមការសម្របសម្រួលរបស់ធនាគារអភិវឌ្ឍន៍អូម៉ង់។
- **កិច្ចអញ្ជើញចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សាក្រោមប្រធានបទ“កត្តាមនុស្ស÷ ការកសាងសហគមសហគ្រិន”** ឯកឧត្តមបានលើកឡើងពិយុទ្ធសាស្ត្រសំខាន់ៗរបស់រាជរដ្ឋាភិបាលនិងរបស់ធនាគារ ARDB ក្នុងការកសាងប្រព័ន្ធអេកូឡូស៊ីសម្រាប់សហគ្រិននៅកម្ពុជាផងដែរ។

សកម្មភាពកិច្ចប្រជុំនៅទីក្រុងមូស្កាត ប្រទេសអូម៉ង់





តំបន់រដ្ឋបាលពិសេសម៉ាកាវ នៃសាធារណរដ្ឋប្រជាមានិតចិន÷

- **កិច្ចប្រជុំក្រុមប្រឹក្សាភិបាលសមាគម ADFIAP លើកទី៩៩÷** ដើម្បីពិភាក្សា អំពីអាទិភាពយុទ្ធសាស្ត្រ ចែករំលែកការយល់ដឹង និងពង្រឹងកិច្ចសហប្រតិបត្តិការសម្រាប់កំណើនប្រកបដោយចីរភាពនិងបរិយាបន្នព្រមទាំងពិនិត្យវឌ្ឍនភាពការងារនិងកំណត់ទិសដៅអនុវត្តបន្តរបស់សមាគម។

- **កិច្ចអញ្ជើញចូលរួមក្នុង កម្មវិធី"ADFIAP-AADFI Joint International CEO Forum 2025" ក្រោមប្រធានបទ÷** Resilient Future: Harnessing Sustainable Finance for Development in Asia and Africa ដើម្បីជំរុញហិរញ្ញវត្ថុប្រកបដោយចីរភាព និងពង្រឹងភាពជាដៃគូរវាងអាស៊ី និងអាហ្វ្រិក។

- **កិច្ចអញ្ជើញចូលរួមកម្មវិធីបើកជាផ្លូវការនៃ ពិព័រណ៌អន្តរជាតិចិន សម្រាប់ការវិនិយោគ និងពាណិជ្ជកម្ម លើកទី២៥ និងបានចូលរួមធ្វើជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាជាន់ខ្ពស់ (High-Level Plenary Discussion)នៃសន្និសីទស្តីពី "ការវិនិយោគសម្រាប់អនាគត"÷** កិច្ចពិភាក្សាផ្តោតទៅលើចក្ខុវិស័យចំពោះយុទ្ធសាស្ត្រស្វែងរកប្រភពទុនសម្រាប់អនាគត នៃការវិនិយោគសកល ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងថាមពលសម្រាប់អនាគត។

- **កិច្ចជំនួបពិភាក្សាជាមួយគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍អាហ្វ្រិក÷** ដើម្បីពិភាក្សាការងារជាមួយ Development Bank of Southern Africa, Land and Agricultural Bank of South Africa និង The association of African DFI (AADFI)ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការលើហិរញ្ញវត្ថុអភិវឌ្ឍន៍ ការកសាងសមត្ថភាព និងការផ្លាស់ប្តូរបទពិសោធន៍

សកម្មភាពកិច្ចប្រជុំនៅទីក្រុងម៉ាកាវ នៃប្រទេសចិន





រដ្ឋធានីខេបថោន សាធារណរដ្ឋអាហ្វ្រិកខាងត្បូង÷

- **កិច្ចនៃការអញ្ជើញចូលរួមសន្និបាតហិរញ្ញវត្ថុជាសកល (FiCS Summit)÷** ដើម្បីពិភាក្សាលើការអភិវឌ្ឍប្រព័ន្ធស្បៀងអាហារប្រកបដោយចីរភាព និងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងធនាគារអភិវឌ្ឍន៍នានា និងបានផ្តល់ធាតុចូលសំខាន់ៗស្តីពីតួនាទីរបស់ធនាគារអភិវឌ្ឍន៍ក្នុងការគាំទ្រហិរញ្ញប្បទានសម្រាប់ប្រព័ន្ធស្បៀងអាហារប្រកបដោយចីរភាព កៀរគរមូលធន និងកំណត់អាទិភាពរួមសម្រាប់ការអភិវឌ្ឍប្រកបដោយបរិយាបន្ន។ កម្មវិធីបើកសន្និបាតហិរញ្ញវត្ថុជាសកលប្រចាំឆ្នាំ ២០២៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ពីរដ្ឋមន្ត្រីហិរញ្ញវត្ថុសាធារណរដ្ឋអាហ្វ្រិកខាងត្បូង អគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ ទេសាភិបាលនៃធនាគារកណ្តាលសាធារណៈរដ្ឋបារាំង និងជាប្រធានធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ប្រធានទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ។
- **កិច្ចពិភាក្សាទ្វេភាគីជាមួយលោក Alvaro Lario ប្រធានអង្គការមូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍកសិកម្ម÷** លើការស្នើសុំធ្វើការពង្រីកទៅលើ គម្រោងហិរញ្ញប្បទានអាកាសធាតុកម្ពុជា (CCFF) ដែលជាគម្រោងគ្រាំទ្រដោយមូនិធិអាកាសធាតុបៃតង (GCF) ដើម្បីរួមចំណែកគាំទ្រដល់ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការអភិវឌ្ឍសេដ្ឋកិច្ចជាតិដែលបញ្ចេញកាបូនតិចលើវិស័យអាទិភាពរួមមាន ព្រៃឈើ និងការប្រើប្រាស់ដី, កសិកម្ម, ធនធានទឹក, ថាមពលកកើតឡើងវិញ, ប្រសិទ្ធភាពថាមពល និងការដឹកជញ្ជូន។
- **កិច្ចនៃការអញ្ជើញចូលរួមជាវាគ្មិន នឹងបានបង្ហាញពីតួនាទីរបស់ ធនាគារ ARDB÷** លើការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពដល់ខ្សែច្រវាក់ស្បៀងអាហារ ចាប់ពីកសិករខ្នាតតូច រហូតដល់សហគ្រាសកែច្នៃ និងវេចខ្ចប់ ដើម្បីលើកកម្ពស់សន្តិសុខស្បៀង អាហារូបត្ថម្ភ និងការអភិវឌ្ឍប្រកបដោយចីរភាព លើការជំរុញហិរញ្ញប្បទានបៃតង តាមរយៈការគាំទ្រប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យ ឡជីវឧស្ម័ន ប្រពន្ធអាកាផ្ងនិក និងកសិកម្មធន់នឹងអាកាសធាតុ ព្រមទាំងអនុវត្តគម្រោង CCFF ដែលគាំទ្រដោយ Green Climate Fund (GCF) ដើម្បីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចកាបូនទាប និងធន់នឹងការប្រែប្រួលអាកាសធាតុ។

រូបភាពនៅសកម្មភាពកិច្ចប្រជុំនៅរដ្ឋធានីខេបថោន សាធារណរដ្ឋអាហ្វ្រិកខាងត្បូង





វេទិកាថ្នាក់ជាតិ

ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងតំណាងធនាគារអភិវឌ្ឍន៍ជនទ និងកសិកម្ម បានចូលរួមកម្មវិធីសំខាន់ៗ រួមមាន÷

- កម្មវិធីបិទមហាសន្និបាតសហព័ន្ធស្រូវអង្ករកម្ពុជាអាណត្តិទី៤ និងកម្មវិធីបោះឆ្នោតជ្រើសរើសប្រធានសហព័ន្ធ ប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលអាណត្តិទី៥។
- បានអញ្ជើញចូលរួមជាកិត្តិយសនៅក្នុងវេទិកាជាតិគណនេយ្យ ឆ្នាំ២០២៥ នាមជ្ឈមណ្ឌលកោះពេជ្រ ក្នុងរាជធានីភ្នំពេញ។
- វេទិកាពាណិជ្ជកម្មស្វាយចន្ទី និងម្រេចកម្ពុជាក្រោមប្រធានបទ ការបើកច្រកទីផ្សារទៅកាន់សហភាពអ៊ឺរ៉ុប ២០២៥។
- កិច្ចប្រជុំក្រុមការងារស្តីពីការលើកកម្ពស់ការវិនិយោគនៅតំបន់ភូមិភាគឦសាន ដែលផ្តោតលើការពិនិត្យសំណើសុំអត្ថប្រយោជន៍ពិសេសការលើកលែងនិងការសម្រួលនីតិវិធីសម្រាប់គម្រោងវិនិយោគរបស់ក្រុមហ៊ុនចំនួន១១ក្រោមកម្មវិធីពិសេសសម្រាប់លើកកម្ពស់ការវិនិយោគនៅខេត្តភូមិភាគឦសានទាំងបួន ។
- បានអញ្ជើញចូលរួមជាអធិបតី និងជាវាគ្មិនកិត្តិយស ក្នុងកិច្ចពិភាក្សាក្រោមប្រធានបទ “Financing the Future: Connecting Capital to Impact on Climate” ក្នុងសន្និសីទមីក្រូហិរញ្ញវត្ថុប្រចាំឆ្នាំ២០២៥ ដែលប្រារព្ធធ្វើឡើងនៅខេត្តសៀមរាប។
- បានចូលរួមកិច្ចប្រជុំ ស្តីពីវិធានការ ដោះស្រាយស្តុកអង្ករលើស និងលើកកម្ពស់ភាពប្រកួតប្រជែងក្នុងទីផ្សារ។
- បានអញ្ជើញចុះត្រួតពិនិត្យវឌ្ឍនភាពគម្រោងសាងសង់រោងផ្ទះសំណាញ់ដាំដុះបន្លែ នៃសហគមន៍កសិកម្មទំនើបសាស៊ី (Sasy Modern Agricultural Community) នៅខេត្តសៀមរាប។
- សកម្មភាពចុះត្រួតពិនិត្យ តាមដាន ការប្រើប្រាស់ឥណទានលើ ការចិញ្ចឹម ដាំដុះ និងអាជីវកម្មកែរច្នៃផលិតផលកសិកម្មដែលជាអតិថិជននៅតាមបណ្តាលខេត្ត÷

រូបភាពសកម្មភាពកម្មវិធីបិទមហាសន្និបាតសហព័ន្ធស្រូវអង្ករកម្ពុជាអាណត្តិទី៤





រូបភាពសកម្មភាពកម្មវិធីវេទិកាជាតិគណនេយ្យ





រូបភាពសកម្មភាពកម្មវិធីពាណិជ្ជកម្មស្វាយចន្ទី និងម្រេចកម្ពុជា





រូបភាពសកម្មភាពប្រជុំដោះស្រាយស្តុកអង្ករលើស និងលើកកម្ពស់ភាពប្រកួតប្រជែងក្នុងទីផ្សារ





រូបភាពសកម្មភាពចុះត្រួតពិនិត្យវឌ្ឍនភាពគម្រោងសាងសង់ផ្ទះសំណាញ់





រូបភាពសកម្មភាពចុះត្រួតពិនិត្យ តាមដាន ការប្រើប្រាស់ឥណទានលើ ការចិញ្ចឹម ដាំដុះ និងអាជីវកម្មកែរច្នៃផលិតផលកសិកម្ម









ការចុះអនុស្សរណៈនៃការយោគយល់ (MoU)

ពិធីចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់គ្នា រវាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ជាមួយសមាគមអតីតយុទ្ធជន និងវត្តជនកម្ពុជា និងសមាគមបណ្តាញកសិករតេជោ



ពិធីចុះហត្ថលេខាន ប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិសង្គហបណ្ឌិត គង់ គីម** ទេសរដ្ឋមន្ត្រី អនុប្រធាន និងជាអគ្គលេខាធិការសមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា **ឯកឧត្តមបណ្ឌិត កៅ ថាច** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និង **លោក ជេត តិរម្យ** អនុប្រធាននៃសមាគមបណ្តាញកសិករតេជោ និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ សមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា ថ្នាក់ដឹកនាំធនាគារ ARDB និងតំណាងសមាគមបណ្តាញកសិករតេជោ សរុបជាង ៥០នាក់។

អនុស្សរណៈនៃការយោគយល់គ្នានេះមានគោលបំណងបង្កើតកិច្ចសហប្រតិបត្តិការ ផ្លាស់ប្តូរព័ត៌មាន និងចែករំលែកបទពិសោធន៍កសិកម្ម ផ្តល់ហិរញ្ញប្បទានគាំទ្រលើកតម្កើងសេដ្ឋកិច្ចគ្រួសារអតីតយុទ្ធជន និងនិវត្តជនកម្ពុជា និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ និងផ្តល់ការគាំទ្រជំនួយបច្ចេកទេសកសិកម្ម និងការតភ្ជាប់ទីផ្សារលក់ផលិតផលកសិកម្ម ។

អនុស្សរណៈនៃការយោគយល់ រវាងធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) និងសភាពាណិជ្ជកម្មអន្តរជាតិកម្ពុជា-សមាគមក្រុមប្រឹក្សាកម្ពុជា-ចិន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងនាយកដ្ឋានអភិវឌ្ឍន៍យុវជន

ពិធីចុះហត្ថលេខានេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត កៅ ថាច** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និង **លោក Johnny Mo** នាយកដ្ឋានអភិវឌ្ឍន៍យុវជន។ ព្រឹត្តិការណ៍នេះមានការចូលរួមពីថ្នាក់ដឹកនាំរបស់ធនាគារ ARDB បុគ្គលិកពាក់ព័ន្ធ និងតំណាងសមាគមក្រុមប្រឹក្សាកម្ពុជាចិន សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច ដោយមានអ្នកចូលរួមសរុបចំនួន ១០០នាក់។ អនុស្សរណៈនៃការយោគយល់នេះមានគោលបំណងជំរុញការអភិវឌ្ឍវិស័យកសិកម្ម និងគាំទ្រកសិករកម្ពុជា តាមរយៈវេទិកាមេខាការអប់រំ និងគម្រោងសហប្រតិបត្តិការផ្សេងៗ។



GRI 2-6: សកម្មភាពខ្សែសង្វាក់ផលិតកម្ម និងទំនាក់ទំនងអាជីវកម្មផ្សេងៗ
GRI 201-1: ផលវិជ្ជមានទៅលើសេដ្ឋកិច្ចដោយផ្ទាល់ និងផលជះ

ការចុះអនុស្សរណៈយោគយល់គ្នារវាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) **និងធនាគារជាតិអភិវឌ្ឍន៍ជនបទ និងកសិកម្ម ប្រទេសឥណ្ឌា** (National Bank For Agriculture and Rural Development - NABARD)



ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានចូលរួមជាអធិបតីក្នុងពិធីចុះអនុស្សរណៈយោគយល់គ្នារវាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងធនាគារជាតិអភិវឌ្ឍន៍ជនបទ និងកសិកម្មប្រទេសឥណ្ឌា ដែលជាធនាគារអភិវឌ្ឍន៍ឥណ្ឌាផ្តោតលើការផ្តល់ហិរញ្ញប្បទានអភិវឌ្ឍន៍នៅតំបន់ជនបទ។

អនុស្សរណៈយោគយល់នេះ មានគោលបំណងពង្រីកកិច្ចសហប្រតិបត្តិការរវាងធនាគារអភិវឌ្ឍន៍នៃប្រទេសកម្ពុជា និងធនាគារអភិវឌ្ឍន៍នៃប្រទេសឥណ្ឌា ក្រោមទម្រង់ការបង្កើតជាថ្នាលសម្រាប់ការចែករំលែកឧត្តមានុវត្តន៍លើនវានុវត្តន៍ហិរញ្ញប្បទានកសិកម្ម ពិសេសការធ្វើឌីជីថលូបនីយកម្មទៅក្នុងការផ្តល់ហិរញ្ញប្បទានខ្សែច្រវាក់ផលិតកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម។ លើសពីនេះទៅទៀត, អនុស្សរណៈយោគយល់នេះ នឹងសហការលើការជំរុញសកម្មភាពនៃសមាគមគ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍តំបន់អាស៊ី និងប៉ាស៊ីហ្វិក (ADFIAP) សំដៅចូលរួមការអភិវឌ្ឍតំបន់ប្រកបដោយចីរភាព។

ពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នារវាងក្រសួងបរិស្ថាន និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន និង **ឯកឧត្តមបណ្ឌិត កៅ ថាច** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានចុះអនុស្សរណៈយោគយល់គ្នាក្នុងគោលបំណងដើម្បីសហការគ្នាគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុដោយផ្អែកលើសកម្មភាព និងការបង្កើនភាពធន់នឹងការប្រែប្រួលអាកាសធាតុតាមរយៈការផ្តល់ហិរញ្ញប្បទានបៃតង។



ការចុះអនុស្សរណៈនៃការយោគយល់ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងសាជីវកម្មធានាឥណទានកម្ពុជា (CGCC)





ឯកឧត្តម ចាន់ សីហា អគ្គនាយករងធនាគារ ARDB និងសហការី បានចូលរួមពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងសាជីវកម្មធានាឥណទានកម្ពុជា។

ពិធីនេះបានប្រព្រឹត្តទៅក្រោមអធិបតីភាព **ឯកឧត្តម ឌិត ឆិណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានការចូលរួមពីអនុរដ្ឋលេខាធិការ អគ្គនាយកសាជីវកម្មឥណទានកម្ពុជា ថ្នាក់ដឹកនាំធនាគារពាណិជ្ជបរទេសនៅកម្ពុជា និងថ្នាក់ដឹកនាំពាក់ព័ន្ធជាច្រើនទៀត ដែលបានប្រព្រឹត្តទៅនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អនុស្សរណៈនៃការយោគយល់ រវាងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងអង្គការ Catalyst"s Organization

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងអង្គការ Catalyst's Organization បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ស្តីពី "កិច្ចសហប្រតិបត្តិការក្នុងកម្មវិធី ជំរុញលេ្បឿន ដើម្បីលើកកម្ពស់សមត្ថភាពស្ត្រី តាមរយៈការបណ្តុះបណ្តាលជំនាញផលិតមាតិកា។



GRI 2-6: សកម្មភាពខ្សែសង្វាក់ផលិតកម្ម និងទំនាក់ទំនងអាជីវកម្មផ្សេងៗ
GRI 201-1: ផលវិជ្ជមានទៅលើសេដ្ឋកិច្ចដោយផ្ទាល់ និងផលជះ

៥. គោលនយោបាយចីរភាពរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

គោលនយោបាយប្រកបដោយចីរភាព..... ៤៧
គោលនយោបាយគាំពារសង្គម និងបរិស្ថាន ៤៨
គោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពប្រទេសកម្ពុជា ៤៩
ឥណទានបៃតងរបស់ធនាគារARDB និងផលជះផ្នែកសេដ្ឋកិច្ច-សង្គម..... ៥០-៥១
ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មគាំទ្រ ៥២-៥៣
ហិរញ្ញប្បទានរាជរដ្ឋាភិបាល ៥៤
វត្តមានរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម នៅលើទីផ្សារ..... ៥៥

៥. គោលនយោបាយចីរភាពរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ស្របតាមចក្ខុវិស័យថ្មីក្នុងការប្រែក្លាយជា គ្រឹះស្ថានឈានមុខក្នុងការផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាព, ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បាននឹងកំពុងប្តេជ្ញាចិត្តនៅក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងដំណើរការឆ្ពោះទៅរកការដាក់ចេញនូវគោលការណ៍ចីរភាព តាមរយៈការដាក់បញ្ចូលគោលនយោបាយចីរភាពទៅក្នុងយុទ្ធសាស្ត្រអាជីវកម្ម, ផលិតផល និងសេវាកម្ម, ការគ្រប់គ្រងមូលធនមនុស្ស, និងប្រតិបត្តិការទាំងមូលរបស់ធនាគារ។

ដោយបានមើលឃើញពីតួនាទីដ៏សំខាន់របស់គ្រឹះស្ថានហិរញ្ញវត្ថុអភិវឌ្ឍន៍ក្នុងការរួមចំណែកនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ, ធនាគារARDB បាននឹងកំពុងបោះជំហានឆ្ពោះទៅមុខ ស្របទៅតាមចក្ខុវិស័យក្នុងការប្រែក្លាយជាធនាគារអភិវឌ្ឍន៍គំរូសម្រាប់ធនាគារផ្សេងៗទៀតនៅក្នុងប្រទេស ដើម្បីដឹកនាំកម្ពុជាឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងប្រកបដោយចីរភាពជាមួយនឹងចក្ខុវិស័យ និងបេសកកម្មថ្មីរបស់ខ្លួន។

ដើម្បីជំរុញដល់ការបោះជំហានឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចីរភាពត្រឹមឆ្នាំ២០៥០, ធនាគារARDB ប្តេជ្ញាចិត្តក្នុងការអនុវត្តគោលដៅ និងវិធានដូចខាងក្រោម÷

- រៀបចំយុទ្ធសាស្ត្រអាជីវកម្មឱ្យស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិលើកិច្ចព្រមព្រៀងទីក្រុងប៉ារីសដែលស្ថិតក្រោមអនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC), ផែនការជាតិរួមចំណែកថ្នាក់ជាតិ (NDCs), គោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់កម្ពុជា កិច្ចព្រមព្រៀង ក្របខ័ណ្ឌជាតិ និងអន្តរជាតិនានា។
- អភិវឌ្ឍន៍ និងអនុវត្តគោលនយោបាយផ្ទៃក្នុងដែលពាក់ព័ន្ធនានា លើប្រតិបត្តិការរបស់ធនាគារដើម្បីធានាបាននូវការអនុវត្តប្រកបដោយចីរភាព (គោលការណ៍ប្រតិបត្តិតាមប្រកបដោយចីរភាព)។
- លើកកម្ពស់ផលិតផល និងសេវាកម្មហិរញ្ញវត្ថុបៃតង និងប្រកបដោយចីរភាព ជាពិសេសនៅក្នុងវិស័យកសិកម្ម វិស័យជនបទ និងវិស័យបៃតងនៅក្នុងប្រទេសកម្ពុជា។
- លើកកម្ពស់សមភាព និងបរិយាប័ន្នសង្គម ដោយផ្តោតសំខាន់លើការលើកកម្ពស់ស្ត្រី និងក្រុមដែលងាយរងគ្រោះ។

ការប្តេជ្ញាចិត្តរបស់ ធនាគារ ARDB ឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងប្រកបដោយចីរភាព ត្រូវបានបង្ហាញតាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការរួមចំណែកដោះស្រាយបញ្ហាសំខាន់ៗនានាស្តីពី ការកើនឡើងកម្តៅផែនដី និងការប្រែប្រួលអាកាសធាតុ និងការក្លាយខ្លួនទៅជាគ្រឹះស្ថានផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាព។ ធនាគារ ARDB ក៏បានប្រកាន់ខ្ជាប់ជាមួយនឹងការប្តេជ្ញាចិត្តក្នុងការរួមចំណែកឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចបៃតង និងប្រកបដោយចីរភាព តាមរយៈការគាំទ្រយ៉ាងមុតមុៈដល់វិស័យកសិកម្ម និងការអភិវឌ្ឍជនបទនៅក្នុងប្រទេសកម្ពុជាផងដែរ។

គោលនយោបាយគាំពារសង្គម និងបរិស្ថានរបស់ធនាគារ ARDB

ក្នុងនាមជាធនាគារគោលនយោបាយដែលផ្តោតសំខាន់លើការអភិវឌ្ឍ ធនាគារ ARDB ប្តេជ្ញាផ្តល់នូវសេវាកម្មធនាគារ ប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះបរិស្ថាន និងសង្គម ព្រមទាំងគោរពដល់ប្រជាជន និងវប្បធម៌កម្ពុជា។ ក្នុងន័យនេះ ធនាគារ ARDB បានពិនិត្យឃើញអំពីទំនួលខុសត្រូវរបស់បុគ្គលិកគ្រប់រូបក្នុងកិច្ចការងារគាំពារសង្គម និងបរិស្ថាន ។ ដើម្បីផ្តល់អាទិភាពដល់កិច្ចការនេះ ធនាគារ ARDB បានបង្កើតគណៈកម្មាធិការសង្គម និងបរិស្ថាន ដែលស្ថិតក្រោមនាយកដ្ឋានគ្រប់គ្រងហានិភ័យដើម្បីធានាថាការសម្រេចចិត្តផ្តល់កម្ចីនានាមានភាពត្រឹមត្រូវនិងស្របទៅតាមគោលនយោបាយសង្គមនិងបរិស្ថានរបស់ធនាគារ ព្រមទាំងអាចគ្រប់គ្រងអំពីផលប៉ះពាល់ពីធនាគារផ្ទាល់ និងអតិថិជនរបស់ខ្លួន លើសង្គម និងបរិស្ថាន។

ជាមួយគ្នានេះ ក្នុងខែកុម្ភៈ ឆ្នាំ២០១៧, ធនាគារ ARDB បានប្រកាសដាក់ឱ្យប្រើប្រាស់នូវគោលនយោបាយគាំពារសង្គម និងបរិស្ថានដើម្បីផ្តល់ការណែនាំដល់បុគ្គលិកពាក់ព័ន្ធក្នុងការកំណត់អត្តសញ្ញាណ, វាយតម្លៃ, និងគ្រប់គ្រងហានិភ័យបរិស្ថាន និងសង្គមដែលអាចកើតមាន។



E – Environment

ហានិភ័យបរិស្ថានត្រូវបានគិតគូរ និងវាយតម្លៃសម្រាប់គ្រប់ប្រភេទឥណទានទាំងអស់ នៅក្នុងដំណើរការត្រួតពិនិត្យផ្នែកសង្គម និងបរិស្ថាន។ ការវាយតម្លៃនេះ ធ្វើឡើងតាមរយៈការត្រួតពិនិត្យលិតលួន់ និងវាយតម្លៃពីផលវិបាក ដែលអាចកើតមានក្នុងពេលអភិវឌ្ឍគម្រោង រួចធ្វើការចាត់ថ្នាក់កម្រិតហានិភ័យទៅតាមគម្រោងនីមួយៗ។

S – Social

ធនាគារ ARDB ប្តេជ្ញាចិត្តលើកកម្ពស់នូវវប្បធម៌ការងារ ប្រកបដោយសុចរិតភាព និងយុត្តិធម៌សម្រាប់គ្រប់សកម្មភាពទាំងអស់របស់ធនាគារដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ ព្រមទាំងរក្សានូវស្តង់ដាខ្ពស់បំផុត នៃអភិបាលកិច្ចសាជីវកម្ម។

G – Governance

ហានិភ័យសង្គមត្រូវបានគិតគូរ និងវាយតម្លៃសម្រាប់ គ្រប់ប្រភេទឥណទានទាំងអស់។ ហានិភ័យសង្គមសំដៅលើហានិភ័យដែលផ្តល់ប៉ះពាល់ ដល់ជីវភាពរស់នៅ និងសុខុមាលភាពរបស់សហគមន៍ ដែលមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោលជាមួយប្រតិបត្តិការរបស់ធនាគារ ARDB ឬគម្រោងរបស់អតិថិជននៃធនាគារ ARDB។

GRI 201-2: ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងហានិភ័យ និងឱកាសផ្សេងទៀតដោយសារការប្រែប្រួលអាកាសធាតុ
GRI 2-23: ការបេតជ្ញាទៅគោលការណ៍

គោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពប្រទេសកម្ពុជា

ធនាគារ ARDB ប្តេជ្ញាប្រកាន់ខ្ជាប់នូវគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា ដែលដាក់ឱ្យប្រើប្រាស់ជាផ្លូវការក្នុងឆ្នាំ២០១៩ ដោយសមាគមធនាគារនៅកម្ពុជា(ABC) ក្រោមការគាំទ្រពីធនាគារជាតិនៃកម្ពុជា(NBC) ដើម្បីអភិវឌ្ឍ និងធ្វើសមាហរណកម្មយុទ្ធសាស្ត្រផ្តល់ហិរញ្ញវត្ថុប្រកបដោយចីរភាពរបស់បណ្តាធនាគារ។ ធនាគារ ARDB បានចូលរួមចំណែកដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ ក៏ដូចជាកិច្ចព្រមព្រៀងទីក្រុងប៉ារីស និងការចូលរួមចំណែករបស់ជាតិ (NDCs) ដើម្បីអនុវត្តអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

បន្ថែមពីនេះ, ធនាគារ ARDB បានផ្តល់ការបណ្តុះបណ្តាលផ្សេងៗ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់ភាគីពាក់ព័ន្ធអំពីបញ្ហាបរិស្ថាន, សង្គម, និងអភិបាលកិច្ច (ESG)។ គំនិតផ្តួចផ្តើមទាំងនេះធ្វើឡើងក្នុងគោលបំណងគ្រប់គ្រងហានិភ័យ, កសាងសមត្ថភាព, ធ្វើបសិដ្ធកម្មប្រព័ន្ធគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) របស់ធនាគារ, ផ្តល់ផលិតផលហិរញ្ញវត្ថុប្រកបដោយចីរភាព, និងប្រើប្រាស់ធនធានដែលមានស្រាប់ ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ព្រមទាំងស្របទៅតាមឧត្តមានុវត្តន៍អន្តរជាតិ និងស្តង់ដាពាក់ព័ន្ធ។

ក្រៅពីនេះ, ធនាគារ ARDB បានធ្វើបរិវត្តកម្មទៅរកម៉ូដែលស្ម័គ្រចិត្តក្នុងការអនុម័តគោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា។ គោលការណ៍នេះរួមបញ្ចូលនូវគោលការណ៍ណែនាំចំនួន ៩ ដែលត្រូវបានរចនាឡើងដើម្បីលើកកម្ពស់ការប្រើប្រាស់ហិរញ្ញវត្ថុប្រកបដោយចីរភាពនៅក្នុងប្រទេសកម្ពុជានិងជួយដល់បណ្តាធនាគារក្នុងការរួមបញ្ចូលកត្តាបរិស្ថានទៅក្នុងដំណើរការផ្តល់កម្ចីរបស់ខ្លួន។

គោលការណ៍ហិរញ្ញវត្ថុប្រកបដោយចីរភាពកម្ពុជា

ការការពារបរិស្ថាន, ប្រជាជន, និងបេតិកភណ្ឌវប្បធម៌

គោលការណ៍ទី១÷ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យបរិស្ថាន

គោលការណ៍ទី២÷ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យសង្គម

គោលការណ៍ទី៣÷ ការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យ សំដៅការពារបេតិកភណ្ឌវប្បធម៌

ការផ្តល់ហិរញ្ញប្បទានសម្រាប់អនាគតប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា

គោលការណ៍ទី៤÷ ការលើកកម្ពស់អក្ខរកម្មហិរញ្ញវត្ថុ និងកិច្ចការពារអតិថិជន

គោលការណ៍ទី៥÷ ការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន

គោលការណ៍ទី៦÷ ការផ្តល់ហិរញ្ញប្បទានដល់គម្រោងនវានុវត្តន៍ដោយប្រើប្រាស់ហិរញ្ញប្បទានបៃតង

ការជំរុញការផ្លាស់ប្តូរនៅក្នុងវិស័យហិរញ្ញវត្ថុ

គោលការណ៍ទី៧÷ ការកសាងសមត្ថភាព និងលើកកម្ពស់ការយល់ដឹង

គោលការណ៍ទី៨÷ ការកាត់បន្ថយកម្មវិបាកផ្នែកបរិស្ថាន

គោលការណ៍ទី៩÷ ការរាយការណ៍ជាប្រចាំអំពីវឌ្ឍនភាពនៃរបាយការណ៍ចីរភាព

សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

Cambodian Sustainable Finance

CAMBODIAN SUSTAINABLE FINANCE PRINCIPLE



ឥណទានបៃតងរបស់ធនាគារ ARDB និងផលប៉ះផ្លែកសេដ្ឋកិច្ចសង្គម

បន្ទាប់ពីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមអស់រយៈពេល ២៦ឆ្នាំ តាមរយៈការផ្តល់ឥណទានខ្នាតតូចដល់ខ្សែច្រវាក់តម្លៃកសិកម្ម, ធនាគារ ARDB បានកែសម្រួលចក្ខុវិស័យថ្មីក្នុងការប្រែក្លាយជាគ្រឹះស្ថានផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាពឈានមុខគេ ដោយផ្តោតលើការអភិវឌ្ឍវិស័យកសិកម្ម វិស័យជនបទ និងវិស័យបៃតង។ ការផ្តល់ឥណទានបៃតង បានបង្ហាញអំពីការគាំទ្រដល់អាជីវកម្មបៃតងនៅក្នុងខ្សែច្រវាក់តម្លៃកសិកម្មចាប់ពីដំណាក់កាលផលិតដំបូងរហូតដល់ដំណាក់កាលចែកចាយ។ សកម្មភាពអាជីវកម្មទាំងនេះមានគោលបំណងកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន ការបង្កើនភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ ការរួមបញ្ចូលនូវបច្ចេកវិទ្យាថ្មីៗ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ។

ធនាគារ ARDB បានបង្កើតគោលការណ៍ឥណទានបៃតង ដែលជាឧបករណ៍ហិរញ្ញវត្ថុ ដើម្បីគាំទ្រគម្រោងបៃតងនៅក្នុងខ្សែច្រវាក់តម្លៃកសិកម្ម (AVC) ដោយផ្តោតលើអាជីវកម្មដែលដោះស្រាយបញ្ហាសំខាន់ៗដូចខាងក្រោម÷

- ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់
- ការបង្កើនភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ
- ការចាប់យកបច្ចេកវិទ្យាថ្មី និង/ឬប្រើប្រាស់បច្ចេកទេសប្រកបដោយចីរភាព និង
- អត្ថប្រយោជន៍រួម÷ បរិស្ថាន, យេនឌ័រ, សង្គម, ចីរភាពនៃសេដ្ឋកិច្ច, និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDGs) ផ្សេងទៀត។

ផលវិជ្ជមានផ្នែកបរិស្ថាន

ការរួមបញ្ចូលគោលដៅ SDGs÷ ឥណទានបៃតងរបស់ ធនាគារ ARDB តាមចូលរួមក្នុងគោលដៅ SDG ១៣ (សកម្មភាពអាកាសធាតុ) ដោយផ្តល់ហិរញ្ញប្បទានដល់កសិផុរកិច្ចដែលផ្តល់អាទិភាពដល់ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់, ការបង្កើនភាពស៊ាំទៅនឹងការប្រែប្រួលអាកាសធាតុ, និងការចាប់យកបច្ចេកវិទ្យា និង/ឬបច្ចេកទេសប្រកបដោយចីរភាព។

អន្តរកាលឆ្ពោះទៅកសិកម្មបៃតង÷ លើកទឹកចិត្តកសិករឱ្យផ្លាស់ប្តូរទម្រង់អាជីវកម្ម ពីការធ្វើកសិកម្មបែបប្រពៃណី ទៅជាការធ្វើកសិកម្មប្រកបដោយចីរភាព តាមរយៈការផ្តល់ឥណទានបៃតងជាមួយនឹងអត្រាការប្រាក់ទាប និងសេវាកម្មបន្ថែមផ្សេងទៀត (ឧ. ការប្រឹក្សាយោបល់ផ្នែកបច្ចេកទេសក្នុងការធ្វើកសិកម្ម, ព័ត៌មានទាក់ទងនឹងទីផ្សារ, និងអក្ខរកម្មផ្នែកហិរញ្ញវត្ថុ និងឌីជីថល)។ ក្នុងនោះ រួមមាន បន្លែសុវត្ថិភាព, ផ្ទះសំណាញ់, ប្រព័ន្ធធារាសាស្ត្រ, ប្រព័ន្ធសូឡា, ការធ្វើកសិកម្មលើទឹក, និងសម្ភារៈបរិក្ខារក្រោយច្រូតកាត់ដែលធន់នឹងអាកាសធាតុនៅក្នុងវិស័យស្រូវអង្ករ។

ការកាត់បន្ថយការបញ្ចេញកាបូន÷ តាមរយៈការផ្តល់ហិរញ្ញប្បទានដល់ការធ្វើកសិកម្មបៃតង ធនាគារARDB បានរួមចំណែកដល់ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ផលវិជ្ជមានផ្នែកសេដ្ឋកិច្ច

ការរួមចំណែកតាមវិស័យ÷ គិតត្រឹមខែធ្នូ ឆ្នាំ២០២៥, ធនាគារ ARDB បានផ្តល់ហិរញ្ញប្បទានដល់កសិផុរកិច្ចបៃតងចំនួន ២៨០ ដែលស្មើនឹង ៤១.៨% នៃសំពៀតឥណទានសរុប ដែលរួមមានវិស័យស្រូវ បន្លែ និងផ្លែឈើ។ គំនិតផ្តួចផ្តើមនេះបានគូសបញ្ជាក់ពីតួនាទីរបស់ធនាគារក្នុងការធ្វើបរិវត្តកម្មសេដ្ឋកិច្ចកសិកម្មរបស់កម្ពុជា។

ការលើកម្ពស់ជីវភាពរស់នៅតាមទីជនបទ÷ គំនិតផ្តួចផ្តើមឥណទានបៃតងផ្តល់លទ្ធភាពឱ្យកសិករខ្នាតតូច និងកសិផុរកិច្ចបៃតងផ្លាស់ប្តូរទម្រង់អាជីវកម្មទៅរកទម្រង់អាជីវកម្មប្រកបដោយចីរភាព ដែលអាចកាត់បន្ថយហានិភ័យរួបរវន្ត និងអន្តរកាល ព្រមទាំងធានាបាននូវចំណូលរយៈពេលវែងដែលមានស្ថិរភាពផងដែរ។ មិនតែប៉ុណ្ណោះ, ការផ្លាស់ប្តូរទម្រង់អាជីវកម្មបានជំរុញឱ្យអាជីវកម្មមាននិរន្តរភាព និងកែលម្អស្តង់ដាជីវភាពរស់នៅរបស់សហគមន៍ជនបទ។

ការអភិវឌ្ឍសហគមន៍÷ តាមរយៈការពង្រឹងសេដ្ឋកិច្ចមូលដ្ឋាននៅតាមទីជនបទកម្មវិធីឥណទានបៃតងបានបង្កើនការងារនិងភាពធន់នឹងសេដ្ឋកិច្ច ជាពិសេសក្នុងវិស័យកសិកម្ម។

ផលវិជ្ជមានផ្នែកសង្គម

ការលើកម្ពស់សមភាពយេនឌ័រ÷ ធនាគារARDB បានគិតគូរអំពីការលើកកម្ពស់យេនឌ័រ ដោយមាន ២៧% នៃសំពៀតឥណទានបៃតងសរុប ត្រូវបានផ្តល់ទៅឱ្យកសិផុរកិច្ចដែលដឹកនាំដោយស្ត្រី។ ការពង្រឹងអំណាចនេះលើកកម្ពស់តួនាទីរបស់ស្ត្រីក្នុងវិស័យកសិកម្ម និងលើកកម្ពស់សមភាពយេនឌ័រ។

សមាហរណកម្មសន្តិសុខស្បៀង÷ វិស័យស្រូវអង្ករបានរួមចំណែកច្រើនស្មើនឹង ២១%នៃសំពៀតឥណទានបៃតងសរុប។ ការណ៍នេះបានបង្ហាញពីតួនាទីប្រកបដោយបុរេសកម្មរបស់ធនាគារARDB ក្នុងការជំរុញហិរញ្ញប្បទានបៃតង ដើម្បីធានាបាននូវសន្តិសុខស្បៀងរយៈពេលវែង និងការពារបរិស្ថាន។

ការជំរុញការអនុវត្តគោលនយោបាយ÷ តាមរយៈគំនិតផ្តួចផ្តើមហិរញ្ញវត្ថុបៃតង ធនាគារ ARDB អាចចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍគោលនយោបាយហិរញ្ញវត្ថុប្រកបដោយចីរភាព និងក្របខ័ណ្ឌបទប្បញ្ញត្តិ ដែលនឹងជះឥទ្ធិពល និងធ្វើជាម៉ូដែលសម្រាប់វិស័យហិរញ្ញវត្ថុ

ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មគាំទ្រ

ឃ្លាំង និងឡសម្ងួត

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រ និងលើកកម្ពស់វិស័យស្រូវអង្ករនៅកម្ពុជា ដោយបានផ្តល់ធនធានហិរញ្ញវត្ថុដើម្បីគាំទ្រដល់វិស័យនេះ។

កម្មវិធីឥណទានពិសេសរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍ និងប្រតិបត្តិការឃ្លាំង និងឡសម្ងួតស្រូវ ពោត ឬកសិផលផ្សេងទៀត (មូលនិធិពិសេស) គឺសំដៅលើអតិថិជនគោលដៅ ដូចជា មជ្ឈមណ្ឌលប្រមូលស្រូវ, រោងម៉ាស៊ីនកិនស្រូវ, ឃ្លាំងស្តុកស្រូវ, និងអ្នកប្រមូលទិញស្រូវ, ព្រមទាំងម្ចាស់ឃ្លាំង និងឡសម្ងួត ឬស៊ីឡូកសិកម្មផ្សេងទៀតដែលអាចប្រមូលទិញស្រូវក្រអូប និងផលិតផលកសិកម្មផ្សេងៗទៀត។

ការផ្តល់ឥណទានតម្រូវឱ្យឃ្លាំងស្តុកមានសមត្ថភាពផ្ទុកស្រូវបានយ៉ាងតិច ៣ ០០០តោន ហើយឡសម្ងួតមានសមត្ថភាពសម្ងួតស្រូវបានយ៉ាងតិច ៥០តោន/ថ្ងៃ។ លក្ខណៈបច្ចេកទេសបានចែងថា ឃ្លាំងស្តុកត្រូវស្ថិតនៅដាច់ដោយឡែកពីរោងម៉ាស៊ីនកិនស្រូវ និងបំពាក់ដោយឧបករណ៍បច្ចេកទេសគ្រប់គ្រាន់ ដូចជា ម៉ាស៊ីនលើកដាក់ទំនិញ និងសាស័រ ជាដើម។ បន្ថែមពីនេះ, ឃ្លាំងស្តុកទាំងនោះត្រូវមានប្រព័ន្ធការពារអគ្គីភ័យ និងការធានារ៉ាប់រងអគ្គីភ័យផងដែរ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ កម្មវិធីឥណទានពិសេសរបស់រាជរដ្ឋាភិបាល ដែលគាំទ្រយន្តការអភិវឌ្ឍ និងប្រតិបត្តិការឃ្លាំងស្តុកស្រូវ និងឡសម្ងួត ក៏ដូចជាលទ្ធកម្មស្រូវ ពោត ឬផលិតផលកសិកម្មផ្សេងទៀត (មូលនិធិពិសេស) បានរួមចំណែកប្រមាណ ៣.៣៣% នៃចំនួនឥណទានសរុប។



សមត្ថភាពស្តុកទុក និងកិនស្រូវ

គិតត្រឹមឆ្នាំ២០២៥ វិស័យស្រូវអង្ករកម្ពុជាមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ទៅលើហេដ្ឋារចនាសម្ព័ន្ធក្រោយប្រមូលផល ដើម្បីគាំទ្រសន្តិសុខស្បៀងក្នុងស្រុក និងពង្រឹងសមត្ថភាពប្រកួតប្រជែងក្នុងការនាំចេញ។ យោងតាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្ពុជាមានរោងម៉ាស៊ីនកិនស្រូវខ្នាតមធ្យម និងធំប្រមាណ ២៤០ រោងម៉ាស៊ីន ក្នុងនោះប្រមាណ ៨០ រោងម៉ាស៊ីន មានសមត្ថភាពនាំចេញតាមស្តង់ដារអន្តរជាតិ។រោងម៉ាស៊ីនស្រូវទាំងនេះមានសមត្ថភាពកិនស្រូវប្រមាណ១.២០០តោនក្នុងមួយម៉ោងសម្ងួតស្រូវលើសពី ៥០,០០០ តោនក្នុងមួយថ្ងៃ និងស្តុកទុកស្រូវប្រមាណ ២ លានតោនក្នុងមួយរដូវប្រមូលផល។ ជារួមរោង ម៉ាស៊ីនទាំងនេះមានសមត្ថភាពកែច្នៃស្រូវលើសពី ៤ លានតោនក្នុងមួយឆ្នាំដែលបានរួមចំណែកពង្រឹងខ្សែច្រវាក់តម្លៃកសិកម្មរបស់កម្ពុជា និងគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

សូចនាករ	សមត្ថភាព
សមត្ថភាពកិនស្រូវ	ប្រហែល ១,២០០ តោន/ម៉ោង
សមត្ថភាពសម្ងួតស្រូវ	លើសពី ៥០,០០០ តោន/ថ្ងៃ
សមត្ថភាពស្តុកទុកស្រូវ	ប្រហែល ២ លានតោន/រដូវប្រមូលផល
សមត្ថភាពកិន និងកែច្នៃសរុប	លើសពី ៤ លានតោន/ឆ្នាំ
រោងម៉ាស៊ីនកិនស្រូវខ្នាតមធ្យម និងធំ	ប្រហែល ២៤០ រោងម៉ាស៊ីន
រោងម៉ាស៊ីនដែលអាចនាំចេញតាមស្តង់ដារអន្តរជាតិ	ប្រហែល ៨០ រោងម៉ាស៊ីន

ក្នុងរយៈពេល ៨ខែ ដំបូងនៃឆ្នាំ២០២៥ កម្ពុជាបាននាំចេញអង្ករចំនួន ៤៧២.៨០៣ តោន ទៅកាន់គោលដៅចំនួន ៦៦ ប្រទេសដែលមានតម្លៃសរុប៣៤៨,១៨លានដុល្លារអាមេរិក។បរិមាណនាំចេញនេះបានកើនឡើង១៤,៧៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ ដែលមានចំនួន ៤១២.០២៣តោន ខណៈចំណូលពីការនាំចេញក៏បានកើនឡើង ១៤,១% ស្មើនឹង ៣០៥,១៥ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០២៤។

ក្រៅពីការនាំចេញអង្ករកម្ពុជាក៏បាននាំចេញស្រូវតាមព្រំដែនទៅកាន់ប្រទេសជិតខាងចំនួនជាង ៤,៨៤ លានតោនដែលបានបង្កើតចំណូលប្រមាណ ១,១១៤ ពាន់លានដុល្លារអាមេរិក។

យោងតាមសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) ទីផ្សារនាំចេញសំខាន់ៗរួមមាន÷ អឺរ៉ុប (២៦ ប្រទេស)÷ ២២៦.៩១០ តោន មានតម្លៃ ១៥៦,៩២ លានដុល្លារអាម៉េរិក ចិន និងតំបន់ស្វយ័ត÷ ១១៦.៣២០ តោន មានតម្លៃ ៦៨,៨៦ លានដុល្លារអាម៉េរិក ប្រទេសសមាជិកអាស៊ាន(៧ប្រទេស)÷ ៦២.១៥៨តោន មានតម្លៃ ៤៣,៥០ លានដុល្លារអាម៉េរិក ទីផ្សារផ្សេងទៀត(៣២ ប្រទេស)÷ ៦៧.៤១១ តោន មានតម្លៃ ៥៩,៤៨ លានដុល្លារអាម៉េរិក។ សម្រាប់ប្រភេទអង្ករនាំចេញ អង្ករក្រអូបមានចំណែកធំបំផុត ៨៧% នៃបរិមាណនាំចេញសរុប បន្ទាប់មកអង្ករស ៩,៧២% អង្ករចំហុយ ១% អង្ករសរីរាង្គ ១,៨៣% និងអង្ករប្រភេទផ្សេងៗ ០,៤៥%។ ប្រភព÷ Cambodia Rice Federation (CRF), from January to August 2025)

GRI 203-1: ការវិនិយោគ និងសេវាកម្មហេដ្ឋារចនាសម្ព័ន្ធ
GRI 203-2: ផលវិជ្ជមានសំខាន់ៗទៅលើសេដ្ឋកិច្ចដោយប្រយោល

ហិរញ្ញប្បទានរាជរដ្ឋាភិបាល

ក្នុងនាមជាធនាគាររដ្ឋ ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(MEF) ធនាគារARDB ទទួលបានអត្ថប្រយោជន៍ពីជំនួយហិរញ្ញវត្ថុដែលសម្របសម្រួលដោយរាជរដ្ឋាភិបាល។ ទោះបីជា ធនាគារ ARDB មិនអាចទទួលបានថវិកាដោយផ្ទាល់ពីដៃគូអភិវឌ្ឍន៍អន្តរជាតិ តាមបទប្បញ្ញត្តិច្បាប់ក៏ដោយ ការសម្របសម្រួលការគាំទ្រហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍ (DPs) តាមរយៈរាជរដ្ឋាភិបាល មានតួនាទីយ៉ាងសំខាន់ក្នុងប្រតិបត្តិការ និងការអនុវត្តគម្រោងរបស់យើង។

ប្រភពហិរញ្ញប្បទានមួយចំនួនរបស់យើង មកពីដៃគូអភិវឌ្ឍន៍អន្តរជាតិ រួមមាន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) មូលនិធិហេដ្ឋារចនាសម្ព័ន្ធអាស៊ាន (AIF) មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) និងធនាគារពិភពលោក (WB)។ ថវិកាទាំងនេះមានសារៈសំខាន់យ៉ាងខ្លាំង ក្នុងការជួយឱ្យARDB អាចគាំទ្រដល់តួអង្គទាំងអស់ក្នុងខ្សែច្រវាក់តម្លៃវិស័យកសិកម្ម ចាប់ពីដំណាក់កាលដើមរហូតដល់ដំណាក់កាលចុងក្រោយ រួមមាន កសិករខ្នាតតូច សហគ្រាសខ្នាតមីក្រូ តូច និងមធ្យម (MSMEs) សហគ្រិន រោងចក្រកែច្នៃ អ្នកនាំចេញ និងសហគមន៍ជនបទនៅកម្ពុជា។ ការគាំទ្រនេះបានជំរុញកំណើនប្រកបដោយចីរភាព និងភាពធន់នៃវិស័យកសិកម្ម ស្របតាមវិសាលភាពនៃគម្រោងនីមួយៗ។

តារាង: សេចក្តីសង្ខេបអំពីថវិកាឥណទានសរុបដែលទទួលបានពីដៃគូអភិវឌ្ឍន៍តាមគម្រោង

គំរោង	រយៈពេល	ត្រឹមថ្ងៃទី ៣១ ធ្នូ២០២៤ (គិតជា ដុល្លារអាមេរិក)	ត្រឹមថ្ងៃទី ៣១ ធ្នូ ២០២៥	ដៃគូរអភិវឌ្ឍន៍
CASDP	២០២៣-២០២៥	៩,៧៤៧,៤៧៦	១៣,៥៣៦,៣៩៧	World Bank
AIMS	២០១៨-២០២៤	៥,000,000	៥,000,000	IFAD
ACSEP	២០២៣-២០២៥	២,៦១១,000	៨,0៦៥,000	ADB
		0	១,000,000	AIF
ASPIREAT	២០២៥	0	១,៧00,000	IFAD

តារាង: សេចក្តីសង្ខេបអំពីថវិកាជំនួយសរុបដែលទទួលបានពីដៃគូអភិវឌ្ឍន៍តាមគម្រោង

គំរោង	រយៈពេល	ត្រឹមថ្ងៃទី ៣១ ធ្នូ២០២៤ (គិតជា ដុល្លារអាមេរិក)	ត្រឹមថ្ងៃទី៣១ ធ្នូ ២០២៥ (គិតជា ដុល្លារអាមេរិក)	ដៃគូរអភិវឌ្ឍន៍
AIMS	២០១៨-២០២៤	៥,៥៤0,៧៣៨	0	IFAD
AIMS-AF	២០២៥	0	១,0១៧,៩៧៥	IFAD
ASPIRE-AT	២០២៥	0	៤៦៩,១00	IFAD

GRI 201-2: ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងហានិភ័យ និងឱកាសផ្សេងទៀតដោយសារការប្រែប្រួលអាកាសធាតុ
GRI 201-4: ជំនួយហិរញ្ញវត្ថុទទួលបានពីរដ្ឋាភិបាល

វត្តមានរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម នៅលើទីផ្សារ

អនុបាតនៃកម្រិតប្រាក់ឈ្នួលស្តង់ដារសម្រាប់បុគ្គលិកថ្មីតាមភេទ ធៀបនឹងប្រាក់ឈ្នួលអប្បបរមាជាតិ

ស្របតាមច្បាប់ការងារជាតិនៃព្រះរាជាណាចក្រកម្ពុជា ធនាគារ ARDB តែងតែគោរពយ៉ាងខ្ជាប់ខ្ជួនន្ទូវបទប្បញ្ញត្តិជាតិមួយចំនួន និងផ្តល់ប្រាក់ឈ្នួលកម្រិតចូលបម្រើការងារដល់បុគ្គលិកទាំងអស់ ដោយមិនប្រកាន់ភេទឡើយ។ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីប្រកាសអំពីប្រាក់ឈ្នួលអប្បបរមាថ្មី នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤។ សេចក្តីប្រកាសនោះបានបញ្ជាក់ថា ប្រាក់ឈ្នួលអប្បបរមា ចំនួន ២០៨ ដុល្លារអាម៉ើរិកក្នុងមួយខែ។ ច្បាប់នេះនឹងចូលជាធរមានជាផ្លូវការ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ សម្រាប់វិស័យប្រើប្រាស់កម្លាំងពលកម្មច្រើននៅកម្ពុជា ជាពិសេសវិស័យកាត់ដេរ ស្បែកជើង និងផលិតផលធ្វើដំណើរ (GFT) ដែលក៏ត្រូវបានប្រើជាគោលសម្រាប់វិស័យផ្សេងៗទាំងអស់នៅក្នុងប្រទេសផងដែរ។

បន្ថែមពីនេះ នីតិវិធីអនុវត្តស្តង់ដារ (SOP) ធនធានមនុស្សរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានកំណត់ន្ទូវគោលការណ៍ផ្តល់ប្រាក់បៀវត្សដោយផ្អែកលើលក្ខណៈសម្បត្តិ និងបន្ទុកការងាររបស់បុគ្គលិកនីមួយៗ។ ទោះបីជាយ៉ាងនេះក្តី ប្រាក់បៀវត្សរបស់បុគ្គលិកម្នាក់ៗត្រូវបានរក្សាជាការសម្ងាត់ និងមិនត្រូវបានបង្ហាញទៅកាន់បុគ្គលិក ឬស្ថាប័នដទៃទៀតនោះទេ។

អនុបាតនៃអ្នកគ្រប់គ្រងជាន់ខ្ពស់ ជាជនជាតិខ្មែរ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម មានបុគ្គលិកសរុបចំនួន ៣៩៩នាក់។ ក្នុងនោះមុខតំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ទាំងអស់ រួមបញ្ចូលទាំងគណៈគ្រប់គ្រង និងថ្នាក់នាយកដ្ឋាន (ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន) សុទ្ធតែត្រូវបានជ្រើសរើសក្នុងចំណោមប្រជាជនខ្មែរដែលមានសិទ្ធិស្នាក់នៅអចិន្ត្រៃយ៍មកពីគ្រប់រាជធានី-ខេត្តនៅក្នុងប្រទេសកម្ពុជា។ ការណ៍នេះបានបង្កើនទំនុកចិត្តរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងអនុញ្ញាតឱ្យធនាគារអាចពង្រីកឥទ្ធិពលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាពនៅទូទាំងប្រទេស។

GRI 202-1: សមាមាត្រនៃប្រាក់ឈ្នួលកម្រិតស្តង់ដារតាមភេទធៀបនឹងប្រាក់ឈ្នួលអប្បបរមាក្នុងស្រុក
GRI 202-2: សមាមាត្រនៃគណៈគ្រប់គ្រងជាន់ខ្ពស់ដែលមកពីសហគមន៍ក្នុងស្រុក

៦. សកម្មភាពចំណូលខុសត្រូវសង្គម របស់ធនាគារ ARDB

មូលនិធិគន្ធបុប្ផាកម្ពុជា ៥៦
ការចូលរួមរបស់ ធនាគារ ARDB ក្នុងការគាំទ្រវប្បធម៌..... ៥៦-៥៧
ធនាគារ ARDB បានបង្កើតបណ្ណាល័យមួយនៅទីស្នាក់ការកណ្តាល..... ៥៧
មជ្ឈមណ្ឌលអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន..... ៥៨
មជ្ឈមណ្ឌលឧត្តមភាព ARDB ACE-GFA..... ៥៩

៦. សកម្មភាពទំនួលខុសត្រូវសង្គមរបស់ធនាគារ ARDB

មូលនិធិគន្ធបុប្ផាកម្ពុជា

ថ្នាក់ដឹកនាំនិងបុគ្គលិកនៃធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម(ARDB) បានចូលរួមដោយស្ម័គ្រចិត្តក្នុងការបរិច្ចាគថវិកាប្រចាំខែជូនមូលនិធិគន្ធបុប្ផា តាមរយៈការអនុញ្ញាតឱ្យកាត់ប្រាក់ដោយផ្ទាល់ពីគណនីសន្សំផ្ទាល់ខ្លួនរបស់បុគ្គលិក។

ក្នុងឆ្នាំ២០២៥ ថ្នាក់ដឹកនាំ និងបុគ្គលិក ធនាគារARDB បានបន្តការបរិច្ចាគប្រចាំខែនេះ ហើយគិតត្រឹមឆ្នាំ២០២៥ ចំនួនទឹកប្រាក់សរុបដែលបានបរិច្ចាគមានចំនួន ១៩,៨១៨.០០ ដុល្លារអាមេរិក។

ការបរិច្ចាគរបស់ធនាគារ ARDB ជូនសមាគមកាកបាទក្រហមកម្ពុជា



សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តម កៅ ថាច** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និង **លោកជំទាវ សួរ សុខគីម** ព្រមទាំងថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់របស់ធនាគារ ARDB។ ក្នុងការចូលរួមបរិច្ចាគថវិកាចំនួន ៧,៣៨០ ដុល្លារអាមេរិក ជូនកាកបាទក្រហមកម្ពុជា ក្នុងឱកាសខួបលើកទី១៦២ នៃទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម (ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៥) និងខួបលើកទី៧០ នៃកាកបាទក្រហមកម្ពុជា ដែលប្រារព្ធឡើងក្រោមប្រធានបទ÷“រួមគ្នាស្ម័គ្រចិត្ត ដើម្បីសហគមន៍មានសុខភាពល្អ និងភាពធន់នឹងការប្រែប្រួលអាកាសធាតុ”។

ការចូលរួមរបស់ធនាគារ ARDB ក្នុងការគាំទ្រវប្បធម៌



ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានចូលរួមយ៉ាងសកម្មក្នុងការគាំទ្រសកម្មភាពវប្បធម៌ តាមរយៈការបរិច្ចាគស្បៀងអាហារ និងសម្ភារចាំបាច់នានាជូនវត្តអារាម។ គំនិតផ្តួចផ្តើមនេះបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ ARDB ចំពោះទំនួលខុសត្រូវសង្គម ព្រមទាំងការអភិរក្សប្រពៃណីវប្បធម៌ និងសាសនារបស់កម្ពុជា។ សកម្មភាពទាំងនេះក៏បានលើកកម្ពស់ស្មារតីមេត្តាករុណា និងសាមគ្គីភាពរបស់ ARDB ផងដែរ ក៏ដូចជាជួយជំរុញតម្លៃសីលធម៌ និងពង្រឹងការចូលរួមរួមគ្នានៅក្នុងសង្គម។

ឯកឧត្តមបណ្ឌិត កៅ ថាច ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម និងបុគ្គលិកទាំងអស់របស់ ធនាគារ ARDB រួមជាមួយសហការី និងសប្បុរសជនពីក្នុង និងក្រៅប្រទេស បានអញ្ជើញទៅសួរសុខទុក្ខ និងសម្តែងការគាំទ្រដល់ប្រជាពលរដ្ឋដែលបានផ្លាស់ទីលំនៅដោយសារជម្លោះតាមព្រំដែនកម្ពុជា-ថៃនិងកំពុងស្នាក់នៅជាបណ្តោះអាសន្ននៅមណ្ឌលសុវត្ថិភាព។

ស្បៀងអាហារ និងសម្ភារចាំបាច់នានា ត្រូវបានរៀបចំ និងប្រគល់ជូនដល់កងទ័ពជួរមុខ ដើម្បីសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះវីរភាព និងការលះបង់ដ៏មានតម្លៃរបស់ពួកគេសម្រាប់ជាតិមាតុភូមិ។ ក្នុងស្មារតីសាមគ្គីជាតិខ្មែរ “ខ្មែរជួយខ្មែរ” និងដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា **ឯកឧត្តមបណ្ឌិត កៅ ថាច** និងបុគ្គលិកទាំងអស់របស់ ធនាគារ ARDB រួមជាមួយសហការី និងសប្បុរសជន បានផ្តល់ជាស្បៀងអាហារ និងសម្ភារនានាជូនដល់គ្រួសារដែលបានផ្លាស់ទីលំនៅចំនួន ២,៦៥០ គ្រួសារ គាំទ្រក្រុមគ្រូពេទ្យស្ម័គ្រចិត្តដែលប្រចាំការនៅមណ្ឌលស្នាក់នៅ និងប្រគល់សម្ភារចាំបាច់ជូនដល់កងទ័ពកម្ពុជានៅជួរមុខ ដោយមានតម្លៃសរុបនៃការចូលរួមចំណែកចំនួន ៧៣,៥០៨.២៩ ដុល្លារអាមេរិក។





ធនាគារ ARDB បានបង្កើតបណ្ណាល័យមួយនៅទីស្នាក់ការកណ្តាល



ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម មានសេចក្តីសោមនស្សរីករាយក្នុងការទទួលស្គាល់ និងសម្តែងនូវការអរគុណយ៉ាងស្មោះស្ម័គ្រចំពោះការបរិច្ចាគសៀវភៅដ៏សប្បុរសពីភាគីពាក់ព័ន្ធទាំងខាងក្នុង និងខាងក្រៅស្ថាប័ន។ ដោយចំនួនសៀវភៅសរុបចំនួន ១,២៥៥ក្បាល ត្រូវបានបរិច្ចាគដោយថ្នាក់ដឹកនាំ និងបុគ្គលិករបស់ធនាគារ ARDBដែលបានឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការចែករំលែកចំណេះដឹង ការសិក្សាបន្ត និងការអភិវឌ្ឍស្ថាប័ន។ ការចូលរួមពីផ្នែកខាងក្នុងនេះ បានបង្ហាញពីស្មារតីសាមគ្គី និងការយកចិត្តទុកដាក់របស់បុគ្គលិក ធនាគារ ARDB ក្នុងការលើកកម្ពស់ការអប់រំ និងការកសាងសមត្ថភាព។ បន្ថែមពីនេះធនាគា ARDB ក៏បានទទួលសៀវភៅចំនួន ១,០៦០ ក្បាល ពីប្រភពខាងក្រៅផងដែរ។ ការចូលរួមដ៏មានតម្លៃទាំងនេះ បានជួយបន្ថែមធនធានសិក្សារបស់ធនាគារ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយដៃគូដែលមានចក្ខុវិស័យដូចគ្នាក្នុងការលើកកម្ពស់ការអប់រំ និងការអភិវឌ្ឍវិជ្ជាជីវៈ។ ជារួម ធនាគា ARDB បានទទួលសៀវភៅចំនួន ២,៣១៥ ក្បាល ដែលនឹងក្លាយជាធនធានដ៏សំខាន់សម្រាប់គាំទ្រដល់ការសិក្សា ការស្រាវជ្រាវ និងការពង្រឹងចំណេះដឹងរបស់បុគ្គលិក ជាពិសេស ដោយផ្តោតលើគោលដៅអភិវឌ្ឍធនធានមនុស្សសម្រាប់ឆ្នាំ២០២៥។

មជ្ឈមណ្ឌលអគ្គបណ្ឌិតសាស្ត្រាចារ្យ អូន ព័ន្ធមុនីរ័ត្ន (APM Center)

មជ្ឈមណ្ឌល APM ត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ចំណេះដឹង ជំរុញនវានុវត្តន៍ និងពង្រឹងសមត្ថភាពរបស់ភាគីពាក់ព័ន្ធជាច្រើន ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងការអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា តាមរយៈមុខងារស្រាវជ្រាវ និងការអភិវឌ្ឍធនធានមនុស្ស។

ចក្ខុវិស័យ

មជ្ឈមណ្ឌលAPM មានគោលបំណងក្លាយជាស្ថាប័នមួយដែលប្តេជ្ញាក្នុងការផលិត និងផ្សព្វផ្សាយចំណេះដឹង ព្រមទាំងបណ្តុះបណ្តាលអ្នកជំនាញ ដើម្បីគាំទ្រការរៀបចំគោលនយោបាយផ្អែកលើភស្តុតាង សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងវិស័យធនាគារដោយរួមចំណែកដល់ការសម្រេចបាននូវអនាគតដែលមានវិបុលភាព ចីរភាព និងបរិយាបន្នសម្រាប់កម្ពុជា។

បេសកកម្ម

ដើម្បីសម្រេចបាននូវចក្ខុវិស័យនេះ មជ្ឈមណ្ឌលAPM ប្តេជ្ញាក្នុងការសិក្សា និងផ្សព្វផ្សាយអំពីបញ្ហាប្រឈមសំខាន់ៗដែលប៉ះពាល់ដល់សេដ្ឋកិច្ច និងវិស័យធនាគារទៅកាន់ភាគីពាក់ព័ន្ធសំខាន់ៗ កំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលមានប្រសិទ្ធភាព និងអនុវត្តបានជាក់ស្តែង ព្រមទាំងពង្រឹងសមត្ថភាព បុគ្គលិកធនាគារARDB និងភាគីពាក់ព័ន្ធផ្សេងៗ ដើម្បីគាំទ្រកិច្ចខិតខំអភិវឌ្ឍនិងសម្រេចគោលដៅអភិវឌ្ឍន៍ទាំងនៅកម្រិតជាតិ និងអន្តរជាតិ។

មជ្ឈមណ្ឌលឧត្តមភាព ARDB ACE-GFA

មជ្ឈមណ្ឌលឧត្តមភាព សម្រាប់ការសិក្សាស្រាវជ្រាវពីហិរញ្ញប្បទានបៃតងចំពោះវិស័យកសិកម្មរបស់សមាគមឥណទានកសិកម្ម និងជនបទ អាស៊ី-ប៉ាស៊ីហ្វិក (មជ្ឈមណ្ឌលឧត្តមភាព ARDB ACE-GFA) ត្រូវបានដាក់ឱ្យដំណើរការជាផ្លូវការនៅខែមេសាឆ្នាំ២០២៥នៅទីស្នាក់ការកណ្តាលរបស់ធនាគារADB។មជ្ឈមណ្ឌលនេះត្រូវបានបង្កើតឡើងដោយផ្អែកលើយុទ្ធសាស្ត្រស្នូលចំនួន ៥ ដែលមានគោលបំណងបម្លែងទិដ្ឋភាពនៃហិរញ្ញប្បទានបៃតងសម្រាប់វិស័យកសិកម្មនៅទូទាំងតំបន់ តាមរយៈ÷ (១) ការស្រាវជ្រាវ និងការផ្សព្វផ្សាយចំណេះដឹង (២) ការបណ្តុះបណ្តាល និងការកសាងសមត្ថភាព (៣) កិច្ចសន្ទនាគោលនយោបាយ និងវេទិកាផ្សេងៗ (៤) ការអនុវត្តគម្រោងសាកល្បង (៥) សេវាប្រឹក្សា និងពិគ្រោះយោបល់។

ចក្ខុវិស័យ

ក្លាយជាមជ្ឈមណ្ឌលឧត្តមភាពឈានមុខគេក្នុងវិស័យហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានអាកាសធាតុសម្រាប់ប្រព័ន្ធកសិ-ស្បៀង ដោយជំរុញការអនុវត្តប្រកបដោយចីរភាព និងលើកកម្ពស់ការអភិវឌ្ឍជនបទប្រកបដោយបរិយាបន្ននៅទូទាំងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

បេសកកម្ម

ជំរុញ និងគាំទ្រហិរញ្ញប្បទានប្រកបដោយចីរភាព មានឥទ្ធិពលលើគោលនយោបាយ និងបញ្ចូលហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានអាកាសធាតុទៅក្នុងប្រព័ន្ធកសិ-ស្បៀង។

ដើរតួនាទីជាមជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវ ការបណ្តុះបណ្តាល និងការចែករំលែកអនុវត្តល្អៗ ក្នុងវិស័យហិរញ្ញប្បទានបៃតង និងកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុ។

អភិវឌ្ឍដំណោះស្រាយហិរញ្ញវត្ថុប្រកបដោយនវានុវត្តន៍ ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងជំរុញកិច្ចសហប្រតិបត្តិការសម្រាប់ប្រព័ន្ធកសិ-ស្បៀងប្រកបដោយចីរភាព នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

៧. ទំនួលខុសត្រូវផ្នែកបរិស្ថាន

ថាមពល.....៦០-៦១
ការប្រើប្រាស់ទឹក.....៦១
ការបំភាយឧស្ម័នផ្ទះកញ្ចក់.....៦២
កាកសំណល់/ សំរាម.....៦២
ការកាត់បន្ថយការប្រើប្រាស់ក្រដាស.....៦៣
ការប្រើប្រាស់ប្លាស្ទិកឡើងវិញ.....៦៤
ការកែច្នៃថាមពលកកើតឡើងវិញ.....៦៤
ការវាយតម្លៃបរិស្ថានរបស់អ្នកផ្គត់ផ្គង់.....៦៥

៧. ទំនួលខុសត្រូវផ្នែកបរិស្ថាន



ក្នុងនាមជាអ្នកចូលរួមយ៉ាងសកម្មក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងការរិចរិលផ្នែកបរិស្ថាន ធនាគារ ARDB បានបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីរួមបញ្ចូលការអនុវត្តប្រកបដោយការប្រុងប្រយ័ត្នចំពោះផលប៉ះពាល់ផ្នែកបរិស្ថានទៅក្នុងប្រតិបត្តិការប្រចាំថ្ងៃដោយបន្ថែមលើបេសកកម្មចម្បងរបស់ធនាគារ ARDB ក្នុងការគាំទ្រដល់គោលដៅការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងបរិស្ថានជាតិរបស់កម្ពុជា។



ថាមពល

ការប្រើប្រាស់ថាមពល

ការប្រើប្រាស់ឥន្ធនៈ និងអគ្គិសនី គឺជាផ្នែកសំខាន់នៃការប្រើប្រាស់ថាមពលរបស់ ធនាគារ ARDB នៅក្នុងអង្គភាព។ ការប្រើប្រាស់ថាមពលសរុបបានកើនឡើងក្នុងឆមាសទី២ នៃឆ្នាំនេះ បន្ទាប់ពី ARDB បានផ្លាស់ប្តូរទៅកាន់អគារថ្មី។ ជាទូទៅ ធនាគារ ARDB ប្រើប្រាស់ថាមពលតាមរយៈមធ្យោបាយផ្សេងៗ រួមមាន ប្រេងសាំង និងប្រេងម៉ាស៊ូតសម្រាប់ការដឹកជញ្ជូន និងការប្រើប្រាស់ ម៉ាស៊ីនផ្សេងៗ ព្រមទាំងអគ្គិសនីសម្រាប់ប្រព័ន្ធភ្លើងបំភ្លឺ និងប្រព័ន្ធត្រជាក់។

ទិន្នន័យនៃការប្រើប្រាស់ថាមពលនៅឆ្នាំ ២០២៥

ប្រេងឥន្ធនៈ	សាំង	ម៉ាស៊ូត	សរុប
ការិយាល័យកណ្តាល	២.៧៧៧	៧.៥២៣	១០.៣០០
សាខាខេត្ត	០.០០០០២៣	២.៨២៩	២.៨២៩
ការិយាល័យចល័ត	២.២០៦	៣.៩៨៩	៦.១៩៥
សរុប	៤.៩៨៣	១៤.៣៤១	១៩.៣២៤

តារាងទី១÷ ទិន្នន័យនៃការប្រើប្រាស់ឥន្ធនៈសរុបរបស់ធនាគារ ARDB នៅក្នុងឆ្នាំ ២០២៥ គិតជា Megajoules (MJ)

ថាមពល	សាំង	អគ្គិសនី	សរុប
ការិយាល័យកណ្តាល	១០.៣	២,៩០៤,៥០៩	២,៩០៤,៥១៩
សាខាខេត្ត	២.៨២៩	៧១៧,០៣៧	៧១៧,០៤០
ការិយាល័យចល័ត	៦.១៩៥	៩៣,១៥០	៩៣,១៥៦
សរុប	១៩.៣២៤	៣,៧១៤,៦៩៦	៣,៧១៤,៧១៥

តារាងទី២÷ ទិន្នន័យនៃការប្រើប្រាស់ថាមពលសរុបរបស់ធនាគារ ARDB នៅក្នុងឆ្នាំ ២០២៥ គិតជា Megajoules (MJ)

ការប្រើប្រាស់ថាមពល ប្រៀបធៀបនឹងឆ្នាំ ២០២៤

ការប្រើប្រាស់ថាមពលសរុបក្នុងឆ្នាំ ២០២៥ បានកើនឡើង ៣៣% ប្រៀបធៀបនឹងឆ្នាំ ២០២៤ ដែលបណ្តាលមកពីកត្តាជាច្រើន។ ជាពិសេស ក្នុងឆ្នាំ ២០២៤ ធនាគារ ARDB បានផ្លាស់ប្តូរការិយាល័យនៅក្នុងត្រីមាសទី២ ដែលបណ្តាលឱ្យការប្រតិបត្តិការនៅការិយាល័យថ្មីមានរយៈពេលត្រឹមតែផ្នែកមួយនៃឆ្នាំប៉ុណ្ណោះ។ ក្នុងន័យនេះ ឆ្នាំ ២០២៥ បានឆ្លុះបញ្ចាំងពីការប្រតិបត្តិការពេញមួយឆ្នាំនៅការិយាល័យថ្មីដែលជាមូលហេតុនាំឱ្យមានការកើនឡើងនៃការប្រើប្រាស់ថាមពលប្រៀបធៀបនឹងឆ្នាំ ២០២៤។ បន្ថែមពីនេះ នៅឆ្នាំ ២០២៥ ARDB បានសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវអគារសាខាភ្នំពេញថ្មី ព្រមទាំងបណ្ណាល័យ មជ្ឈមណ្ឌល APM និងមជ្ឈមណ្ឌល ARDB ACE-GFA។ ការចាប់ផ្តើមប្រតិបត្តិការនៅទីតាំងទាំងនេះ បានរួមចំណែកបន្ថែមដល់ការកើនឡើងសរុបនៃការប្រើប្រាស់ថាមពល។

ការប្តេជ្ញាចិត្តចំពោះការប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព

ដើម្បីលើកកម្ពស់ និងបង្ហាញការប្តេជ្ញាចិត្តចំពោះប្រសិទ្ធភាពថាមពល ធនាគារ ARDB ក៏បានរៀបចំយុទ្ធសាស្ត្រតាមរយៈគំនិតផ្តួចផ្តើមជាច្រើន ដើម្បីកាត់បន្ថយការប្រើប្រាស់ថាមពលក្នុងឆ្នាំបន្ទាប់។ គំនិតផ្តួចផ្តើមទាំងនោះរួមមាន÷

- **យុទ្ធនាការលើកកម្ពស់ការយល់ដឹងអំពីការសន្សំថាមពលនៅកន្លែងធ្វើការ÷** ធនាគារ ARDB បានដាក់ឱ្យអនុវត្តយុទ្ធនាការសន្សំថាមពលនៅកន្លែងធ្វើការ ក្នុងគោលបំណងបង្កើតវប្បធម៌នៃការប្រើប្រាស់ថាមពលប្រកបដោយទំនួលខុសត្រូវក្នុងចំណោមបុគ្គលិក រួមមានការកំណត់សីតុណ្ហភាពម៉ាស៊ីនត្រជាក់ និងការរំលឹកប្រចាំសប្តាហ៍ឱ្យបិទកុំព្យូទ័រ ភ្លើង និងឧបករណ៍ផ្សេងៗ បន្ទាប់ពីម៉ោងធ្វើការ។
- **ការត្រួតពិនិត្យសន្តិសុខប្រចាំថ្ងៃបន្ទាប់ពីម៉ោងធ្វើការ÷** ដើម្បីធានាថាឧបករណ៍អគ្គិសនីទាំងអស់ត្រូវបានបិទបន្ទាប់ពីម៉ោងធ្វើការ។
- **ការចាប់ផ្តើមដំឡើងប្រព័ន្ធភ្លើង LED÷** ធនាគារ ARDB បានចាប់ផ្តើមផ្លាស់ប្តូរមកប្រើប្រាស់ភ្លើង LED ជាគម្រោងសាកល្បង ដើម្បីវាយតម្លៃសក្តានុពលនៃការសន្សំថាមពល។
- **ការដំឡើងប្រព័ន្ធសូឡា** (Solar Panel System)÷ ធនាគារ ARDB បានចាប់ផ្តើមដំឡើងប្រព័ន្ធសូឡា ដើម្បីផលិតថាមពលស្អាត ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពថាមពល កាត់បន្ថយការប្រើប្រាស់អគ្គិសនី និងរួមចំណែកដល់និរន្តរភាពបរិស្ថាន។

ការប្រើប្រាស់ទឹក

ការប្រើប្រាស់ទឹក

ការប្រើប្រាស់ទឹករបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) គឺបានមកពីរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (PPWSA) ហើយត្រូវបានប្រើប្រាស់ដោយផ្ទាល់រួមមានទាំងការប្រើប្រាស់សម្រាប់បន្ទប់ទឹកការហូបទឹករបស់បុគ្គលិកការលាងសម្អាតរថយន្តដឹកជញ្ជូនរបស់អង្គភាព និងមិនទាន់មានប្រព័ន្ធនៃការស្តុកទឹកទុកនៅឡើយ។

ទិន្នន័យនៃការប្រើប្រាស់ទឹកនៅឆ្នាំ ២០២៥

	ការប្រើប្រាស់ទឹក
ការិយាល័យកណ្តាល	៦,៧៦៥,000
សាខាតាមខេត្ត	១៨,0៨១,000
ការិយាល័យចល័ត	១,៧៩៩,000
សរុប	២៦,៦៤៥,000

តារាងទី៣÷ ធនាគារអភិវឌ្ឍន៍កសិកម្ម និង ជនបទ(ARDB)ឆ្នាំ ២០២៥ ការប្រើប្រាស់ទឹកសរុបគិតជា cu.m

GRI 302-4: ការកាត់បន្ថយការប្រើប្រាស់ថាមពល
GRI 303-5: ការប្រើប្រាស់ទឹក

លើសពីនេះ ធនាគារអភិវឌ្ឍន៍ជនបទ និង សិកម្ម (ARDB) ក៏បានគិតគូរពីប្រសិទ្ធភាពនៃការប្រើប្រាស់ទឹកផងដែរ។ ដើម្បីរក្សាការប្រើប្រាស់ទឹកប្រកបដោយប្រសិទ្ធភាព ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម (ARDB) បាន រួមបញ្ចូលសកម្មភាពមួយចំនួនដែលជាការប្តេជ្ញាចិត្តឆ្ពោះទៅរកនិរន្តរភាពដូចខាងក្រោម÷ បុគ្គលិកសម្អាតបានពិនិត្យការប្រើប្រាស់ទឹកក្នុងបន្ទប់ទឹកជាប្រចាំថ្ងៃ។ រាល់បញ្ហា ឬការខូចខាតណាមួយដែលត្រូវបានរាយការណ៍ទៅនាយកដ្ឋានរដ្ឋបាល និងទំនាក់ទំនងសាធារណៈ ដើម្បីថែទាំ ឬជួសជុលជាបន្ទាន់។

ការបំភាយឧស្ម័នផ្ទះកញ្ចក់

គិតត្រឹមឆ្នាំ ២០២៥ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) មិនទាន់មានវិធីសាស្ត្រក្នុងការគណនាការបំភាយឧស្ម័នផ្ទះកញ្ចក់(GHGs) នៅឡើយទេ។ ប៉ុន្តែធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម(ARDB) បានដឹងពីសារៈសំខាន់នៃការគណនាការបំភាយឧស្ម័នផ្ទះកញ្ចក់(GHGs) ខណៈពេលដែលការបំភាយឧស្ម័នផ្ទះកញ្ចក់(GHGs) គឺជាកត្តាមួយដ៏សំខាន់ដែលជះឥទ្ធិពលលើការប្រែប្រួលអាកាសធាតុ។ ការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់របស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម(ARDB) ត្រូវបានផ្តោតលើទស្សនៈជាច្រើនដូចជា បច្ចេកវិទ្យាសន្សំសំចៃថាមពល ដូចជាការផ្លូចផ្តើមប្រើប្រាស់ LED និងការបិទ ភ្លើងបន្ទាប់ពីម៉ោងធ្វើការងារចប់។

លើសពីនេះ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) នឹងពិចារណាកិច្ចសហប្រតិបត្តិការជាមួយអ្នកប្រឹក្សាយោបល់ ឬដៃគូរអភិវឌ្ឍន៍ក្នុងការគណនាការបំភាយឧស្ម័នផ្ទះកញ្ចក់ផ្ទាល់ (Scope ១) នៅក្នុងរបាយការណ៍បន្តបន្ទាប់ទៀត។

កាកសំណល់/សំរាម

ផលិតផលឥណទានបៃតង

ជំណើរការវាយតម្លៃឥណទានបៃតងរបស់ ធនាគារARDB បានរួមបញ្ចូលផ្នែកបរិស្ថាន និងសង្គម(E&S) ដោយលើកទឹកចិត្តឱ្យអតិថិជន ដែលទទួលបានឥណទានយកទៅអនុវត្តទៅលើការគ្រប់គ្រងសំណល់ប្រកបដោយការទទួលខុសត្រូវខ្ពស់។ ការវាយតម្លៃនេះ មានគោលបំណងកំណត់អត្តសញ្ញាណ ផលជះសំខាន់ៗដល់បរិស្ថានរួមមាន÷ការបំពុលទឹកការបំពុលខ្យល់ការសឹករិចរិលដី និងការបម្លែងកាកសំណល់រឹង និងរាវ ក្នុងគោលបំណងលើកកម្ពស់ដល់យុទ្ធសាស្ត្រកាត់បន្ថយការបំពុលដល់បរិស្ថាន។ វិធានការនេះ ត្រូវបានអនុវត្តយ៉ាងសកម្មដោយរួមបញ្ចូលលក្ខណៈវិនិច្ឆ័យលើបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ក្នុងការវាយតម្លៃឥណទានបៃតង។ ទោះបីជាការអនុវត្តទាំងនេះមិនមែនជាកាតព្វកិច្ចចាំបាច់ក៏ដោយ ធនាគារ ARDB បានលើកទឹកចិត្តឱ្យអតិថិជនអនុវត្តការគ្រប់គ្រងកាកសំណល់ប្រកបដោយប្រសិទ្ធភាពដូចជាការរៀបចំស្តុកទុកកាកសំណល់ឱ្យបានត្រឹមត្រូវការគ្រប់គ្រងកាកសំណល់ទៅតាមស្តង់ដា និងអនុវត្តការគ្រប់គ្រងកាកសំណល់ល្អស្របតាមគោលការណ៍សំខាន់ៗ ទាំង ៤ (4Rs) រួមមាន÷

កាត់បន្ថយ÷ កាត់បន្ថយការបង្កើតកាកសំណល់ដោយប្រើប្រាស់ធនធានឱ្យមានប្រសិទ្ធភាព និងកាត់បន្ថយការប្រើប្រាស់ជាអប្បបរិមា។

ប្រើឡើងវិញ÷ ប្រើប្រាស់សម្ភារៈឬផលិតផលឡើងវិញក្នុងគោលបំណងដូចគ្នា ឬផ្សេងគ្នា។

កែច្នៃឡើងវិញ÷ ការកែរច្នៃកាកសំណល់ទៅជាផលិត-ផលថ្មី។

បដិសេធ÷ ជៀសវាងការប្រើផលិតផល ដែលមិនចាំបាច់ ឬផលិតផលដែលអាចបង្កើតកាកសំណល់ច្រើន។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានប្តេជ្ញាចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវបរិស្ថាន តាមរយៈយុទ្ធសាស្ត្រអាជីវកម្មសកល ធ្វើកិច្ចសហការជាមួយដៃគូ ធ្វើប្រតិបត្តិការអាជីវកម្មឱ្យមានចីរភាព លើកកម្ពស់សុខមាលភាពរបស់បុគ្គលិក និងគ្រប់គ្រងហានិភ័យលើអភិបាលកិច្ចអាជីវកម្ម ដែលសកម្មភាពទាំងអស់នោះមានដូចជា÷

ការកាត់បន្ថយការប្រើប្រាស់ក្រដាស (Paper-less)

ធនាគារ ARDB បានអនុម័តដាក់ឱ្យប្រើប្រាស់គោលការណ៍ ដើម្បីកាត់បន្ថយការប្រើប្រាស់ក្រដាស ប្លាស្ទិច និងសម្ភារៈការិយាល័យដោយជំនួសជាការប្រើប្រាស់តាមរយៈប្រព័ន្ធឌីជីថលដូចជាការប្រើប្រាស់Tablet និងកុំព្យូទ័រដើម្បីកាត់បន្ថយទៅលើការប្រើប្រាស់ឯកសារជាក្រដាសនានា។

ក) ការគ្រប់គ្រងឯកសារឌីជីថល

- **ដំណើរការដាក់ពាក្យ÷** អតិថិជនអាចប្រើប្រាស់កម្មវិធីឌីជីថលនិងប្រព័ន្ធអេឡិចត្រូនិចក្នុងការដាក់ពាក្យស្នើសុំប្រើប្រាស់ផលិតផល និងសេវាកម្មធនាគារ ARDB ជាទម្រង់ស្នើសុំតាមប្រព័ន្ធអនឡាញដែលមានសុវត្ថិភាព។ ការកាត់បន្ថយការប្រើប្រាស់ឯកសារជាក្រដាស ជំរុញឱ្យការអនុវត្តប្រតិបត្តិការលឿនជាងមុន។
- **លំហូរនៃការអនុម័តការងារ÷** ការប្រើប្រាស់ Tablet និងកុំព្យូទ័រ ធ្វើឱ្យមានលំហូរការងារ ការអនុម័តប្រកបដោយប្រសិទ្ធភាព ដែលបុគ្គលិកនិងថ្នាក់ដឹកនាំ អាចពិនិត្យផ្ទៀងផ្ទាត់ ផ្តល់យោបល់ និងអនុម័តឯកសារតាមប្រព័ន្ធឌីជីថល បង្កើនល្បឿនការអនុវត្តការងារឆាប់រហ័ស។

ខ) ការកាត់បន្ថយធនធាន

- **កាត់បន្ថយការប្រើប្រាស់ក្រដាស÷** តាមរយៈការធ្វើឯកសារឌីជីថល យើងអាចប្រើប្រាស់ក្រដាសតិចជាងមុន ដែលកាត់បន្ថយកម្រិតកាបូន និងជួយការពារបរិស្ថាន។
- **កាត់បន្ថយការប្រើប្រាស់ផ្លាស្ទិច÷** គោលដៅប្រកបដោយចីរភាពរបស់ធនាគារ ARDB គឺធ្វើឱ្យថយចុះនៃការប្រើប្រាស់សម្ភារៈការិយាល័យ ដែលប្រើដោយក្រដាស ក្រណ្ឌ (folders) និងសាមីប្លាស្ទិចជាដើម។

គ) ការធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់

- **ការប្រើប្រាស់ពីចម្ងាយ÷** បុគ្គលិកទាំងអស់របស់ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) អាចចូលប្រើឯកសារដែលត្រូវការនៅក្នុងទីតាំងណាមួយដែលជំរុញឱ្យមានភាពប្រសើរឡើងនូវការងារជាក្រុមនិងភាពបត់បែនក្នុងកាលវិភាគការងារ ជាពិសេសសម្រាប់ក្រុមដែលធ្វើការងារពីចម្ងាយ។
- **ដំណើរការល្អប្រសើរ÷** ឧបករណ៍ឌីជីថលជួយសម្រួលដល់សកម្មភាពធនាគារជាច្រើនដោយសម្រួលដល់ការទាញយកព័ត៌មានឆាប់រហ័ស ការកែសម្រួលងាយស្រួលជាងមុន និងការចែករំលែកឯកសារជាក្រុមប្រកបដោយប្រសិទ្ធភាព។

ឃ) សន្តិសុខ និងការអនុលោមតាមច្បាប់

- **ការការពារទិន្នន័យ÷** ឯកសារឌីជីថលអាចត្រូវបានដាក់លេខកូត និងរក្សាទុកដោយសុវត្ថិភាពនៅលើCloud កាត់បន្ថយហានិភ័យដែលទាក់ទងនឹងការបាត់បង់ ឬខូចឯកសារច្បាប់ដើម។
- **ការអនុលោមតាមបទប្បញ្ញត្តិ÷** ការរក្សាកំណត់ត្រាអេឡិចត្រូនិចស្របតាមបទប្បញ្ញត្តិ ដែលធ្វើឱ្យងាយស្រួលក្នុងការរក្សាឯកសារទុកដែលមានភាពត្រឹមត្រូវ និងងាយស្រួលក្នុងការធ្វើសវនកម្ម។

ង) ការចូលរួមរបស់អតិថិជន

- **បទពិសោធន៍អតិថិជនកាន់តែប្រសើរឡើង÷** អតិថិជនទទួលបានអត្ថប្រយោជន៍ពីសេវាកម្មរហ័ស និងភាពងាយស្រួលនៃប្រតិបត្តិការអនឡាញ ហត្ថលេខាឌីជីថល និងការអនុម័តតាមអ៊ីនធឺណិតធ្វើឱ្យដំណើរការទាំងមូលកាន់តែងាយស្រួលប្រើប្រាស់។

- **មតិយោបល់ និងការទំនាក់ទំនង÷** ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលសម្រាប់ទទួលមតិយោបល់របស់អតិថិជន បង្កើនឱ្យមានទំនាក់ទំនង និងអនុញ្ញាតឱ្យអតិថិជនជ្រើសរើសដោយផ្ទាល់ទៅតាមការយល់ឃើញ និងកម្រិតចំណេះដឹងរបស់អតិថិជន។

ច) ការប្រើប្រាស់ម៉ាស៊ីនសម្ងួតដៃ

- ធនាគារ ARDB បានបំពាក់នូវម៉ាស៊ីនសម្ងួតដៃនៅគ្រប់បន្ទប់ទឹក ការបំពាក់នេះនឹងជួយដល់ការកាត់បន្ថយការប្រើប្រាស់ក្រដាសដើម្បីសម្ងួតដៃ។

ឆ) ស្លាកណែនាំឱ្យប្រើក្រដាស់តិច

- ធនាគារARDB បានបំពាក់ស្លាកណែនាំអំពីការប្រើប្រាស់ក្រដាស ដោយភ្ជាប់ពាក្យស្លោក"សន្សំសំចៃក្រដាស រក្សាព្រៃឈើ និងសង្គ្រោះពិភពលោក" នៅគ្រប់បន្ទប់ទឹករបស់ធនាគារ។

ការប្រើប្រាស់ប្លាស្ទិកឡើងវិញ

ធនាគារ ARDB បានទិញផលិតផលដែលអាចប្រើប្រាស់ឡើងវិញបាន (Good Refills) ដោយប្រើធុងដែលអាចបញ្ចូលសម្រាប់ការប្រើប្រាស់ម្តងទៀត(ឧទាហរណ៍ ពែងអ៊ីណុក ដបដែកអ៊ីណុកសម្រាប់លាងសម្អាត ប៊ិចដែលអាចបញ្ចូលទឹក) ដោយប្តូរពីធុងប្លាស្ទិកប្រើតែម្តងទៅជាដបដែកអ៊ីណុកដែលអាចប្រើឡើងវិញបានគឺជាការអនុវត្តប្រកបដោយនិរន្តរភាព ដែលស្របនឹងការកាត់បន្ថយកាកសំណល់បរិស្ថាន។ ជាមួយនឹងភាពធន់នៃដបដែកអ៊ីណុកមានភាពរឹងមាំ យូរអង្វែង និងធន់នឹងការប្រើប្រាស់។

ការកាត់បន្ថយកាកសំណល់ប្លាស្ទិកយ៉ាងខ្លាំង សកម្មភាពទាំងនេះមានផលជះជាវិជ្ជមានដល់បរិស្ថានដោយកាត់បន្ថយកម្រិតការបំពុលសរុប ជាពិសេសនៅក្នុងប្រព័ន្ធទឹក និងទីលានចាក់សំរាម ព្រោះប្លាស្ទិកតិចជាងនឹងត្រូវបានបោះចោល និងអាចជ្រើសយកកែច្នៃឡើងវិញ ដូច្នេះកាត់បន្ថយផលប៉ះពាល់នៃប្លាស្ទិកលើសត្វព្រៃ និងប្រព័ន្ធអេកូឡូស៊ី។

ដែកអ៊ីណុកមិនលាយសារធាតុគីមីដែលបង្កគ្រោះថ្នាក់ដូចជា BPA ទេ ដែលអាចផ្តល់សុវត្ថិភាពដល់សុខភាព មិនដូចប្លាស្ទិកទេ។ យូរៗទៅដបដែលអាចប្រើឡើងវិញ ដោយបានកាត់បន្ថយតម្រូវការសម្រាប់ការទិញម្តងហើយម្តងទៀតបើធៀបនឹងប្លាស្ទិកដែលប្រើតែម្តង រួមមានដូចជាដបទឹកជាដើម ដែលជាផ្នែកមួយនៃការធ្វើយុទ្ធនាការផ្សព្វផ្សាយ ឬចាប់រង្វាន់ផ្សេងៗ។

ការកែច្នៃថាមពលកកើតឡើងវិញ

ដើម្បីគាំទ្របុគ្គលិករបស់យើងក្នុងការកែច្នៃអាគុយ (ថ្ម) ដែលបានប្រើប្រាស់ឡើងវិញ ជាការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាព និងការប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ យើងចាប់ផ្តើមគម្រោងកែច្នៃអាគុយ (ថ្ម)ខាងក្នុង។ គំនិតផ្តួចផ្តើមនេះមានគោលបំណងលើកកម្ពស់និរន្តរភាពបរិស្ថានតាមរយៈការកាត់បន្ថយកាកសំណល់អាគុយ លើកកម្ពស់ការចូលរួមរបស់បុគ្គលិកក្នុងកម្មវិធីកែច្នៃឡើងវិញ ធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចវិលជុំតាមរយៈការមិនបោះកាកសំណល់ចោល ដែលប៉ះពាល់សុវត្ថិភាព និងឱកាសប្រើប្រាស់សម្ភារៈអាគុយឡើងវិញ និងការលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការប្រើប្រាស់ប្រកបដោយការទទួលខុសត្រូវ។

ការកែច្នៃថាមពលកកើតឡើងវិញ

ធនាគារ ARDB បានគោរពតាមច្បាប់ និងបទប្បញ្ញត្តិគ្រប់គ្រងកាកសំណល់ ហើយ បច្ចុប្បន្ន ធនាគារ ARDB កំពុងខិតខំប្រឹងប្រែងបង្កើតគំនិតផ្តួចផ្តើម និងបទប្បញ្ញត្តិផ្ទៃក្នុងលើ ផលប៉ះពាល់ដល់បរិស្ថាន ដើម្បីគ្រប់គ្រងការបោះចោលកាកសំណល់នៅទីស្នាក់ការកណ្តាលរបស់ធនាគារ នៅតាមសាខា និងការិយាល័យចល័តផ្សេងទៀត។

ការវាយតម្លៃបរិស្ថានក្រុមហ៊ុនផ្គត់ផ្គង់

ធនាគារ ARDB ក្រោមការត្រួតពិនិត្យបច្ចេកទេស និងហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រកាន់ខ្ជាប់នូវគោលការណ៍នៃលទ្ធកម្មប្រកបដោយនិរន្តរភាព ដូចដែលបានចែងនៅក្នុងមាត្រា ៥៦ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ ច្បាប់នេះត្រូវបានផ្សព្វផ្សាយដោយព្រះមហាក្សត្រលេខ. NS/RKAM/0523/005 ចេញផ្សាយនៅថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០២៣ បញ្ជាក់យ៉ាងច្បាស់ថា÷ *“លទ្ធកម្មសាធារណៈត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍នៃលទ្ធកម្មប្រកបដោយនិរន្តរភាព។ លទ្ធកម្មប្រកបដោយនិរន្តរភាពមានការអនុលោមតាមស្តង់ដារបច្ចេកទេស តម្រូវការ និងលក្ខណៈវិនិច្ឆ័យដែលផ្តល់អាទិភាពដល់ការការពារបរិស្ថាន និងការគ្រប់គ្រងផលប៉ះពាល់សេដ្ឋកិច្ចសង្គម។លក្ខខណ្ឌនិងនីតិវិធីសម្រាប់លទ្ធកម្មប្រកបដោយនិរន្តរភាពនឹងត្រូវបានបង្កើតឡើងដោយអនុក្រឹត”*។

លទ្ធកម្មប្រកបដោយចីរភាព

ធនាគារ ARDB ជាធនាគារដែលបម្រើគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដំណើរការលទ្ធកម្មរបស់ធនាគារ ARDB អនុវត្តតាមក្របខ័ណ្ឌរចនាសម្ព័ន្ធច្បាស់លាស់ ក្នុងគោលបំណងធានាថាការសម្រេចចិត្តទិញរបស់ធនាគារ មិនត្រឹមតែរួមចំណែកដល់ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ។ ដំណើរការនៃលទ្ធកម្មប្រកបដោយចីរភាព ត្រូវបានគ្រប់គ្រងជាចម្បងដោយច្បាប់ស្តីពីលទ្ធកម្មសាធារណៈ (២០២៣) និងបទប្បញ្ញត្តិដែលពាក់ព័ន្ធដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



ច្បាប់ស្តីពីលទ្ធកម្មសាធារណៈនៅកម្ពុជា (២០២៣) ដែលត្រូវបានប្រកាសដាក់ឱ្យប្រើនៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ រួមមានមាត្រាមួយ ស្តីពីការបង្កើតលទ្ធកម្មសាធារណៈប្រកបដោយចីរភាពនៅកម្ពុជា។ មាត្រា ៥៦ នៃច្បាប់ចែងថា

“ការអនុវត្តលទ្ធកម្មសាធារណៈ ត្រូវអនុលោមតាមបរិបទនៃលទ្ធកម្មប្រកបដោយចីរភាព។ លទ្ធកម្មសាធារណៈប្រកបដោយចីរភាព តម្រូវឱ្យមានលក្ខណៈបច្ចេកទេស លក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យ ដោយផ្តល់អាទិភាពដល់ការការពារបរិស្ថាន និងការគ្រប់គ្រងផលប៉ះពាល់លើសង្គម សេដ្ឋកិច្ច។ លក្ខខណ្ឌ វិធាន និងនីតិវិធីសម្រាប់ការអនុវត្តលទ្ធកម្មសាធារណៈប្រកបដោយចីរភាព ត្រូវកំណត់ដោយអនុក្រឹត្យ”

ជាចុងក្រោយ សកម្មភាពលទ្ធកម្មរបស់ធនាគារ ARDB នឹងត្រូវធ្វើសវនកម្ម និងត្រួតពិនិត្យដោយអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីវាយតម្លៃការអនុលោមតាមបទប្បញ្ញត្តិនិងកំណត់អត្តសញ្ញាណភាពមិនប្រក្រតី ឬផ្នែកណាសម្រាប់កែលម្អ។

GRI 306-4: កាកសំណល់ត្រូវបានបង្វែចេញពីការបញ្ចេញចោល
GRI 306-5: កាកសំណល់ដែលបានបញ្ចេញចោល
GRI 308: ការវាយតម្លៃផលជះដល់បរិស្ថាននៃអ្នកផ្គត់ផ្គង់
GRI 3-3: ការគ្រប់គ្រងប្រធានបទសំខាន់ៗ

៨. អភិបាលកិច្ច និងភាពចម្រុះ

វិធីសាស្ត្រនៃការគ្រប់គ្រង ៦៦
ក្រមសីលធម៌ និងសុចរិតភាព ៦៧-៦៨
ភាពចម្រុះ និងឱកាសស្មើគ្នា ៦៩-៧០
សុខភាព និងសុវត្ថិភាពការងារ ៧១-៧៤
ទំនួលខុសត្រូវផ្នែកសង្គម ៧៥
ការងារ ៧៥-៧៦
អត្ថប្រយោជន៍ការងារ ៧៧-៧៩
ការបណ្តុះបណ្តាល និងការអប់រំ ៨០-៨៥
សន្ទស្សន៍មាតិកាGRI ៨៦-៨៨

អតិថិជន និងភាពច្បាស់

ធនាគារARDB ទទួលស្គាល់ថាភាពច្បាស់ សមធម៌និងបរិយាបន្នគឺមានតម្លៃយ៉ាងសំខាន់ចំពោះសមត្ថភាពស្ថាប័ន ហើយវាមានឥទ្ធិពលទៅដល់ការផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចសង្គម ទូទាំងសហគមន៍ ខេត្ត និងតំបន់នានាក្នុងប្រទេសកម្ពុជា។ ធនាគារ ARDB បន្តខិតខំប្រឹងប្រែងដើម្បីដាក់បញ្ចូលគុណតម្លៃស្នូលរបស់ធនាគារ ដូចជា សុចរិតភាព កិច្ចសហការ និងនវានុវត្តន៍ ដើម្បីដើម្បីធានាបានទូវកន្លែងការងារដែលមានស្តង់ដារខ្ពស់ បរិយាកាសការងារល្អ និងគោរព ឱ្យតម្លៃទៅលើសុចរិតភាព យុត្តិធម៌ និងបរិយាប័ន្ន។



វិធីសាស្ត្រនៃការគ្រប់គ្រង





ក្រមសីលធម៌ និងសុចរិតភាព

ក្រមសីលធម៌វិជ្ជាជីវៈ:

ក្រមសីលធម៌ ត្រូវបានបង្កើត និងប្រកាសអនុវត្តដោយលិខិតសម្រេចលេខ ០០២/១៧ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៧ ដែលជាក្របខណ្ឌណែនាំអំពីអាកប្បកិរិយារបស់បុគ្គលិកដោយផ្តោតលើវិជ្ជាជីវៈការគោរពគ្នានិងសុចរិតភាព។

ធនាគារ ARDB បានធ្វើការទំនាក់ទំនងជាប្រចាំ និងផ្តល់ការបណ្តុះបណ្តាលដល់បុគ្គលិកទាំងអស់ អំពីក្រមសីលធម៌នេះដើម្បីធានាថាគ្រប់គ្នាយល់ដឹងច្បាស់អំពីអាកប្បកិរិយា និងស្តង់ដារដែលត្រូវអនុវត្ត។ វិធីសាស្ត្រប្រកបដោយភាពសកម្មនេះបានជួយលើកកម្ពស់វប្បធម៌ នៃការអនុវត្តតាមច្បាប់ និងសុចរិតភាព ព្រមទាំងផ្តល់អំណាច ដល់បុគ្គលិកក្នុងការរក្សាតម្លៃរបស់អង្គភាពក្នុងការប្រាស្រ័យទាក់ទងប្រចាំថ្ងៃ។

ក្រមសីលធម៌ស្ថាប័នហិរញ្ញវត្ថុ (BFI Code of Conduct): ធនាគារ ARDB ក៏អនុវត្តតាមក្រមសីលធម៌របស់វិស័យធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ដើម្បីធានាស្ថិរភាព និងនិរន្តរភាពនៃការរីកចម្រើនរបស់វិស័យធនាគារដោយជំរុញវប្បធម៌នៃសុចរិតភាព និងទំនុកចិត្តជាមួយភាគីពាក់ព័ន្ធ។

គោលការណ៍បណ្តឹងរបស់អតិថិជន

ធនាគារARDB បានអនុវត្តយ៉ាងសកម្មតាមគោលនយោបាយបណ្តឹងអតិថិជន ដែលបានកំណត់ក្នុងលិខិតសម្រេចលេខ ១៣៩/២១ ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ២០២១។ គោលនយោបាយនេះ អនុញ្ញាតឱ្យអតិថិជនរបស់ធនាគារអាចដាក់បណ្តឹងទាក់ទងនឹងផលិតផល ឬសេវាកម្មដែលមានការមិនស្រួល ឬបញ្ហាផ្សេងៗ។

បណ្តឹងអាចដាក់បានទាំងជាពាក្យផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ។ បណ្តឹងផ្ទាល់មាត់អាចដាក់ជូនបុគ្គលិកផ្នែកទទួលភ្ញៀវរួមទាំងមន្ត្រីសេវាអតិថិជនឬបុគ្គលិកដែលបានកំណត់ឱ្យទទួលបន្ទុកដោះស្រាយបណ្តឹង។ ចំពោះបណ្តឹងជាលាយលក្ខណ៍អក្សរ អតិថិជនអាចផ្ញើតាមរយៈអ៊ីមែល complaint@ardb.com.kh ឬតាមគេហទំព័រ ardb.com.kh ។

បណ្តឹងផ្ទាល់មាត់នឹងត្រូវបានដោះស្រាយក្នុងរយៈពេល ២ថ្ងៃ បន្ទាប់ពីទទួលបាន។ ចំណែកបណ្តឹងជាលាយលក្ខណ៍អក្សរ នឹងត្រូវដោះស្រាយក្នុងរយៈពេល ៣០ថ្ងៃ គិតចាប់ពីថ្ងៃដាក់បណ្តឹង ដើម្បីធានាការស៊ើបអង្កេត និងការឆ្លើយតបឱ្យបានពេញលេញ។

យន្តការសម្រាប់ការផ្តល់យោបល់ និងការរាយការណ៍ទាក់ទងនឹងក្រមសីលធម៌

ធនាគារ ARDB កំពុងស្ថិតក្នុងដំណាក់កាលរៀបចំគោលនយោបាយ និងនីតិវិធីស្តីពីវិស្សលប៉ូវីង។ គោលនយោបាយថ្មីនេះនឹងជួយពង្រឹងនូវប្រព័ន្ធសម្រាប់រាយការណ៍បញ្ហា និងសំណូមពរនានា មិនត្រឹមតែផ្តោតលើផលិតផល និងសេវាកម្មរបស់ធនាគារប៉ុណ្ណោះទេ ប៉ុន្តែក៏រាប់បញ្ចូលទាំងសកម្មភាពរបស់បុគ្គលិក និងថ្នាក់ដឹកនាំទាំងអស់នៅធនាគារ ARDB ផងដែរ។ បច្ចុប្បន្នគោលនយោបាយនេះកំពុងស្ថិតក្នុងដំណាក់កាលព្រាង ដែលនឹងបញ្ចប់ និងដាក់ឱ្យអនុវត្តនៅឆ្នាំ២០២៥។

GRI 2-23 ការប្តេជ្ញាទៅលើគោលការណ៍
GRI 2-26: យន្តការសម្រាប់ស្វែងរកយោបល់ និងលើកឡើងកង្វល់
GRI 205-1: ប្រតិបត្តិការត្រូវបានវាយតម្លៃសម្រាប់ហានិភ័យដែលទាក់ទងនឹងអំពើពុករលួយ
GRI 205-2: ការទំនាក់ទំនង និងការបណ្តុះបណ្តាលអំពីគោលនយោបាយ និងនីតិវិធីនៃអំពើពុករលួយ
GRI 205-3: ឧប្បត្តិហេតុនៃអំពើពុករលួយ និងសកម្មភាពដែលបានបញ្ចប់
GRI 206-1: សកម្មភាពផ្លូវច្បាប់ទៅលើសកម្មភាពប្រឆាំង នឹងការប្រកួតប្រជែង ការជម្រុញឱ្យមានភាពប្រកួតប្រជែង និងឯកាធិភាព

ការប្រឆាំងអំពើពុករលួយ

ក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ មិនមានករណីផ្លូវច្បាប់ ដែលទាក់ទងនឹងអំពើពុករលួយត្រូវបានប្តឹងប្រឆាំងនឹងធនាគារARDB ឬបុគ្គលិករបស់ខ្លួនឡើយ។ ករណីបែបនេះ បានបញ្ជាក់យ៉ាងច្បាស់អំពីការប្តេជ្ញាចិត្តរបស់ធនាគារ ARDB ចំពោះការអនុវត្តប្រកបដោយក្រមសីលធម៌ និងអនុលោមភាពតាមច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

ទំនាស់ផលប្រយោជន៍

ធនាគារARDB បានប្តេជ្ញាថាធនាគារត្រូវតែគ្រប់គ្រងទំនាស់ផលប្រយោជន៍ឱ្យបានល្អ ទាំងខាងក្នុងធនាគារ និងជាមួយអតិថិជនរបស់ធនាគារ។ ការអនុវត្តប្រកបដោយភាពស្មោះត្រង់និងក្រមសីលធម៌ដោយបុគ្គលពាក់ព័ន្ធនឹងធនាគារ ARDB គឺជាមូលដ្ឋានដ៏សំខាន់ដើម្បីគាំទ្រដល់បេសកកម្ម និងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ។បុគ្គលិកទាំងអស់ត្រូវបានរំពឹងថានឹងបំពេញតួនាទីភារកិច្ចនិងទំនួលខុសត្រូវរបស់ពួកគេប្រកបដោយសុចរិតភាព និងភាពស្មោះត្រង់ខ្ពស់បំផុតគ្រប់ពេលវេលាព្រមទាំងធានាថាពួកគេជៀសវាងរាល់ទំនាស់ផលប្រយោជន៍ដែលអាចកើតមានឡើង។ ក្រមសីលធម៌វិជ្ជាជីវៈសម្រាប់និយោជិតរបស់ធនគារ ARDB ក៏បានបង្ហាញអំពីកាលៈទេសៈដែលអាចបង្កឱ្យមានទំនាស់ផលប្រយោជន៍ដូចជា÷ ការផ្តល់ និងទទួលអត្ថប្រយោជន៍ អំណោយ ប្រើប្រាស់សេវាសម្ភារៈ ឬបរិក្ខារបស់ធនាគារARDB សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួនជាដើម។

ការបណ្តុះបណ្តាលស្តីពីអំពើពុករលួយ

ដើម្បីពង្រឹងការប្តេជ្ញាចិត្តរបស់ធនាគារ ARDB ចំពោះឧត្តមភាពនៃក្រមសីលធម៌ នាយកដ្ឋានធនធានមនុស្សបានរួមបញ្ចូលវគ្គបណ្តុះបណ្តាលស្តីពីក្រមសីលធម៌ក្នុងអំឡុងពេលតម្រង់ទិសបុគ្គលិកថ្មី។ ដើម្បីធានាថាបុគ្គលិកទាំងអស់ទទួលបាននិងយល់ដឹងអំពីអាកប្បកិរិយាប្រកបដោយក្រមសីលធម៌និងទំនាស់ផលប្រយោជន៍។ ចំណេះដឹងជាមូលដ្ឋាននេះ ត្រូវបានពង្រឹងបន្ថែមតាមរយៈកម្មវិធីចែករំលែកពាក់ព័ន្ធកិច្ចការធនធានមនុស្ស(HR Talks) ដែលគោលការណ៍សំខាន់ៗត្រូវបានពិនិត្យឡើងវិញហើយបុគ្គលិកនឹងត្រូវបានជូនដំណឹងអំពីបច្ចុប្បន្នភាពបទប្បញ្ញត្តិណាមួយ។ តាមរយៈការពង្រឹងគោល-ការណ៍ទាំងនេះជាបន្តបន្ទាប់ ធនាគារ ARDB ធានាថាបុគ្គលិកទាំងអស់នៅតែទទួលបានព័ត៌មានគ្រប់គ្រាន់ ប្រុងប្រយ័ត្ន និងអនុលោមតាមការប្តេជ្ញាចិត្តរបស់ធនាគារចំពោះតម្លាភាព និងការអនុវត្តប្រកបដោយក្រមសីលធម៌ក្នុងអាជីពការងាររបស់ពួកគេជាមួយធនាគារ ARDB។

ការប្រឆាំងការប្រកួតប្រជែងមិនស្មើភាព

ការប្រឆាំងការប្រកួតប្រជែងមិនស្មើភាព និងជំហរឧត្តមភាពលើទីផ្សារ

បច្ចុប្បន្ន មិនមានសកម្មភាព ឬហេតុការណ៍ណាមួយដែលបានកើតឡើង ដែលទាក់ទងនឹងការប្រឆាំងការប្រកួតប្រជែង និងជំហរឧត្តមភាពលើទីផ្សារឡើយ។ ធនាគារARDB ប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកកម្ពស់ តម្លាភាព យុត្តិធម៌ នៃការប្រកួតប្រជែងនៅក្នុងទីផ្សារហើយត្រួតពិនិត្យយ៉ាងម៉ឺងម៉ាត់នូវអនុលោមភាពបទដ្ឋានច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធទាំងអស់។

GRI 205-1: ប្រតិបត្តិការត្រូវបានវាយតម្លៃសម្រាប់ហានិភ័យដែលទាក់ទងនឹងអំពើពុករលួយ
GRI 205-2: ការទំនាក់ទំនង និងការបណ្តុះបណ្តាលអំពីគោលនយោបាយ និងនីតិវិធីនៃអំពើពុករលួយ
GRI 205-3: ឧប្បត្តិហេតុនៃអំពើពុករលួយ និងសកម្មភាពដែលបានបញ្ចប់
GRI 206-1: សកម្មភាពផ្លូវច្បាប់ទៅលើសកម្មភាពប្រឆាំង នឹងការប្រកួតប្រជែង ការជម្រុញឱ្យមានភាពប្រកួតប្រជែងនិងឯកាធិភាព

ភាពចម្រុះ និងឱកាសស្មើគ្នា

ធនាគារ ARDB បានយកចិត្តទុកដាក់លើសមភាពយេនឌ័រ ដោយផ្តល់សិទ្ធិស្មើគ្នាដល់បុគ្គលិកទាំងអស់ក្នុងការបំពេញការងារ និងផ្តល់ឱកាសការងារស្មើគ្នាដោយគ្មានការរើសអើង។ លើសពីនេះទៅទៀត ពីមួយឆ្នាំទៅមួយឆ្នាំ ធនាគារARDB មានការរីកចម្រើនជាលំដាប់ ហើយចំនួនបុគ្គលិកបានកើនឡើងគួរឱ្យកត់សម្គាល់ ជាពិសេសចំនួនបុគ្គលិកស្ត្រី។ ធនាគារ ARDB តែងតែផ្តល់ឱកាសដល់បុគ្គលិកទាំងអស់ដែលមានស្នាដៃ និងគុណសម្បត្តិដោយមិនគិតពីយេនឌ័រឡើយ។

ភាពចម្រុះនៃគណៈ:ត្រប់ត្រង និងបុគ្គលិក

ភាគរយ (%)នៃបុគ្គលក្នុងត្រប់ត្រង និងក្រុមបុគ្គលិកនៅក្នុងប្រភេទភាពចម្រុះនីមួយៗដូចខាងក្រោម:

គណៈគ្រប់គ្រងជាន់ខ្ពស់				
អាយុ-ភេទ	គណៈគ្រប់គ្រង (អគ្គនាយក-អគ្គនាយករង)		ថ្នាក់នាយកដ្ឋាន (ប្រធាននាយកដ្ឋាន-អនុប្រធាននាយកដ្ឋាន)	
	បុរស	ស្ត្រី	បុរស	ស្ត្រី
ក្រោមអាយុ៣០ឆ្នាំ	0%	0%	២%	៥%
អាយុ៣០ ដល់ ៥០ឆ្នាំ	0%	0%	៥៤%	២១%
អាយុលើស៥០ឆ្នាំ	១00%	0%	១៥%	៣%
សរុប	១00%	0%	៧0%	៣0%
បុគ្គលិកទូទៅ				
អាយុ-ភេទ	ថ្នាក់ការិយាល័យ (ប្រធានការិយាល័យ-អនុប្រធានការិយាល័យ)		ថ្នាក់បុគ្គលិក (បុគ្គលិកជាន់ខ្ពស់, បុគ្គលិក, ជំនួយការ)	
	បុរស	ស្ត្រី	បុរស	ស្ត្រី
ក្រោមអាយុ៣០ឆ្នាំ	៨%	២៥%	៣២%	១៩%
អាយុ៣០ ដល់ ៥០ឆ្នាំ	៤៧%	១៩%	៣៣%	១៥%
អាយុលើស៥០ឆ្នាំ	២%	0%	១%	១%
សរុប	៥៦%	៤៤%	៦៦%	៣៤%

សមាមាត្រនៃប្រាក់ខែគោល និងអត្ថប្រយោជន៍តាមភេទ

- សមាមាត្រប្រាក់ខែគោល និងអត្ថប្រយោជន៍របស់ស្ត្រី ធៀបនឹងបុរស សម្រាប់ប្រភេទបុគ្គលិកនីមួយៗ តាមតំបន់ប្រតិបត្តិការសំខាន់ៗ។

ធនាគារ ARDB តែងតែថែទាំ និងយកចិត្តទុកដាក់ចំពោះបុគ្គលិកទាំងអស់ មិនថាជាបុរស ឬស្ត្រី។ បន្ថែមពីនេះ ធនាគារ ARDB បានពិចារណាយ៉ាងម៉ត់ចត់អំពីអត្ថប្រយោជន៍របស់បុគ្គលិក ដូចជា ប្រាក់ខែ និងប្រាក់ឧបត្ថម្ភផ្សេងៗ ដើម្បីលើកទឹកចិត្ត និងបង្ហាញពីការថែទាំរបស់ធនាគារ ARDB ចំពោះបុគ្គលិក។

សមាមាត្រប្រាក់ខែគោលតាមភេទ (ស្ត្រី ធៀបនឹងបុរស)		
ថ្នាក់នាយកដ្ឋាន (ប្រធាននាយកដ្ឋាន- អនុប្រធាននាយកដ្ឋាន)	ថ្នាក់ការិយាល័យ (ប្រធានការិយាល័យ- អនុប្រប្រធានការិយាល័យ)	ថ្នាក់បុគ្គលិក (បុគ្គលិកជាន់ខ្ពស់, បុគ្គលិក, ជំនួយការ)
០.៨៨	០.៨០	១.០០

និយោជិកផ្នែកសន្តិសុខ,អនាម័យ និងអ្នកបើកបរ

សមាមាត្រប្រាក់ខែគោល តាមភេទ (ស្ត្រី ធៀបនឹងបុរស)
និយោជិក (ផ្នែកសន្តិសុខ,ផ្នែកបើកបរ, ផ្នែកសម្អាត)
០.៧៨

និយោជិក (ផ្នែកសន្តិសុខ,ផ្នែកបើកបរ, ផ្នែកសម្អាត)		
អាយុ-ភេទ	បុរស	ស្ត្រី
ក្រោមអាយុ៣០ឆ្នាំ	២៦%	៦%
អាយុ៣០ ដល់ ៥០ឆ្នាំ	៣៨%	១៩%
អាយុលើស៥០ឆ្នាំ	៩%	២%
សរុប	៧២%	២៨%

សុខភាព និងសុវត្ថិភាពការងារ

ក្នុងនាមជាធនាគារពាណិជ្ជ និងជាគោលនយោបាយឈានមុខមួយ ដែលបានប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកម្ពុជា ធនាគារធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានផ្តល់អាទិភាពខ្ពស់ដល់សុខភាព សុវត្ថិភាព និងសុខុមាលភាពរបស់បុគ្គលិក និងដៃគូ។ ដើម្បីការពារសុខុមាលភាពបុគ្គលិក ធនាគារ ARDB បានផ្តល់ការទទួលបានសេវាសុខភាពការងារ និងការពិគ្រោះជំងឺ តាមរយៈការធានារ៉ាប់រងសុខភាពពី (Figtree Blue-Forte) ការធានារ៉ាប់រងអាយុជីវិតពី (Manulife) និងមូលនិធិសន្តិសុខសង្គមជាតិ (NSSF)។

ក្របខណ្ឌសុខភាព និងសុវត្ថិភាពការងារ របស់ធនាគារ ARDB អនុវត្តតាមស្តង់ដារGRI 403 និងរួមបញ្ចូលច្បាប់ការងារកម្ពុជាដែលកំណត់ដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ព្រមទាំងផែនទីបង្ហាញផ្លូវស្តីពីការគ្របដណ្តប់សុខភាពជាសកលសម្រាប់ឆ្នាំ ២០២៤-២០៣៥ ដែលជាការប្តេជ្ញារួមរបស់សមាជិកនៃអង្គការសុខភាពពិភពលោក។ លើសពីនេះធនាគារARDB ក៏បានសម្របសម្រួលក្របខណ្ឌ សុខភាព និងសុវត្ថិភាពការងារ របស់ខ្លួនឱ្យស្របតាមយុទ្ធសាស្ត្រដែលបានកំណត់ក្នុងផែនការរបស់អភិបាលកិច្ចសុវត្ថិភាព និងសុខភាពការងារលើកទី ៣ របស់កម្ពុជា (២០២៣-២០២៧)។ វិធីសាស្ត្រនេះធានាថាមានការប្តេជ្ញាជ័ទូលំទូលាយក្នុងការការពារបុគ្គលិក ព្រមទាំងរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ។

ការគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ

ការគ្រប់គ្រងសុខភាព និងសុវត្ថិភាពត្រូវបានត្រួតពិនិត្យដោយផ្នែកធនធានមនុស្សរបស់ធនាគារ ARDB ដែលមានតួនាទីសកម្មក្នុងការកំណត់អត្តសញ្ញាណកាត់បន្ថយ និងតាមដានហានិភ័យនៅកន្លែងធ្វើការ។ ដោយបានអនុវត្តតាមច្បាប់ និងគោលនយោបាយការងារនៃកម្ពុជា ដោយធានាបរិយាកាសការងារមានសុវត្ថិភាព និងអនាម័យតាមរយៈការត្រួតពិនិត្យជាប្រចាំ និងការត្រួតពិនិត្យការអនុលោមភាពដើម្បីរក្សាស្តង់ដារសុវត្ថិភាពខ្ពស់ការវាយតម្លៃហានិភ័យទៅលើប្រតិបត្តិការទាំងអស់វិធានការឆ្លើយតបបន្ទាន់ដែលមានប្រសិទ្ធភាព និងយន្តការតាមដានសុខភាពបុគ្គលិក។

ការសម្គាល់គ្រោះថ្នាក់ ការវាយតម្លៃហានិភ័យ ការត្រួតពិនិត្យលើខ្លឹមប្បត្តិហេតុ

ការកំណត់អត្តសញ្ញាណគ្រោះថ្នាក់ និងការគ្រប់គ្រងហានិភ័យ គឺជាផ្នែកសំខាន់នៃយុទ្ធសាស្ត្រសុខភាព និងសុវត្ថិភាពការងាររបស់យើង។ ធនាគារ ARDB មានគោលបំណងកាត់បន្ថយគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការងារឱ្យនៅកម្រិតទាបបំផុត និងគ្រប់គ្រងហានិភ័យដែលពាក់ព័ន្ធ ដោយធានាការវាយតម្លៃហានិភ័យជាប្រចាំ ការកំណត់អត្តសញ្ញាណគ្រោះថ្នាក់យ៉ាងម៉ត់ចត់ និងការស៊ើបអង្កេតចំពោះហេតុការណ៍នៅកន្លែងធ្វើការ និងពេលធ្វើដំណើរ។

ផ្នែកធនធានមនុស្សមានតួនាទីក្នុងការតាមដាន និងរាយការណ៍អំពីគ្រោះថ្នាក់ ធ្វើការវិភាគហេតុការណ៍ដើម្បីកំណត់មូលហេតុដើម និងអនុវត្តវិធានការកែតម្រូវ ព្រមទាំងគ្រប់គ្រងនីតិវិធី និងគោលការណ៍គ្រប់គ្រងហានិភ័យ។

សេវាសុខភាពការងារ (Occupational Health Services)

ដើម្បីការពារសុខុមាលភាពបុគ្គលិករបស់ធនាគារ ARDB បានផ្តល់ការទទួលបានសេវាសុខភាពការងារ និងការពិគ្រោះវេជ្ជសាស្ត្រ តាមរយៈគោលនយោបាយធានារ៉ាប់រងសុខភាពពី (Figtree Blue-Forte) និងការធានារ៉ាប់រងអាយុជីវិតពី (Manulife)។ ដោយអនុវត្តតាមច្បាប់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បុគ្គលិកទាំងអស់ត្រូវបានចុះឈ្មោះក្នុងមូលនិធិសន្តិសុខសង្គមទាំងផ្នែកសោធននិវត្តន៍ និងសុខភាព ដែលសរុបបុគ្គលិកចំនួន ៣៣៦ នាក់ក្នុងឆ្នាំ ២០២៤ និង ៣៩៩ នាក់ក្នុងឆ្នាំ ២០២៥។ សេវាទាំងនេះត្រូវបានគ្រប់គ្រងដោយរក្សាការសម្ងាត់យ៉ាងតឹងរឹង ស្របតាមស្តង់ដារការងារកម្ពុជា ដើម្បីធានាការការពារឯកជនភាពព័ត៌មានសុខភាពផ្ទាល់ខ្លួន និងការចូលរួមរបស់បុគ្គលិក។

GRI 403: សុខភាព និងសុវត្ថិភាពការងារ
GRI 403-1: ប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាព
GRI 403-2: ការកំណត់អត្តសញ្ញាណគ្រោះថ្នាក់ ការវាយតម្លៃហានិភ័យ និងការស៊ើបអង្កេតឧប្បត្តិហេតុ
GRI 403-3: សេវាសុខភាពការងារ

ចំនួនបុគ្គលិកសរុបទាមទារសំណងធានារ៉ាប់រង÷

ប្រភេទធានារ៉ាប់រង	បរិយាយ	២០២៤	២០២៥
ធានារ៉ាប់រងសុខភាព	ចំនួនបុគ្គលិកដែលទទួលបានអត្ថប្រយោជន៍	៣៧៩	៣៩៩
	ចំនួនទាមទារសំណងធានារ៉ាប់រង	៣៦៦	៣៧០
	កញ្ចប់ពិនិត្យសុខភាពទូទៅ	១២១	១៩
	ករណីគ្រោះថ្នាក់	២៤៥	៣៥១
ធានារ៉ាប់រងអាយុជីវិត	ចំនួនបុគ្គលិកដែលទទួលបានអត្ថប្រយោជន៍	៣៧១	៣៩៩
	ករណីរុះកាត់	0	0

ការចូលរួមរបស់បុគ្គលិក ការពិគ្រោះយោបល់ និងការទំនាក់ទំនងស្តីពីសុខភាព និងសុវត្ថិភាពការងារ

ធនាគារ ARDB ធានាការចូលរួមយ៉ាងសកម្មរបស់បុគ្គលិកក្នុងវិស័យសុខភាព និងសុវត្ថិភាពការងារ (OHS) តាមរយៈគណៈកម្មាធិការសុខភាពនិងកម្មវិធី HR Talks ដែលបានបង្កើតឡើង។ គណៈកម្មាធិការនេះរួមមានតំណាងពីថ្នាក់គ្រប់គ្រង និងតំណាងបុគ្គលិក ហើយប្រជុំជាប្រចាំដើម្បីពិនិត្យគំនិតផ្តួចផ្តើមក្នុងការកែលម្អសុវត្ថិភាព និងដោះស្រាយបញ្ហាបារម្ភរបស់បុគ្គលិក។ កម្មវិធី HR Talks ជួយជំរុញការចូលរួមរបស់បុគ្គលិកក្នុងការពិភាក្សា និងការពិគ្រោះយោបល់អំពីសុខភាព។ លើសពីនេះ ធនាគារ ARDB ក៏លើកទឹកចិត្តដល់សកម្មភាពមនុស្សធម៌ ដោយបុគ្គលិកបានចូលរួមបរិច្ចាគប្រាក់ប្រចាំខែដោយស្ម័គ្រចិត្តទៅមូលនិធិគន្ធបុប្ផា។ វិធីសាស្ត្រសហការនេះគាំទ្រដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG 8 និងយុទ្ធសាស្ត្រទី IV នៃផែនការសុខភាព និងសុវត្ថិភាពការងារ ។

ឆ្នាំ	ចំនួនបុគ្គលិក	ចំនួនទឹកប្រាក់
២០២៤	៣៧៩	១៧,៩៧៦ ដុល្លារអាម៉េរិក
២០២៥	៣៩០	១៩,៨១៨ ដុល្លារអាម៉េរិក

ការបណ្តុះបណ្តាលបុគ្គលិកស្តីពីសុខភាព និងសុវត្ថិភាពការងារ

ការបណ្តុះបណ្តាលសុខភាព និងសុវត្ថិភាពការងារជាប្រចាំ គឺជាផ្នែកសំខាន់នៃការប្តេជ្ញាចិត្តរបស់ធនាគារ ARDB ចំពោះសុវត្ថិភាពបុគ្គលិក។ ផ្នែកធនធានមនុស្សរៀបចំកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំដែលត្រូវបានកែសម្រួលឱ្យសមស្រប ដោយរួមបញ្ចូលការយល់ដឹងអំពីគ្រោះថ្នាក់ វិធីការពារសុវត្ថិភាព ការត្រៀមខ្លួនបន្ទាន់ និងជំនួយបឋមការស្គាល់បញ្ហាសុខភាពផ្លូវចិត្ត និងការបង្ការជំងឺ។ កម្មវិធីទាំងនេះត្រូវបានផ្តល់ជាភាសាខ្មែរ និងអង់គ្លេស ដើម្បីធានាថាបុគ្គលិកទាំងអស់អាចចូលរួម និងយល់ដឹងបានយ៉ាងពេញលេញ។

GRI 403: សុខភាពនិងសុវត្ថិភាពការងារ
GRI 403-4: ការចូលរួម ការពិគ្រោះយោបល់ និងការទំនាក់ទំនងរបស់បុគ្គលិក លើសុខភាព និងសុវត្ថិភាពការងារ
GRI 403-5: វគ្គបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារ

ការលើកកម្ពស់សុខភាពបុគ្គលិក

គណៈកម្មាធិការសុខភាពរបស់ធនាគារ និងផ្នែកធនធានមនុស្ស បានរៀបចំយុទ្ធនាការលើកកម្ពស់ការយល់ដឹង និងការចូលរួមជាប្រចាំ ដើម្បីជំរុញសុខភាព និងសុខុមាលភាពទូទៅ ព្រមទាំងផ្តល់សេវាប្រឹក្សាយោបល់នៅកន្លែងធ្វើការ។ ក៏បានអនុវត្តកម្មវិធីសុខុមាលភាពផ្សេងៗដែលរួមមានការត្រួតពិនិត្យសុខភាពបង្ការ សិទ្ធិឈប់សម្រាកពិសេស និងសិក្ខាសាលាស្តីពីសុខភាពស្ត្រី។

ការបង្ការ និងកាត់បន្ថយផលប៉ះពាល់សុខភាព និងសុវត្ថិភាពការងារ

ធនាគារ ARDB បានពង្រីកវិធានការសុវត្ថិភាពរបស់ខ្លួនទៅកាន់បុគ្គលិក និងដៃគូអាជីវកម្ម ដោយតម្រូវឱ្យអនុវត្តតាមស្តង់ដារសុខភាព និងសុវត្ថិភាពការងារ ដែលបានកំណត់ក្នុងមាត្រា ២៣០ នៃច្បាប់ការងារកម្ពុជា។ ដើម្បីបង្ការ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានផ្នែកសុខភាព និងសុវត្ថិភាពការងាររបស់បុគ្គលិករបស់ធនាគារ ARDB ដែលកំពុងអនុវត្តលក្ខខណ្ឌ សុវត្ថិភាពការងារក្នុងកិច្ចសន្យាសម្រាប់ដៃគូនិងធ្វើការវាយតម្លៃជាប្រចាំដើម្បីកំណត់និងដោះស្រាយចន្លោះប្រហោងផ្នែកសុវត្ថិភាពស្របតាមមាត្រា ៥៦ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ មុនពេលបង្កើតទំនាក់ទំនងអាជីវកម្ម។

បុគ្គលិកដែលស្ថិតក្រោមប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ

ប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ បានគ្របដណ្តប់យ៉ាងពេញលេញលើបុគ្គលិក បុគ្គលិកបណ្តោះអាសន្ន និងបុគ្គលិកផ្សេងៗទាំងអស់ ដែលស្ថិតក្រោមការគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារ ARDB។ តាមរយៈការផ្សព្វផ្សាយគោលនយោបាយសុវត្ថិភាពជាប្រចាំ និងការត្រួតពិនិត្យការអនុលោមតាម យើងធានាថាបុគ្គលិក និងកម្មករទាំងអស់ទទួលបានអត្ថប្រយោជន៍ពីបរិយាកាសការងារដែលមានសុវត្ថិភាព។

របួសដែលពាក់ព័ន្ធនឹងការងារ

ធនាគារARDB បានរក្សាទុកកំណត់ត្រាលម្អិតអំពីរបួសទាំងអស់ដែលពាក់ព័ន្ធនឹងការងារ និងអនុវត្តតាមច្បាប់ការងារកម្ពុជាដោយរាយការណ៍ហេតុការណ៍ធ្ងន់ធ្ងរទៅកាន់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។ដោយប្រើប្រាស់ទិន្នន័យទាំងនេះ យើងអនុវត្តវិធានការជាក់លាក់ដើម្បីកាត់បន្ថយអត្រារបួសដោយគាំទ្រយុទ្ធសាស្ត្រទី III នៃផែនការ សុខភាព និងសុវត្ថភាពការងារតាមរយៈការតាមដាននិងវិភាគទិន្នន័យរបួសយ៉ាងលម្អិតសម្រាប់វិធានការបង្ការនិងគាំទ្រគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG 3 តាមរយៈការកែលម្អសុវត្ថិភាពកន្លែងធ្វើការ និងការកាត់បន្ថយហានិភ័យសុខភាព។

ជំងឺដែលពាក់ព័ន្ធនឹងការងារ

ករណីជំងឺដែលពាក់ព័ន្ធនឹងការងារ ត្រូវបានតាមដាន និងដោះស្រាយយ៉ាងឆាប់រហ័ស ដើម្បីបង្ការការកើតឡើងបន្ថែម។ ធនាគារ ARDB សហការជាមួយអ្នកផ្តល់សេវាសុខាភិបាល តាមរយៈក្រុមហ៊ុនធានារ៉ាប់រង ដើម្បីគាំទ្របុគ្គលិកដែលរងផលប៉ះពាល់ និងធានាការស្តារសុខភាពឡើងវិញ។ វិធានការទាំងនេះស្របតាមយុទ្ធសាស្ត្រទី VI នៃផែនការ សុខភាព និងសុវត្ថិភាពការងារដែលផ្តោតលើការដោះស្រាយបញ្ហាសុខភាពនៅកន្លែងការងារ តាមរយៈការផ្តល់កម្មវិធីបង្ការ និងគាំទ្រគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព SDG 3 ដោយធានាការទទួលបានសេវាសុខភាពការងារប្រកបដោយគុណភាព។

GRI 403-6: ការលើកកម្ពស់សុខភាពបុគ្គលិក
GRI 403-7: ការការពារ និងកាត់បន្ថយផលប៉ះពាល់សុខភាព និងសុវត្ថិភាពការងារ
GRI 403-8: បុគ្គលិកដែលគ្របដណ្តប់ដោយប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ
GRI 403-9: របួសទាក់ទងនឹងការងារ
GRI 403-10: ជំងឺដែលពាក់ព័ន្ធនឹងការងារ

អត្ថប្រយោជន៍ឈប់សម្រាកពិសេស និងគោលការណ៍គាំទ្រគ្រួសារ

ដើម្បីគាំទ្របន្ថែមដល់សុខុមាលភាពបុគ្គលិក និងតុល្យភាពរវាងការងារ និងជីវិតផ្ទាល់ខ្លួន ធនាគារ ARDB បានផ្តល់អត្ថប្រយោជន៍ជាច្រើន ដែលត្រូវបានរៀបចំឱ្យសមស្របទៅនឹងតម្រូវការរបស់បុគ្គលិកដែលមានភាពចម្រុះដូចជា÷

- **អត្ថប្រយោជន៍ និងច្បាប់ឈប់សម្រាក់ពិសេសសម្រាប់បុគ្គលិកស្ត្រី÷** បុគ្គលិកស្ត្រីមានសិទ្ធិទទួលបានការឈប់សម្រាកបន្ថែមដែលទាក់ទងនឹងសុខភាព ដែលសមស្របនឹងតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ រួមទាំងអំឡុងពេលសម្រាក់លំហែមាតុភាពឬពេលមានបញ្ហាសុខភាពក្នុងអំឡុងពេលមានផ្ទៃពោះ។ក្រៅពីទទួលបានបៀវត្ស៣ខែពេញក្នុងអំឡុងពេលឈប់សម្រាកលំហែមាតុភាព បុគ្គលិកស្ត្រីក៏ទទួលបានប្រាក់ឧបត្ថម្ភផ្សេងៗបន្ថែមទៀតផងដែរ។

- **ច្បាប់ឈប់សម្រាកថែទាំកូន÷** ទាំងម្តាយ និងឪពុកទទួលបានសិទ្ធិឈប់សម្រាក ដើម្បីមើលថែទារកដែលទើបនឹងកើត។ សម្រាប់ឪពុក ត្រូវបានលើកទឹកចិត្តឱ្យឈប់សម្រាក ដែលហៅថាការសម្រាកបិតុភាព ស្របតាមគោល-នយោបាយរបស់ធនាគារក្នុងការលើកកម្ពស់សមភាពយេនឌ័រ។

- **អត្ថប្រយោជន៍នៃច្បាប់ឈប់សម្រាកពិសេសផ្សេងៗ÷** ធនាគារ ARDB ផ្តល់អត្ថប្រយោជន៍ឈប់សម្រាកស្តង់ដារ ដែលរួមមាន ឈប់សម្រាកប្រចាំឆ្នាំ១.៥ថ្ងៃក្នុងមួយខែ ឈប់សម្រាកពេលឈឺ ឈប់សម្រាកពិសេស ៧ថ្ងៃក្នុងមួយឆ្នាំ ឈប់សម្រាកមាតុភាព ៩០ ថ្ងៃ ថ្ងៃឈប់សម្រាកចុងសប្តាហ៍ ថ្ងៃឈប់សម្រាកបុណ្យសាធារណៈ និងការឈប់សម្រាកមានប្រាក់ឈ្នួល ដើម្បីធានាថាបុគ្គលិកមានភាពបត់បែនក្នុងការដោះស្រាយតម្រូវការផ្ទាល់ខ្លួន និងគ្រួសារ។ សមតុល្យថ្ងៃឈប់សម្រាកដែលនៅសល់នៅចុងឆ្នាំ នឹងត្រូវបង់ជូនបុគ្គលិកវិញ ដោយគណនាតាមប្រាក់ខែគោល។ បន្ថែមពីនេះ បុគ្គលិកដែលទទួលអាហារូបករណ៍ពេញលេញនៅក្រៅប្រទេស ត្រូវបានអនុញ្ញាតឱ្យទទួលបាន ៥០% នៃប្រាក់ខែ ដើម្បីបន្តការសិក្សារបស់ខ្លួន។

- **សិទ្ធិពិសេសសម្រាប់ស្ត្រីមានផ្ទៃពោះនិងម្តាយបំបៅកូន÷** បុគ្គលិកស្ត្រីត្រូវបានអនុញ្ញាតឱ្យមានពេលសម្រាក១ម៉ោងដើម្បីបំបៅទារក រហូតដល់កូនមានអាយុ ១ ឆ្នាំ។

- **អត្ថប្រយោជន៍នៃច្បាប់ឈប់សម្រាកពិសេសផ្សេងៗ÷** ធនាគារ ARDB ផ្តល់អត្ថប្រយោជន៍ឈប់សម្រាកដែលមានស្តង់ដារ រួមមាន÷ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ច្បាប់ឈប់សម្រាកពេលមានជំងឺ និងច្បាប់ឈប់សម្រាកពិសេស ដើម្បីធានាថាបុគ្គលិក អាចមានពេលវេលាគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាផ្ទាល់ខ្លួន និងគ្រួសារ។ សមតុល្យនៃចំនួនថ្ងៃនៃច្បាប់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ នៅចុងឆ្នាំនឹងត្រូវទូទាត់ជាថវិកាជូនបុគ្គលិកវិញ ដោយយកបៀវត្សមូលដ្ឋានមកគណនា។ សម្រាប់បុគ្គលិក ដែលទទួលបានអាហារូបករណ៍ពេញទៅសិក្សានៅក្រៅប្រទេស ត្រូវបានផ្តល់នូវបៀវត្សប្រចាំខែ ៥០% នៃបៀវត្សមូលដ្ឋានខែចុងក្រោយ ដើម្បីបន្តការសិក្សារបស់ពួកគេ។

GRI 403-7: ការការពារ និងកាត់បន្ថយផលប៉ះពាល់សុខភាពនិងសុវត្ថិភាពការងារ
GRI 403-8: បុគ្គលិកដែលគ្របដណ្តប់ដោយប្រព័ន្ធគ្រប់គ្រងសុខភាពនិងសុវត្ថិភាពការងារ
GRI 403-9: របួសទាក់ទងនឹងការងារ
GRI 403-10: គ្រោះថ្នាក់សុខភាព

ទំនួលខុសត្រូវផ្លែកសង្គម

ការងារ

ចំនួនសរុបនៃនិយោជិកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ចែកតាមភេទ÷

ចំនួនសរុបនៃនិយោជិកធនាគារ ARDB បែងចែកតាមភេទ	
២០២៥ ពេញម៉ោង	
ស្ត្រី	១៤១
បុរស	២៥៨
សរុប	៣៩៩

ចំនួនសរុបនៃនិយោជិកធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បែងចែកតាមភេទ និងក្រុមអាយុ

ក្រុមអាយុ	ស្ត្រី	បុរស	គិតជាភាគរយ
អាយុក្រោម៣០ឆ្នាំ	៦៨	៧៥	៣៦%
អាយុ៣០-៥០ឆ្នាំ	៦៩	១៦៣	៥៨%
អាយុលើស៥០ឆ្នាំ	៤	២០	៦%
សរុប	១៤១	២៥៨	១០០%

ការជ្រើសរើសនយោបិកថ្មី និងការផ្លាស់ប្តូរនយោបិក

នៅចុងរយៈពេលរាយការណ៍ ធនាគារ ARDB បានជួលបុគ្គលិកថ្មីចំនួន ៣៨នាក់ ដែលស្មើនឹង ១០% នៃចំនួនបុគ្គលិកសរុប។ កំណើននេះកើតឡើងដោយសារការអភិវឌ្ឍរបស់ធនាគារ ARDB ដែលធ្វើឱ្យប្រតិបត្តិការរបស់ធនាគារកើនឡើង ហើយត្រូវការបុគ្គលិកបន្ថែមជាច្រើន។ អត្រាផ្លាស់ប្តូរបុគ្គលិកសរុបមានចំនួន ១៩ នាក់ ឬ ៤.៥៥% នៃកម្លាំងពលកម្មសរុប ដោយមូលហេតុរួមមានការចាកចេញទៅបង្កើតអាជីវកម្មផ្ទាល់ខ្លួនការស្វែងរកបទពិសោធន៍ការងារថ្មីៗនិងការឈប់សម្រាកដើម្បីមើលថែទាំកូន។លទ្ធផលនេះបង្ហាញពីការរក្សាបុគ្គលិកបានល្អនិងការគ្រប់គ្រងកម្លាំងពលកម្មប្រកបដោយប្រសិទ្ធភាព។អត្រាប្តូរទាបនេះក៏បង្ហាញថាធនាគារARDB បានផ្តល់បរិយាកាសការងារដែលមានស្ថិរភាពនិងការគាំទ្រល្អដែលមានសារៈសំខាន់នៅពេលអង្គការកំពុងពង្រីកខ្លួន។ ទោះជាយ៉ាងណា ចំនួនបុគ្គលិកថ្មីបុរស (២១ នាក់) ខ្ពស់ជាងបុគ្គលិកស្ត្រីមានត្រឹម (១៧ នាក់) ដែលបង្ហាញថាធនាគារ ARDB នៅមានឱកាសក្នុងការពង្រឹងភាពស្មើភេទក្នុងកម្លាំងពលកម្ម។ តាមរយៈការលើកកម្ពស់ដំណើរការជ្រើសរើសបុគ្គលិកដែលមានលក្ខណៈរួមបញ្ចូលកាន់តែច្រើន ធនាគារARDB អាចធានាបាននូវការតំណាងធនធានមនុស្ស ដែលមានតុល្យភាពដែលនឹងជំរុញការច្នៃប្រឌិត និងឆ្លុះបញ្ចាំងកាន់តែច្បាស់ពីសហគមន៍ដែលធនាគារបម្រើ។ អត្រា និងចំនួនបុគ្គលិកថ្មី និងការប្តូរបុគ្គលិកត្រូវបានបង្ហាញក្នុងតារាងខាងក្រោម។

GRI 2-7: បុគ្គលិក
GRI 401-1: ការជួលបុគ្គលិក និងការផ្លាស់ប្តូរបុគ្គលិក

ការជ្រើសរើសបុគ្គលិកថ្មីតាមក្រុមអាយុ និងភេទ

ក្រុមអាយុ	ស្ត្រី		បុរស		សរុប	
អាយុក្រោម៣០ឆ្នាំ	១១	៦៥%	៩	៤៣%	២០	៥៣%
អាយុ៣០-៥០ឆ្នាំ	៦	៣៥%	១១	៥២%	១៧	៤៥%
អាយុលើស៥០ឆ្នាំ	០	០%	១	៥%	១	៣%
សរុប	១៧	១០០%	២១	១០០%	៣៨	១០០%

ការជ្រើសរើសនយោជិកថ្មីតាមតំបន់

តំបន់	ចំនួនជ្រើសរើសបុគ្គលិកថ្មី
ភ្នំពេញ	៣៤
កំពង់ស្ពឺ	១
បាត់ដំបង	១
ស្វាយរៀង	១
តាកែវ	១
សរុប	៣៨

ការផ្លាស់ប្តូរនយោជិកតាមក្រុមអាយុ និងភេទ

ក្រុមអាយុ	ស្ត្រី		បុរស		សរុប	
អាយុក្រោម៣០ឆ្នាំ	៦	៨៦%	៣	២៥%	៩	៤៧%
អាយុ៣០-៥០ឆ្នាំ	១	១៤%	៨	៦៧%	៩	៤៧%
អាយុលើស៥០ឆ្នាំ	០	០%	១	៨%	១	៥%
សរុប	៧	១០០%	១២	១០០%	១៩	១០០%

ការផ្លាស់ប្តូរនយោជិកតាមតំបន់

តំបន់	ចំនួនការផ្លាស់ប្តូរបុគ្គលិក
ភ្នំពេញ	១៥
តាកែវ	១
ស្ទឹងត្រែង	១
បាត់ដំបង	១
កំពង់ឆ្នាំង	១
សរុប	១៩

GRI 2-7: បុគ្គលិក
GRI 401-1: ការជួលបុគ្គលិក និងការផ្លាស់ប្តូរបុគ្គលិក

អត្ថប្រយោជន៍ការងារ

និយោជិកធ្វើការពេញម៉ោងទាំងអស់នៅធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម មានសិទ្ធទទួលបានអត្ថប្រយោជន៍ជាច្រើនដូចខាងក្រោម÷



GRI 201-3: កាតព្វកិច្ចផែនការអត្ថប្រយោជន៍ដែលបានកំណត់និងផែនការចូលនិវត្តន៍
GRI 401-2: អត្ថប្រយោជន៍ផ្តល់ជូនដល់និយោជិតពេញម៉ោង ដែលមិនត្រូវបានផ្តល់ជូនសល់និយោជិតបណ្តោះអាសន្ន ឬក្រៅម៉ោង

ច្បាប់មាតុភាព/បិតុភាព

ការឈប់សម្រាកមាតាបិតា (Parental Leave) ត្រូវបានផ្តល់ជូនដល់បុគ្គលិកទាំងបុរស និងស្ត្រី ដោយផ្អែកលើការកើតកូន។

ច្បាប់មាតុភាព/បិតុភាព	ស្ត្រី	បុរស	សរុប
និយោជិកដែលមានសិទ្ធិសុំច្បាស់ មាតុភាព/បិតុភាព	១៤១	២៥៤	៣៩៥
និយោជិកដែលបានប្រើប្រាស់សិទ្ធិសុំច្បាស់ មាតុភាព/បិតុភាព	១០	១១	២១
និយោជិកដែលត្រឡប់មកធ្វើការវិញក្រោយប្រើប្រាស់សិទ្ធិសុំច្បាស់មាតុភាព/បិតុភាព	៧	១១	២១
និយោជិកដែលត្រឡប់មកធ្វើការវិញក្រោយប្រើប្រាស់សិទ្ធិសុំច្បាស់មាតុភាព/បិតុភាព និងនៅបន្តធ្វើការ១២ខែក្រោយត្រឡប់មកធ្វើការ	៧	១១	២១

អត្រាត្រឡប់ទៅធ្វើការវិញ និងអត្រារក្សាទុកនិយោជកិ ក្រោយសម្រាកច្បាប់ថែទាំកូនឈឺបានបញ្ចប់

អត្រាត្រឡប់ទៅធ្វើការ និងអត្រារក្សាទុកនិយោជិក	ស្ត្រី	បុរស	សរុប
អត្រាត្រឡប់មកធ្វើការ	១០០%	១០០%	១០០%
អត្រារក្សាទុកនិយោជិក	១០០%	១០០%	១០០%

ការគ្រប់គ្រងអនុវត្តន៍ការផ្តល់រង្វាន់លើសមត្ថភាពការងារ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) បានបង្កើតគោលនយោបាយធនធានមនុស្ស ដែលរួមមានការគ្រប់គ្រងការអនុវត្តការងារដែលត្រូវបានអនុម័តដោយនាយកប្រតិបត្តិ តាមរយៈសេចក្តីសម្រេចលេខ ០០៤/១៧ ស.រ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ ២០១៧។

នៅឆ្នាំ ២០២២ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានកែសម្រួលនូវការពង្រឹងប្រសិទ្ធភាពការងារឡើងវិញ។ ក្នុងឆ្នាំដដែលធនាគារបានបង្កើតក្រុមការងារ (KPI) ដែលដឹកនាំដោយនាយកប្រតិបត្តិដើម្បីពិនិត្យ និងធ្វើបច្ចុប្បន្នភាពនីតិវិធីនៃការអនុវត្តការងាររបស់បុគ្គលិក។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ធ្វើការវាយតម្លៃការអនុវត្តជាប្រចាំសម្រាប់បុគ្គលិកទាំងអស់ ដោយប្រើសូចនាករការអនុវត្តសំខាន់ៗ (KPI) ដែលបានកំណត់នៅដើមឆ្នាំនីមួយៗ។ សូចនាករការអនុវត្តសំខាន់ៗទាំងនេះ (KPI) រួមបញ្ចូលអាកប្បកិរិយានៃការអនុវត្តបុគ្គល ផ្តោតលើផ្នែកសំខាន់ៗដូចជា ការអនុវត្តផ្នែកហិរញ្ញវត្ថុ ការចូលប្រើប្រាស់របស់អតិថិជន ដំណើរការអាជីវកម្មខាងក្នុង និងការអភិវឌ្ឍ និងការបង្កើនកំណើន។

ដោយផ្អែកលើសមត្ថភាពហិរញ្ញវត្ថុរបស់ធនាគារ និងតម្រូវការរបស់ធនាគារ លទ្ធផលការងារល្អអាចទទួលបានអត្ថប្រយោជន៍ឱកាសឡើងដំណែង និងការអាចចូលក្នុងកម្មវិធីអភិវឌ្ឍន៍ប្រកបដោយវិជ្ជាជីវៈ។

កម្មវិធីគ្រប់គ្រងទេពកោសល្យជាយុទ្ធសាស្ត្រ និងការទទួលបានជំនាញ

ការទទួលបានជំនាញ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម បានបង្កើតគោលនយោបាយ និងនីតិវិធីដ៏ទូលំទូលាយដើម្បីធានាបាននូវការជ្រើសរើសដោយយុត្តិធម៌ និងតម្លាភាព ការអភិវឌ្ឍបុគ្គលិក និងការរួមបញ្ចូលកន្លែងធ្វើការ។ ធនាគារបានប្តេជ្ញាចិត្តក្នុងការលើកកម្ពស់យីហោនិយោជក និងពង្រីកបណ្តាញទេពកោសល្យ និងបណ្តាញវិជ្ជាជីវៈរបស់ខ្លួន ដើម្បីទាក់ទាញ និងរក្សាបាននូវទេពកោសល្យកំពូល។ ធនាគារអភិវឌ្ឍន៍ជនបទ និង កសិកម្ម អនុវត្តគោលការណ៍នៃឱកាសស្មើគ្នាសម្រាប់បុរស និងស្ត្រី ជំរុញការងារចម្រុះនិងរួមបញ្ចូលនិងពង្រឹងដំណើរការជួលដែលមិនរើសអើងដែលផ្តល់អាទិភាពដល់ការជ្រើសរើសដោយយុត្តិធម៌និងផ្អែកលើគុណសម្បត្តិ។ តាមរយៈការរួមបញ្ចូលគោលការណ៍ទាំងនេះ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម កាត់បន្ថយការផ្លាស់ប្តូរជំរុញការបង្កើតថ្មី និងធានានូវនិរន្តរភាពរបស់អង្គការរយៈពេលវែង។

មូលនិធិសោធននិវត្តន៍

ធនាគារ ARDB បានដាក់ឱ្យប្រើប្រាស់មូលនិធិសោធននិវត្តន៍ (Pension Fund) ដែលជាផែនការចូលនិវត្តន៍មួយ ដើម្បីគាំទ្រសុខុមាលភាពរយៈពេលវែងនិងសុវត្ថិភាពហិរញ្ញវត្ថុរបស់បុគ្គលិកដោយទទួលស្គាល់ថាបុគ្គលិកគឺជាទ្រព្យសម្បត្តិសំខាន់បំផុតមួយរបស់ធនាគារ។ គំនិតផ្តួចផ្តើមនេះត្រូវបានបង្កើតឡើង ដើម្បីធានាថាបុគ្គលិកមានការការពារផ្នែកហិរញ្ញវត្ថុបន្ទាប់ពីចូលនិវត្តន៍។

មូលនិធិសោធននិវត្តន៍នេះដើរតួនាទីជាយន្តការសន្សំរយៈពេលវែង ដែលការបរិច្ចាគត្រូវបានប្រមូលផ្តុំក្នុងអំឡុងពេលបុគ្គលិកបម្រើការងារនៅធនាគារ។ មូលនិធិនេះត្រូវបានគ្រប់គ្រង និងវិនិយោគ ដើម្បីបង្កើតប្រាក់ចំណេញ ដែលអាចអនុញ្ញាតឱ្យបុគ្គលិកទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុនៅពេលដល់អាយុចូលនិវត្តន៍។ តាមរយៈកម្មវិធីនេះ ធនាគារ ARDB មានគោលបំណងផ្តល់ប្រភពចំណូលមានស្ថិរភាពសម្រាប់បុគ្គលិកក្នុងអំឡុងពេលចូលនិវត្តន៍។

តាមរយៈការដាក់ឱ្យមានមូលនិធិសោធននិវត្តន៍ ធនាគារ ARDB បង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ចំពោះសុខុមាលភាព ការលើកទឹកចិត្ត និងភាពស្មោះត្រង់របស់បុគ្គលិក។ ផែនការចូលនិវត្តន៍នេះមិនត្រឹមតែជួយបុគ្គលិករៀបចំអនាគតរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ធនាគារចំពោះការគ្រប់គ្រងធនធានមនុស្សប្រកបដោយទំនួលខុសត្រូវ និងការគាំទ្រ។គំនិតផ្តួចផ្តើមនេះរួមចំណែកក្នុងការបង្កើតបរិយាកាសការងារដែលមានសុវត្ថិភាព និងការគាំទ្រខ្ពស់ ព្រមទាំងពង្រឹងតួនាទីរបស់ធនាគារ ARDB ជានិយោជកដែលយកចិត្តទុកដាក់ និងមានទំនួលខុសត្រូវ។

ការបណ្តុះបណ្តាល និងការអប់រំ

ចំនួនម៉ោងបណ្តុះបណ្តាលនិយោជិតជាមធ្យមក្នុងមួយឆ្នាំ

តាមរយៈការដាក់ឱ្យមានមូលនិធិសោធននិវត្តន៍ ធនាគារ ARDB បង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ចំពោះសុខុមាលភាព ការលើកទឹកចិត្ត និងភាពស្មោះត្រង់របស់បុគ្គលិក។ ផែនការចូលនិវត្តន៍នេះមិនត្រឹមតែជួយបុគ្គលិករៀបចំអនាគតរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់ធនាគារចំពោះការគ្រប់គ្រងធនធានមនុស្សប្រកបដោយទំនួលខុសត្រូវ និងការគាំទ្រ។គំនិតផ្តួចផ្តើមនេះរួមចំណែកក្នុងការបង្កើតបរិយាកាសការងារដែលមានសុវត្ថិភាព និងការគាំទ្រខ្ពស់ ព្រមទាំងពង្រឹងតួនាទីរបស់ ARDB ជានិយោជកដែលយកចិត្តទុកដាក់ និងមានទំនួលខុសត្រូវ។

ការបណ្តុះបណ្តាល និងការអប់រំ

ចំនួនម៉ោងបណ្តុះបណ្តាលនិយោជិតជាមធ្យមក្នុងមួយឆ្នាំ

នៅឆ្នាំ ២០២៥ ធនាគារ ARDB បានកត់ត្រាកំណើនយ៉ាងច្បាស់លាស់នៃចំនួនម៉ោងបណ្តុះបណ្តាលមធ្យមរបស់បុគ្គលិកគ្រប់កម្រិត ដែលបង្ហាញពីការប្តេជ្ញាខ្ពស់របស់ធនាគារចំពោះការអភិវឌ្ឍបុគ្គលិក និងការពង្រឹងសមត្ថភាព។ នៅកម្រិតថ្នាក់នាយកដ្ឋាន (ប្រធាននាយកដ្ឋាន និងអនុប្រធាននាយកដ្ឋាន) បុគ្គលិកស្ត្រីបានបញ្ចប់ម៉ោងបណ្តុះបណ្តាលមធ្យម ៣៨.៤៤ ម៉ោង ខណៈបុគ្គលិកបុរសមានមធ្យម ២៥.៨៩ ម៉ោង ដែលនាំឱ្យមធ្យមសរុបស្មើ ២៩.៥៤ ម៉ោង។ នេះបង្ហាញពីកំណើន ៣៨.០៣% បើប្រៀបធៀបនឹងឆ្នាំ ២០២៤ ដែលមានត្រឹម ២១.៤០ ម៉ោង។ នៅកម្រិតថ្នាក់ការិយាល័យ (ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ) បុគ្គលិកស្ត្រីបានកត់ត្រាមធ្យម ៤៦.៩៧ ម៉ោង និងបុគ្គលិកបុរស ៤៥.៥១ ម៉ោង ដោយមធ្យមសរុបស្មើ ៤៦.០៩ ម៉ោង។ នេះបង្ហាញពីកំណើនយ៉ាងខ្លាំង ៨១.៤៥% បើប្រៀបធៀបនឹងឆ្នាំ ២០២៤ ដែលមាន ២៥.៤០ ម៉ោង។ សម្រាប់កម្រិតបុគ្គលិក (បុគ្គលិកជាន់ខ្ពស់ បុគ្គលិក និងជំនួយការ) ម៉ោងបណ្តុះបណ្តាលមធ្យមបានឈានដល់ ៣៨.៤៧ ម៉ោង ដោយបុគ្គលិកស្ត្រី ៣៨.៨០ ម៉ោង និងបុគ្គលិកបុរស ៣៨.៣៣ ម៉ោង។ នេះបង្ហាញពីកំណើន ៨៦.៧៥% បើប្រៀបធៀបនឹងឆ្នាំ ២០២៤ ដែលមាន ២០.៦០ ម៉ោង។

ជារួមធនាគារ ARDB បានសម្រេចបានកំណើនយ៉ាងខ្លាំង និងមានភាពស្ថិរភាពនៃម៉ោងបណ្តុះបណ្តាលក្នុងគ្រប់កម្រិតការងារនៅឆ្នាំ ២០២៥។ ការចូលរួមក្នុងការបណ្តុះបណ្តាលរបស់បុគ្គលិកបុរស និងស្ត្រីមានតុល្យភាព ខណៈដែលបរិមាណសរុបនៃការបណ្តុះបណ្តាលបានកើនឡើងយ៉ាងច្បាស់លាស់ពីឆ្នាំមួយទៅឆ្នាំមួយ។ ដើម្បីគាំទ្រកំណើននេះ ធនាគារ ARDB បន្តពង្រឹងសមត្ថភាពបុគ្គលិក តាមរយៈការវាយតម្លៃតម្រូវការបណ្តុះបណ្តាលជាប្រព័ន្ធ ដែលអនុវត្តនៅគ្រប់នាយកដ្ឋាន ដើម្បីធានាថាគំនិតផ្តួចផ្តើមនៃការរៀនសូត្រត្រូវបានសម្របសម្រួលជាមួយចក្ខុវិស័យរបស់ធនាគារអាទិភាពប្រតិបត្តិការនិងដំណើរការឌីជីថលនីយកម្មដែលកំពុងបន្តរបស់ប្រព័ន្ធធនាគារ។

ការស្រាវជ្រាវ និងការអភិវឌ្ឍសមត្ថភាព

ស្របតាមចក្ខុវិស័យក្នុងការក្លាយជាគ្រឹះស្ថានផ្តល់ហិរញ្ញប្បទានបៃតង និងហិរញ្ញប្បទានប្រកបដោយចីរភាពឈានមុខគេ ធនាគារបានពង្រីកការវិនិយោគលើការស្រាវជ្រាវយ៉ាងសំខាន់ ដោយផ្តោតជាពិសេសលើហិរញ្ញប្បទានបៃតង និងការសិក្សាគោលនយោបាយ។ នៅខែសីហា ឆ្នាំ២០២៤ ធនាគារបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ជាមួយសមាគមឥណទានកសិកម្ម និងជនបទអាស៊ី-ប៉ាស៊ីហ្វិក (Asia-Pacific Rural and Agricultural Credit Association) ដើម្បីបង្កើតមជ្ឈមណ្ឌលឧត្តមភាព ARDB APRACA Center of Excellence - From Agriculture to Green Finance (ARDB ACE-GFA)។ ក្រុមការងារស្រាវជ្រាវពិសេសមួយក៏ត្រូវបានបង្កើតឡើង ដើម្បីគាំទ្រមជ្ឈមណ្ឌលនេះ និងរួមចំណែកក្នុងការស្រាវជ្រាវអនុវត្តលើហិរញ្ញប្បទានបៃតង។

ស្របគ្នានេះ ធនាគារ ARDB បានបង្កើតមជ្ឈមណ្ឌលអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន (APM Center) ដើម្បីពង្រឹងបន្ថែមសមត្ថភាពស្រាវជ្រាវ និងការងារគោលនយោបាយរបស់ខ្លួន។ ជាមួយនឹងការបង្កើតមជ្ឈមណ្ឌលទាំងពីរ ធនាគារបានផ្តោតអាទិភាពលើការអភិវឌ្ឍជំនាញរបស់អ្នកស្រាវជ្រាវវ័យក្មេង តាមរយៈកម្មវិធីបណ្តុះបណ្តាលដែលមានរចនាសម្ព័ន្ធច្បាស់លាស់។ នៅឆ្នាំ ២០២៦ ធនាគារARDB មានផែនការផ្តល់កម្មវិធីបណ្តុះបណ្តាលចាប់ពីកម្រិតមូលដ្ឋានរហូតដល់កម្រិតខ្ពស់ ដើម្បីបង្កើនសមត្ថភាពស្រាវជ្រាវ និងចំណេះដឹងស្ថាប័នបន្ថែមទៀត។ គំនិតផ្តួចផ្តើមទាំងនេះបង្ហាញពីការប្តេជ្ញារយៈពេលវែងរបស់ធនាគារ ARDB ចំពោះការអភិវឌ្ឍធនធានមនុស្ស និងការរួមចំណែកក្នុងរបៀបវារៈអភិវឌ្ឍន៍បៃតង។ តាមរយៈការស្រាវជ្រាវ និងការផ្តល់យោបល់គោលនយោបាយផ្អែកលើភស្តុតាង ធនាគារមានគោលបំណងពង្រឹងចំណេះដឹង គាំទ្រវិស័យបៃតង និងជំរុញកំណើនប្រកបដោយចីរភាព ក្នុងយុគសម័យនៃការផ្លាស់ប្តូរបច្ចេកវិទ្យា និងសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស។

GRI 2-7: បុគ្គលិក
GRI 404-1: ម៉ោងបណ្តុះបណ្តាលជាមធ្យមក្នុងមួយឆ្នាំសម្រាប់និយោជិកម្នាក់

ប្រភេទបុគ្គលិក	ស្ត្រី	បុរស	ស្ត្រី	បុរស	ម៉ោងបណ្តុះបណ្តាលសរុប		ភាគរយ (២០២៤-២០២៥)
កម្រិតថ្នាក់នាយកដ្ឋាន (HoD-DHoD)	២០២៤	២០២៥	២០២៤	២០២៥	២០២៤	២០២៥	
	២៣.១	២០.២	៣៨.៤៤	២៥.៨៩	២១.៤	២៩.៥៤	៣៨.០៣%
កម្រិតថ្នាក់ការិយាល័យ (ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ)	១៨.៥៥	៣២.៤	៤៦.៩៧	៤៥.៥១	២៣.៤	៤៦.០៩	៨១.៤៥%
កម្រិតថ្នាក់បុគ្គលិក (បុគ្គលិកជាន់ខ្ពស់ បុគ្គលិក និងជំនួយការ)	១៧.០៥	២៤	៣៨.៨០	៣៨.៣៣	២០.៦	៣៨.៤៧	៨៦.៧៥%

ការវាយតម្លៃសមត្ថភាព និងការអភិវឌ្ឍអាជីព

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ផ្តល់ការវាយតម្លៃសមត្ថភាពការងារ តែចំពោះបុគ្គលិកដែលមានកិច្ចសន្យារយៈពេលមិនកំណត់ប៉ុណ្ណោះ។ នៅឆ្នាំ ២០២៥ បុគ្គលិកចំនួន ៣៨០ នាក់ ដែលស្មើនឹង ៩៥% នៃបុគ្គលិកសរុប បានទទួលការវាយតម្លៃសមត្ថភាពក្នុងអំឡុងរយៈពេលរាយការណ៍។

ក) បុគ្គលិកតាមភេទដែលបានទទួលការវាយតម្លៃសមត្ថភាព

ភេទ	បុគ្គលិក	ភាគរយ
ស្ត្រី	១៣៤	៣៥%
បុរស	២៤៦	៦៥%
សរុប	៣៨០	១០០%

ខ) បុគ្គលិកតាមប្រភេទដែលបានទទួលការវាយតម្លៃសមត្ថភាព

ប្រភេទបុគ្គលិក	ស្ត្រី	បុរស
កម្រិតគ្រប់គ្រង (CEO-DCEO)	០	៤
កម្រិតថ្នាក់នាយកដ្ឋាន (HoD-DHoD)	១៨	៤៣
កម្រិតថ្នាក់ការិយាល័យ (ប្រធានការិយាល័យ និងអនុប្រធានការិយាល័យ)	៥៣	៧០
កម្រិតថ្នាក់បុគ្គលិក (បុគ្គលិកជាន់ខ្ពស់ បុគ្គលិក និងជំនួយការ)	៥៣	១០២
បុគ្គលិកគាំទ្រ (សន្តិសុខ អ្នកបើកបរ និងអ្នកសម្អាត)	១០	២៧
សរុប	១៣៤	២៤៦

GRI 2-7: បុគ្គលិក
GRI 404-1: ម៉ោងបណ្តុះបណ្តាលជាមធ្យមក្នុងមួយឆ្នាំសម្រាប់និយោជិកម្នាក់
GRI 404-3: ភាគរយនៃនិយោជិតដែលទទួលបានការវាយតម្លៃជាប្រចាំ និងការអភិវឌ្ឍន៍អាជីព

កម្មវិធីបណ្តុះបណ្តាលលើកាសិក្សារ និងអភិវឌ្ឍន៍

ការចូលរួមរបស់បុគ្គលិកក្នុងកម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍មានលក្ខណៈបញ្ចូលគ្រប់ភេទ និងគ្រប់កម្រិតការងារ។ អត្រាចូលរួមបានបង្ហាញពីភាពស្មើគ្នារវាងបុគ្គលិកបុរស និងស្ត្រី ក៏ដូចជារវាងថ្នាក់ដឹកនាំជាន់ខ្ពស់ និងក្រុមបុគ្គលិកមិនមែនថ្នាក់ដឹកនាំ ដោយគាំទ្រពីគោលបំណងរបស់ ធនាគារARDB ក្នុងការធានាការទទួលបានឱកាសអភិវឌ្ឍវិជ្ជាជីវៈដោយស្មើភាព។

ការចូលរួមរបស់បុគ្គលិកក្នុងកម្មវិធីរៀនសូត្រ និងអភិវឌ្ឍន៍ តាមភេទ និងតាមប្រភេទការងារ

ភេទ / ប្រភេទការងារ	២០២៤		២០២៥	
	បុរស	ស្ត្រី	បុរស	ស្ត្រី
	៦៥%	៣៥%	៤0%	៣៣%
ក្រុមគ្រប់គ្រងជាន់ខ្ពស់	៣២%		៩%	
ក្រុមបុគ្គលិកមិនមែនថ្នាក់គ្រប់គ្រង	៦៩%		៦២%	

GRI 2-7: បុគ្គលិក
GRI 404-3: ភាពរយនៃនិយោជិតដែលទទួលបានការវាយតម្លៃជាប្រចាំនិងការអភិវឌ្ឍន៍អាជីព

កម្មវិធីបណ្តុះបណ្តាល និងអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ

កម្មវិធីសិក្សា និងអភិវឌ្ឍន៍ក្នុងឆ្នាំ ២០២៥÷

ការបណ្តុះបណ្តាលក្នុងស្ថាប័ន	
១	តម្លៃស្នូលរបស់ ធនាគារ ARDB
២	គោលការណ៍វាយតម្លៃសមត្ថភាពបុគ្គលិក
៣	កញ្ចប់ថែទាំសុខភាពបុគ្គលិកសម្រាប់ឆ្នាំ ២០២៥
ការបណ្តុះបណ្តាលកាតព្វកិច្ច	
១	ការប្រឆាំងការលាងលុយកខ្វក់ និងការផ្តល់ហិរញ្ញប្បទានដល់ភេរវកម្ម
២	ការយល់ដឹងអំពីសន្តិសុខអ៊ីនធឺណិត
៣	ការប្រើប្រាស់ AI នៅកន្លែងធ្វើការ
៤	ការប្រើប្រាស់ AI ក្នុងវិស័យធនាគារ និងរូបិយប័ណ្ណឌីជីថលរបស់ធនាគារកណ្តាល
៥	ការច្នៃប្រឌិតសំខាន់ៗ និងកំណើនប្រកបដោយចីរភាព
៦	ការរាយការណ៍អំពីការបំពាន (Whistleblowing)
៧	ការគ្រប់គ្រងឥណទាន
៨	គោលការណ៍ និងគោលនយោបាយឥណទានបៃតង
៩	លំហូរការងារយុទ្ធនាការ ការបង្កើតប្រតិបត្តិការ និងការបង្កើតគណនី
១០	ដំណើរការដាក់សែក
១១	ប្រព័ន្ធធានាឥណទាន និងប្រព័ន្ធគ្រប់គ្រងការធានា
កម្មវិធីអភិវឌ្ឍន៍ជំនាញទន់	
១	ការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព
២	បច្ចេកទេសលក់
៣	ភាពជីកនាំ និងការគ្រប់គ្រង
៤	ការបណ្តុះបណ្តាលគ្រូបង្គោល
ការអភិវឌ្ឍជំនាញ និងការពង្រឹងសមត្ថភាពសម្រាប់ក្រុមការងារស្រាវជ្រាវ	
១	ការវិភាគទិន្នន័យ
២	វិធីសាស្ត្រស្រាវជ្រាវមូលដ្ឋាន
៣	ម៉ាក្រូសេដ្ឋកិច្ចមូលដ្ឋាន និងគោលនយោបាយ
៤	ការរចនាការស្រាវជ្រាវបែបចម្រុះវិធីសាស្ត្រ
៥	ការវិភាគទិន្នន័យបែបគុណភាព
៦	ការតាមដានម៉ាក្រូសេដ្ឋកិច្ចសកលសម្រាប់ការផ្លាស់ប្តូរដែលមានភាពយូរអង្វែង
៧	សេចក្តីណែនាំអំពីគម្រោង ការបណ្តុះបណ្តាល ការគ្រប់គ្រង និងការវាយតម្លៃ

កម្មវិធីគាំទ្រផ្សេងៗទៀត	
១	ការបង្ហាត់បង្រៀន និងការណែនាំ
២	កម្មវិធី Job rotation
៣	កម្មវិធី Professional certification
៤	ជំនួយឧបត្ថម្ភអាហារូបករណ៍
៥	កម្មវិធីអភិវឌ្ឍន៍ការគ្រប់គ្រង និងភាពជាអ្នកដឹកនាំ
៦	ការបណ្តុះបណ្តាលភាសា និងមជ្ឈមណ្ឌលអប់រំអូស្ត្រាលី
៧	កម្មវិធីគ្រប់គ្រងទេពកោសល្យ

កម្មវិធីពង្រឹងជំនាញនិយោជិក និងអ្នកបន្តវេន

កម្មវិធីគាំទ្រសមត្ថភាព និងអភិវឌ្ឍន៍សមត្ថភាពរបស់ ធនាគារ ARDB ក្នុងឆ្នាំ ២០២៥ ត្រូវបានរៀបចំឡើង ដើម្បីពង្រឹងសុចរិតភាពក្នុងការប្រតិបត្តិ សមត្ថភាពនៃការអនុវត្តការងារ ការច្នៃប្រឌិត និងការអភិវឌ្ឍធនធានមនុស្សនៅគ្រប់កម្រិតនៃអង្គភាព។

គំនិតផ្តួចផ្តើមទាំងនេះមានគោលបំណងធានាថាបុគ្គលិកមានជំនាញ និងចំណេះដឹងសមស្រប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរក្នុងវិស័យហិរញ្ញវត្ថុ ក៏ដូចជាពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងការអភិវឌ្ឍប្រកបដោយចីរភាពរបស់ស្ថាប័ន។

- កម្មវិធីបណ្តុះបណ្តាលផ្ទៃក្នុងស្ថាប័ន ពង្រឹងតម្លៃស្នូលរបស់ធនាគារ គោលការណ៍គ្រប់គ្រងសមិទ្ធផលការងារ និងសុខុមាលភាពបុគ្គលិក រួមទាំងការយល់ដឹងអំពីកញ្ចប់សេវាសុខាភិបាលឆ្នាំ ២០២៥។ កម្មវិធីគាំទ្រការអនុវត្តតាមបទប្បញ្ញត្តិ ការគ្រប់គ្រងហានិភ័យ និងការអនុវត្តការងារប្រកបដោយការទទួលខុសត្រូវ ព្រមទាំងបង្កើនប្រសិទ្ធភាពប្រតិបត្តិការ តាមរយៈការបណ្តុះបណ្តាលអំពីយុទ្ធនាការនៃដំណើរការការងារ ដំណើរការប្រតិបត្តិការ ការទូទាត់មូលប្បទានប័ត្រ និងក្របខណ្ឌគ្រប់គ្រងលើការធានា។
- ដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈបន្ថែម ធនាគារ ARDB ផ្តល់កម្មវិធីអភិវឌ្ឍន៍ជំនាញទន់ (Soft Skills Development Programs) ការទំនាក់ទំនង ការលក់ និងភាពជាអ្នកដឹកនាំ។ លើសពីនេះ ផែនការបណ្តុះបណ្តាលគ្រូបង្គោល មានលក្ខណៈទូលំទូលាយត្រូវបានរៀបចំឡើងដោយផ្អែកលើនាញដែលបានកំណត់។គំនិតផ្តួចផ្តើមនេះជួយពង្រឹងសមត្ថភាពបណ្តុះបណ្តាលផ្ទៃក្នុង ដោយផ្តល់ឱ្យបុគ្គលិកនូវជំនាញបច្ចេកទេស និងជំនាញបង្រៀន។ កម្មវិធីបណ្តុះបណ្តាលគ្រូបង្គោល ត្រូវបានរៀបចំឡើង សម្រាប់អនុវត្តជាប្រចាំប្រចាំឆ្នាំ ដោយមានគោលបំណង និងកម្រិតការរៀនសូត្រខុសៗគ្នា។
- ក្នុងពេលដំណាលគ្នានេះ កម្មវិធីអភិវឌ្ឍជំនាញ និងពង្រឹងសមត្ថភាពសម្រាប់ក្រុមការងារស្រាវជ្រាវ មានគោលបំណងពង្រឹងសមត្ថភាពក្នុងការវិភាគ និងស្រាវជ្រាវ រួមមានការវិភាគទិន្នន័យ ម៉ាក្រូសេដ្ឋកិច្ច វិធីសាស្ត្រស្រាវជ្រាវប្រកបដោយគុណភាព ការគ្រប់គ្រងគម្រោង និងការតាមដានម៉ាក្រូសេដ្ឋកិច្ចសកល។
- លើសពីការបណ្តុះបណ្តាលផ្លូវការ ធនាគារ ARDB ក៏ផ្តល់ឱកាសអភិវឌ្ឍបន្ថែមផ្សេងៗទៀត ដូចជាការប្តូរតួនាទីការងារ (Job Rotation) កម្មវិធី Professional Certification អាហារូបករណ៍ និងការបណ្តុះបណ្តាលភាសា។ ជារួម គំនិតផ្តួចផ្តើមទាំងនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់ធនាគារក្នុងការពង្រឹងសមត្ថភាពបុគ្គលិកជំរុញការច្នៃប្រឌិតគាំទ្រហិរញ្ញប្បទានប្រកបដោយចីរភាព និងធានានិរន្តរភាពរយៈពេលវែងរបស់ស្ថាប័ន។

បុគ្គលិកដែលទទួលការវាយតម្លៃសមត្ថភាព និងការអភិវឌ្ឍអាជីពជាប្រចាំ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម អនុវត្តការវាយតម្លៃសមត្ថភាព និងការអភិវឌ្ឍអាជីពជាប្រចាំសម្រាប់បុគ្គលិកទាំងអស់ តាមរយៈការវាយតម្លៃសូចនាករសមត្ថភាព (KPI) ដែលត្រូវបានកំណត់នៅដើមឆ្នាំនីមួយៗ។

KPI ទាំងនេះវាស់វែងទាំងសមត្ថភាពការងារ និងអាកប្បកិរិយារបស់បុគ្គលិក ដោយផ្តោតលើចំណុចសំខាន់ៗដូចជា÷

- **កត្តាហិរញ្ញវត្ថុ ÷** មានសកម្មភាពដែលមានគោលបំណងពង្រីក និងរក្សាទុកធនធានរបស់ធនាគារ។
- **កត្តាអតិថិជន÷** មានគំនិតផ្តួចផ្តើមដែលគាំទ្រទាំងអតិថិជនខាងក្រៅ និងខាងក្នុង។ អតិថិជនខាងក្រៅរួមមានកសិករ និងអាជីវកម្មក្នុងខ្សែសង្វាក់តម្លៃកសិកម្ម ព្រមទាំងដៃគូ និងភាគីពាក់ព័ន្ធរបស់ ធនាគារ ARDB ខណៈអតិថិជនខាង ក្នុងរួមមានគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់របស់ធនាគារ ARDB។
- **កត្តារៀបចំដំណើរការផ្ទៃក្នុង និងអភិវឌ្ឍន៍÷** មានគំនិតផ្តួចផ្តើមដែលមានគោលបំណងពង្រឹងប្រតិបត្តិការ និងលំហូរការងារនៅក្នុងអង្គភាព ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាព កាត់បន្ថយហានិភ័យប្រតិបត្តិការ និងធានានិរន្តរភាពរយៈពេលវែង។
- **កត្តាអភិវឌ្ឍន៍សមត្ថភាព÷** សកម្មភាពដែលមានគោលបំណងលើកកម្ពស់ការអភិវឌ្ឍផ្ទាល់ខ្លួន និងវិជ្ជាជីវៈ ដោយផ្តល់អំណាចដល់បុគ្គលក្នុងការពង្រឹងជំនាញ ចំណេះដឹង និងឥទ្ធិពលរបស់ខ្លួន ព្រមទាំងគាំទ្រការរីកចម្រើន និងភាពជោគជ័យរបស់មនុស្សគ្រប់រូប។

ជាផ្នែកនៃដំណើរការនេះ បុគ្គលិក ធនាគារ ARDB ទាំងអស់ត្រូវបានផ្តល់ឱកាសក្នុងការវាយតម្លៃមិត្តរួមការងារក្នុងនាយកដ្ឋានដូចគ្នា។ការវាយតម្លៃពីមិត្តរួមការងារនេះជំរុញវប្បធម៌សហការណ៍ការទទួលខុសត្រូវនិងការផ្តល់មតិយោបល់ដែលមានលក្ខណៈស្ថាបនា ដើម្បីធានាថាបុគ្គលិកទទួលបានទស្សនៈពេញលេញ និងមានតុល្យភាពអំពីការចូលរួមរបស់ខ្លួន។ បន្ថែមពីនេះ បុគ្គលិកដែលមានកិច្ចសន្យារយៈពេលមិនកំណត់ក៏ត្រូវបានវាយតម្លៃសមត្ថភាពបន្ទាប់ពីបញ្ចប់រយៈពេលសាកល្បង ដើម្បីធានាការ សមស្របជាមួយស្តង់ដារ និងការរំពឹងទុករបស់អង្គភាព។ ធនាគារ ARDB ប្តេជ្ញាជំរុញការរៀនសូត្របន្តពង្រឹងភាពរឹងមាំរបស់ក្រុមការងារ និងគាំទ្រការរីកចម្រើនទាំងផ្ទាល់ខ្លួន និងអង្គភាព។

GRI 404-2: កម្មវិធីសម្រាប់បង្កើតជំនាញនិយោជិក និងកម្មវិធីជំនួយការផ្ទាស់ប្តូរ
GRI 404-3: ភាគរយនៃនិយោជិកដែលទទួលបាន ការវាយតម្លៃជាប្រចាំនិងការអភិវឌ្ឍន៍អាជីព

សន្ទស្សន៍មាតិកា GRI

ផ្នែកនេះបង្ហាញពីសមិទ្ធផលប្រកបដោយចីរភាពរបស់ ARDB ដោយផ្អែកលើស្តង់ដារ Global Reporting Initiative (GRI Standards) ÷

ស្តង់ដា GRI	លេខសម្គាល់ និងចំណងជើងនៃការបង្ហាញ		ទំព័រ
GRI ២: ព័ត៌មានទូទៅ	២-១	ព័ត៌មានស្ថាប័ន	២១
	២-៦	សកម្មភាព ខ្សែសង្វាក់ផលិតកម្មផ្សេងៗ និងទំនាក់ទំនងអាជីវកម្ម	១-២, ៨-២០, ២៤-៣៤, ៣៦-៣៧, ៤៤-៤៦
	២-៧	បុគ្គលិក	៧៥-៧៦, ៨០-៨២
	២-២២	សេចក្តីថ្លែងការណ៍ស្តីពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រកបដោយចីរភាព	៣-៦
	២-២៣	ការប្តេជ្ញាទៅលើគោលការណ៍	៤៨, ៦៧
	២-២៦	យន្តការសម្រាប់ស្វែងរកយោបល់ និងលើកឡើងកង្វល់	៦៧
	២-២៨	សមាជិកភាពសមាគម	២២-២៣
GRI3: ប្រធានបទសំខាន់	៣-៣	ការគ្រប់គ្រងប្រធានបទសំខាន់ៗ	៦៥,៦៦
GRI ២០១: ការអនុវត្តសេដ្ឋកិច្ច	២០១-១	ផលវិជ្ជមានទៅលើសេដ្ឋកិច្ចដោយផ្ទាល់ និងផលជះ	២៤-២៨, ៤៤-៤៦
	២០១-២	ផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុ និងហានិភ័យ និងឱកាសផ្សេងទៀតដោយសារការប្រែប្រួលអាកាសធាតុ	៤៨, ៥៤
	២០១-៣	កាតព្វកិច្ចផែនការអត្ថប្រយោជន៍ដែលបានកំណត់ និងផែនការចូលនិវត្តន៍ផ្សេងទៀត	៧៧, ៧៩
	២០១-៤	ជំនួយហិរញ្ញវត្ថុទទួលបានពីរដ្ឋាភិបាល	៥៤
GRI ២០២: វត្តមានទីផ្សារ	២០២-១	សមាមាត្រនៃប្រាក់ឈ្នួលកម្រិតស្តង់ដារតាមភេទធៀបនឹងប្រាក់ឈ្នួលអប្បបរមាក្នុងស្រុក	៥៥
	២០២-២	សមាមាត្រនៃគណៈគ្រប់គ្រងជាន់ខ្ពស់ដែលមកពីសហគមន៍ក្នុងស្រុក	៥៥
GRI ២០៣: ផលជះទៅលើសេដ្ឋកិច្ចដោយប្រយោល	២០៣-១	ការវិនិយោគ និងសេវាកម្មហេដ្ឋារចនាសម្ព័ន្ធ	៥២-៥៣
	២០៣-២	ផលវិជ្ជមានសំខាន់ៗទៅលើសេដ្ឋកិច្ចដោយប្រយោល	៣៥-៣៧, ៤៩-៥៣, ៥៨-៥៩
GRI ២០៥: ការប្រយុទ្ធប្រឆាំងអំពើពុករលួយ	២០៥-១	ប្រតិបត្តិការត្រូវបានវាយតម្លៃសម្រាប់ហានិភ័យដែលទាក់ទងនឹងអំពើពុករលួយ	៦៧-៦៨
	២០៥-២	ការទំនាក់ទំនង និងការបណ្តុះបណ្តាលអំពីគោលនយោបាយ និងនីតិវិធីនៃអំពើពុករលួយ	៦៧-៦៨
	២០៥-៣	ឧប្បត្តិហេតុនៃអំពើពុករលួយ និងសកម្មភាពដែលបានបញ្ជាក់	៦៧-៦៨
GRI ២០៦: សកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង	២០៦-១	សកម្មភាពផ្លូវច្បាប់ទៅលើសកម្មភាពប្រឆាំងនឹងការប្រកួតប្រជែង ការជម្រុញឱ្យមានភាពប្រកួតប្រជែង និងឯកាធិភាព	៦៧-៦៨

ស្តង់ដា GRI	លេខសម្គាល់ និងចំណងជើងនៃការបង្ហាញ		ទំព័រ
GRI ៣០២: ថាមពល	៣០២-១	ការប្រើប្រាស់ថាមពលនៅក្នុងស្ថាប័ន	៦០
	៣០២-៤	ការកាត់បន្ថយការប្រើប្រាស់ថាមពល	៦១
GRI ៣០៣: ទឹក និងទឹកសំណល់	៣០៣-៥	ការប្រើប្រាស់ទឹក	៦១
GRI ៣០៥: ការបំភាយឧស្ម័ន	៣០៥-១	ការបំភាយឧស្ម័ន GHG ដោយផ្ទាល់ (វិសាលភាព ១)	៦២
GRI ៣០៦: កាកសំណល់	៣០៦-១	កាកសំណល់ និងផលប៉ះពាល់សំខាន់ៗទាក់ទងនឹងកាកសំណល់	៦២
	៣០៦-២	ការគ្រប់គ្រងផលប៉ះពាល់សំខាន់ៗទាក់ទងនឹងកាកសំណល់	៦៣-៦៤
	៣០៦-៤	កាកសំណល់ត្រូវបានបង្វែរចេញពីការបញ្ចេញចោល	៦៥
	៣០៦-៥	កាកសំណល់ដែលបានបញ្ចេញចោល	៦៥
GRI ៣០៨: ការវាយតម្លៃផលជះដល់បរិស្ថាននៃអ្នកផ្គត់ផ្គង់	៣០៨-១	អ្នកផ្គត់ផ្គង់ថ្មីដែលត្រូវបានពិនិត្យដោយប្រើលក្ខណៈវិនិច្ឆ័យបរិស្ថាន	៦៥
	៣០៨-២	ផលប៉ះពាល់បរិស្ថានអវិជ្ជមាននៅក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ និងសកម្មភាពដែលបានធ្វើឡើង	៦៥
GRI ៤០១: ការងារ	៤០១-១	ការជួលបុគ្គលិកថ្មី និងការផ្លាស់ប្តូរបុគ្គលិក	៧៥-៧៦
	៤០១-២	អត្ថប្រយោជន៍ផ្តល់ជូនដល់និយោជិតពេញម៉ោង ដែលមិនត្រូវបានផ្តល់ជូនដល់និយោជិតបណ្តោះអាសន្ន ឬក្រៅម៉ោង	៧៧
	៤០១-៣	ច្បាប់សម្រាកមាតុភាព/បិតុភាព	៧៨
GRI ៤០៣: សុខភាព និងសុវត្ថិភាពការងារ	៤០៣-១	ប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ	៧១
	៤០៣-២	ការកំណត់អត្តសញ្ញាណគ្រោះថ្នាក់ ការវាយតម្លៃហានិភ័យ និងការស៊ើបអង្កេតឧប្បត្តិហេតុ	៧១
	៤០៣-៣	សេវាសុខភាពការងារ	៧២
	៤០៣-៤	ការចូលរួម ការពិគ្រោះយោបល់ និងការទំនាក់ទំនងរបស់បុគ្គលិកលើសុខភាព និងសុវត្ថិភាពការងារ	៧២
	៤០៣-៥	វគ្គបណ្តុះបណ្តាលស្តីពីសុខភាព និងសុវត្ថិភាពការងារ	៧២
	៤០៣-៦	ការលើកកម្ពស់សុខភាពបុគ្គលិក	៧៣
	៤០៣-៧	ការការពារ និងកាត់បន្ថយផលប៉ះពាល់សុខភាព និងសុវត្ថិភាពការងារ	៧៣-៧៤
	៤០៣-៨	បុគ្គលិកដែលគ្របដណ្តប់ដោយប្រព័ន្ធគ្រប់គ្រងសុខភាព និងសុវត្ថិភាពការងារ	៧៣-៧៤
	៤០៣-៩	របួសទាក់ទងនឹងការងារ	៧៣-៧៤
	៤០៣-១០	ជំងឺដែលពាក់ព័ន្ធនឹងការងារ	៧៣-៧៤

ស្តង់ដា GRI	លេខសម្គាល់ និងចំណងជើងនៃការបង្ហាញ		ទំព័រ
GRI ៤០៤: ការបណ្តុះបណ្តាល និងការអប់រំ	៤០៤-១	ម៉ោងបណ្តុះបណ្តាលជាមធ្យមក្នុងមួយឆ្នាំសម្រាប់និយោជិកម្នាក់	៨០-៨១
	៤០៤-២	កម្មវិធីសម្រាប់បង្កើនជំនាញនិយោជិក និងកម្មវិធីជំនួយការផ្លាស់ប្តូរ	៨៣-៨៥
	៤០៤-៣	ភាគរយនៃនិយោជិតដែលទទួលបានការវាយតម្លៃជាប្រចាំ និងការអភិវឌ្ឍន៍អាជីព	៨១-៨២, ៨៥
GRI ៤០៥: ភាពចម្រុះ និងឱកាសស្មើគ្នា	៤០៥-១	ភាពចម្រុះនៃស្ថាប័នអភិបាលកិច្ច និងនិយោជិត	៦៩
	៤០៥-២	សមាមាត្រនៃប្រាក់ខែគោល និងប្រាក់បៀវត្សរ៍របស់ស្ត្រី និងបុរស	៧០

៩.របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច នៃធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍ក្រុមប្រឹក្សាភិបាល
និង
របាយការណ៍ហិរញ្ញវត្ថុបានធ្វើសវនកម្មរួច
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

មាតិកា **ទំព័រ**

របាយការណ៍ក្រុមប្រឹក្សាភិបាល	១ - ៥
របាយការណ៍ហិរញ្ញវត្ថុ	
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ	៦ - ៧
របាយការណ៍លទ្ធផលលម្អិត	៨
របាយការណ៍បម្រែបម្រួលមូលធន	៩-១០
របាយការណ៍លំហូរសាច់ប្រាក់	១១- ១២
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ	១៣ - ៩៤
របាយការណ៍សវនករឯករាជ្យ	៩៥ - ៩៨

របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់ជូននូវរបាយការណ៍របស់ខ្លួន ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ហៅកាត់ថា "ធនាគារ") សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥។

សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺចូលរួមគ្រប់ទិដ្ឋភាពទាំងអស់នៃធនាគារពាណិជ្ជ និងការផ្តល់សេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងអំឡុងការិយបរិច្ឆេទនេះ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពអាជីវកម្មចម្បងទាំងនេះទេ។

លទ្ធផលហិរញ្ញវត្ថុ

	២០២៥	
	ដុល្លារអាមេរិក	ពាន់រៀល
ខាតសម្រាប់ការិយបរិច្ឆេទ	(១.៧៥៦.៤៩៦)	(៧.០៤៥.៣០៧)

ភាគលាភ

ពុំមានភាគលាភដែលត្រូវបានបែងចែកនោះទេ ហើយក្រុមប្រឹក្សាភិបាល ក៏ពុំបានស្នើឱ្យមានការបង់ភាគលាភផ្សេងៗ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ នោះដែរ។

ដើមទុន

ព័ត៌មានលម្អិតនៃដើមទុនភាគហ៊ុន និងរចនាសម្ព័ន្ធកាន់កាប់ភាគហ៊ុន ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២០ នៃរបាយការណ៍ហិរញ្ញវត្ថុ។

ទុនបម្រុង និងសំវិធានធន

ផ្ទេរទៅ ឬបានពីទុនបម្រុង ឬសំវិធានធន នៅក្នុងអំឡុងការិយបរិច្ឆេទ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

អគារលេខ ១៦៨ ផ្លូវបេតុង លេខ៧ ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ
168, St.7, Village Prek Leap, Sangkat Prek Leap, Khan Chroy Changvar, Phnom Penh City
E-mail : admin@ardb.com.kh
ទូរស័ព្ទ (៨៥៥)២៣ ២២០ ៨១០/ ២២០ ៨១១ Tel : (855)23 220 810/220 811
Website : www.ardb.com.kh
Facebook : ARDB Bank

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍ក្រុមប្រឹក្សាភិបាល

ឥណទាន និងបុរេប្រទានពិបាកទារ និងឥណទាន និងបុរេប្រទានជាប់សង្ស័យ

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថា វិធានការទាក់ទងនឹងការលុបចោលឥណទាន និងបុរេប្រទានជាប់សង្ស័យ និងការប៉ាន់ស្មាននៃសំវិធានធនលើឥណទាន និងបុរេប្រទានជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទាន និងបុរេប្រទានពិបាកទារដែលត្រូវបានលុបចោល និងបានធ្វើសំវិធានធនគ្រប់គ្រាន់លើឥណទាន និងបុរេប្រទានជាប់សង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលនឹងបណ្តាលឱ្យទឹកប្រាក់នៃឥណទាន និងបុរេប្រទានជាប់សង្ស័យដែលត្រូវបានលុបចោល ឬទឹកប្រាក់នៃសំវិធានធនក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានភាពមិនគ្រប់គ្រាន់ជាសារវន្តឡើយ។

ទ្រព្យសកម្ម

មុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមរម្យដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មដែលប្រហែលជាមិនអាចលក់បាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា រួមទាំងតម្លៃដែលបានកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកាត់បន្ថយមកត្រឹមតម្លៃដែលរំពឹងថានឹងអាចលក់បានលើទីផ្សារ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចនឹងបណ្តាលឱ្យតម្លៃទ្រព្យសកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារមានភាពមិនត្រឹមត្រូវឡើយ។

វិធីសាស្ត្រក្នុងការវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតដែលអាចនឹងបណ្តាលឱ្យការអនុវត្តវិធីសាស្ត្របច្ចុប្បន្នក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលរបស់ធនាគារមានភាពមិនត្រឹមត្រូវ ឬមិនសមស្របឡើយ។

បំណុលយថាហេតុ និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(១) ការដាក់បន្ទុកលើទ្រព្យសកម្មណាមួយរបស់ធនាគារ ដែលកើតមានឡើងចាប់តាំងពីចុងការិយបរិច្ឆេទដើម្បីធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(២) បំណុលយថាហេតុណាមួយចំពោះធនាគារ ដែលកើតមានឡើងចាប់តាំងពីចុងការិយបរិច្ឆេទ ក្រៅពីដំណើរការធម្មតានៃអាជីវកម្មធនាគារឡើយ។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ធនាគារដែលត្រូវទាមទារឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេលដប់ពីរខែ បន្ទាប់ពីចុងការិយបរិច្ឆេទដែលនឹង ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារក្នុងការទូទាត់បំណុលរបស់ខ្លួននៅថ្ងៃកំណត់សងនេះទេ។

ការផ្លាស់ប្តូរនៃហេតុការណ៍

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ លុះត្រាតែបានបង្ហាញនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចនឹងបណ្តាលឱ្យតួលេខណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវឡើយ។

ប្រតិបត្តិការជាសារវន្ត និងមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល៖

(១) លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ធនាគារក្នុងការិយបរិច្ឆេទនេះ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដោយកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ និង

(២) ពុំមានកត្តា ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីបានកើតឡើងនោះទេក្នុងចន្លោះពេលរវាងចុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះដែលអាចនាំឱ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលប្រតិបត្តិការរបស់ធនាគារក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះត្រូវបានរៀបចំឡើងទេ។

ការចោះផ្សាយភាគហ៊ុន និងប័ណ្ណបំណុល

នៅក្នុងអំឡុងការិយបរិច្ឆេទ ពុំមានការចោះផ្សាយភាគហ៊ុន និងប័ណ្ណបំណុលថ្មីដោយធនាគារនោះទេ។

ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារក្នុងអំឡុងការិយបរិច្ឆេទ និងរហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានដូចខាងក្រោម៖

ឈ្មោះ	**មុខតំណែង**
ឯកឧត្តម រស់ សីលវ៉ា	ប្រធានក្រុមប្រឹក្សាភិបាល
ឯកឧត្តមបណ្ឌិត កៅ ថាច	អភិបាល
ឯកឧត្តមបណ្ឌិត សាន វិសាល	អភិបាល
ឯកឧត្តម ឃី កុសល	អភិបាល
លោក ប៉ាក សេរីវឌ្ឍនា	អភិបាលឯករាជ្យ
ឯកឧត្តម ចាន់ សីហា	អភិបាល
ឯកឧត្តម ឈាង វណ្ណារិទ្ធ	អភិបាល

អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

ចាប់តាំងពីចុងការិយបរិច្ឆេទមុន ក្រុមប្រឹក្សាភិបាលពុំបានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលធ្វើឡើងដោយធនាគារ ឬសាជីវកម្មពាក់ព័ន្ធណាមួយជាមួយក្រុមប្រឹក្សាភិបាល ឬក្រុមហ៊ុនណាមួយដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ធ្វើឡើងជាមួយធនាគារណាមួយ ដែលអភិបាលនោះមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុជាសារវន្តនោះទេ លើកលែងតែអត្ថប្រយោជន៍ដែលចាត់ទុកថាបានកើតឡើងដោយគុណធម៌នៃប្រតិបត្តិការដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៣០ នៃរបាយការណ៍ហិរញ្ញវត្ថុ។

ទាំងនៅក្នុងអំឡុងពេល ឬនៅចុងបញ្ចប់នៃការិយបរិច្ឆេទ គឺធនាគារមិនដែលជាភាគីនៃការរៀបចំក្នុងគោលបំណងដើម្បីអនុញ្ញាតឱ្យក្រុមប្រឹក្សាភិបាលទទួលបានអត្ថប្រយោជន៍តាមរយៈនៃការទិញភាគហ៊ុន ឬប័ណ្ណបំណុលរបស់ធនាគារ ឬក្រុមហ៊ុនសាជីវកម្មផ្សេងទៀត។

ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ធនាគារ មានភារៈទទួលខុសត្រូវលើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលរបស់ធនាគារចាំបាច់ត្រូវ៖

(១) អនុវត្តគោលការណ៍គណនេយ្យសមស្រប ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា “ស.រ.ទ.ហ.អ.ក”) ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនោះឱ្យមានសង្គតិភាព។

(២) អនុលោមតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មានទៅតាម ស.រ.ទ.ហ.អ.ក ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដាទាំងនេះ ក្នុងការបង្ហាញនូវភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(៣) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីធនាគារអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនស្របទៅតាម ស.រ.ទ.ហ.អ.ក និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព។

(៤) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយប្រើប្រាស់មូលដ្ឋាននិរន្តរភាពអាជីវកម្ម លុះត្រាតែវាមានភាពមិនត្រឹមត្រូវក្នុងការសន្មតថា ធនាគារនឹងបន្តប្រតិបត្តិការរបស់ខ្លួននាពេលអនាគត និង

(៥) គ្រប់គ្រង និងដឹកនាំធនាគារឱ្យមានប្រសិទ្ធិភាព ហើយចូលរួមក្នុងការសម្រេចចិត្តជាសារវន្តទាំងអស់ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលរបស់ធនាគារ ហើយត្រូវប្រាកដថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ធនាគារបានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍ក្រុមប្រឹក្សាភិបាល

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ និងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញត្រឹមត្រូវ នូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាល

.....

រស់ សីលវ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី 30 APR 2026

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	២០២៥		២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល (ដែលបានបង្ហាញឡើងវិញ - កំណត់សម្គាល់ ៣៧)
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៥	៥.៣៣៤.៩៦៩	២១.៤០៩.២៣១	២.៨៦៩.៦៨៥	១១.៥៥០.៤៨២
ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ	៦	១២.៧៥៥.២៨៣	៥១.១៨៦.៩៥១	១៣.៨៧១.៣៥០	៥៥.៨៣២.១៨៣
ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា	៧	២២.៨៨៨.៦៨៣	៩១.៨៥២.២៨៥	៦.០៣៧.៧៤២	២៤.៣០១.៩១២
ឥណទាន និងបុរេប្រទានទៅអតិថិជន	៨	៥២៤.១៣៤.៨៧៨	២.១០៣.៣៥៣.២៦៥	៤៧៤.៨៣៤.៣៦៧	១.៩១១.២០៨.៣២៧
ទ្រព្យសកម្មផ្សេងៗ	៩	១.៥៣៥.៦១៨	៦.១៦២.៤៣៥	២.៤៧៣.០៨៨	៩.៩៥៤.១៧៩
ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ	១០	១៧.៩៨៧.៧៨៣	៧២.១៨៤.៩៧៣	១៦.៣៣២.៥៦៦	៦៥.៧៣៨.៥៧៨
ទ្រព្យសម្បត្តិបានរឹបអូស	១១	៥៧.៩២៧.៣៥៤	២៣២.៤៦២.៤៧២	២៩.៣៨២.៩៩៥	១១៨.២៦៦.៥៥៥
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	១២	១៧៦.១០៣	៧០៦.៧០១	២៨៨.៣០៩	១.១៦០.៤៤៤
ទ្រព្យសម្បត្តិ និងបរិក្ខារ	១៣	២១.៦៨៥.៦២៧	៨៧.០២៤.៤២១	២០.០៨២.៦១៨	៨០.៨៣២.៥៣៧
ទ្រព្យសកម្មអរូបី	១៤	៦.១៣៣.៩៧៥	២៤.៦១៥.៦៤២	៤.២១៨.៧១៥	១៦.៩៨០.៣២៨
ពន្ធលើប្រាក់ចំណេញដែលត្រូវទទួល		៨៤៧.៨៩៦	៣.៤០២.៦០៧	៨៤៧.៨៩៦	៣.៤១២.៧៨២
ទ្រព្យសកម្មសរុប		៦៧១.៤០៨.១៦៩	២.៦៩៤.៣៦០.៩៨៣	៥៧១.២៣៩.៣៣១	២.២៩៩.២៣៨.៣០៧
បំណុល និងមូលធន					
បំណុល					
ប្រាក់បញ្ញើពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ	១៥	២៣.៤០៩	៩៣.៩៤០	៦២.៣៦៨	២៥១.០៣១
ប្រាក់បញ្ញើពីអតិថិជន	១៦	៦៤.៣១៤.៥៣៤	២៥៨.០៩៤.២២៥	១១.២២២.៧៩២	៤៥.១៧១.៧៣៨
ប្រាក់កម្ចី	១៧	៤៣៨.៤៣៥.២៤៩	១.៧៥៩.៤៤០.៦៥៤	៣៩០.៦២០.៩៣៧	១.៥៧២.២៤៩.២៧១
បំណុលបន្ទាប់បន្សំ	១៨	១.០៤៤.០៨៤	៤.១៨៩.៩០៩	១.០៤៤.០៨៤	៤.២០២.៤៣៨
បំណុលភតិសន្យា	១២	១៩៣.១៣៨	៧៧៥.០៦៣	៣០៣.៩២៩	១.២២៣.៣១៤
បំណុលផ្សេងៗ	១៩	១.២១៤.១០៧	៤.៨៧២.២១២	៦២៦.២១២	២.៥២០.៥០៣
សំវិធានធនសម្រាប់កិច្ចសន្យាហិរញ្ញវត្ថុ		១០.២៨១	៤១.២៥៨	១០.១២៦	៤០.៧៥៧
បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន		-	-	៦៥៦.៣៤៤	២.៦៤១.៧៨៥
បំណុលពន្ធពន្យារ - សុទ្ធ	២៩(ខ)	២.១៣៤.៨៥៦	៨.៥៦៧.១៧៧	២.១៣៤.៨៥៦	៨.៥៩២.៩៩៥
បំណុលសរុប		៥០៧.៣៦៩.៦៥៨	២.០៣៦.០៧៤.៤៣៨	៤០៦.៦៨១.៦៤៨	១.៦៣៦.៨៩៣.៦៣២

ធនាគារអតិថិជនបន និងកសិកម្ម

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	២០២៥		២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល (ដែលបានបង្ហាញឡើងវិញ - កំណត់សម្គាល់ ៣៧)
មូលធន					
ដើមទុន	២០	១៣៧.២៣៣.៦០៦	៥៥៦.៤៧៥.៣៣០	១៣៧.២៣៣.៦០៦	៥៥៦.៤៧៥.៣៣០
ដើមទុនផ្សេងៗ	២១	(៣.៩០០.៩៥៦)	(១៥.៣៥១.២៧១)	(៤.៤២១.៧១៧)	(១៧.៤៤០.០៤៣)
ដើមទុនបម្រុង	២២	៣.៩៨៨.៥៨៩	១៦.២០១.៨៨០	៣.២៧២.០២៦	១៣.៣២៧.៧៤៦
ទុនបម្រុងតាមបទប្បញ្ញត្តិ	២៣	៣១.៦៨៥.២៨៦	១២៨.៣២៣.៤៧៦	១២.៧៩១.៣៩៦	៥២.៥៤០.០៨៣
(ខាត)/ចំណេញបង្គរ		(៤.៩៦៨.០១៤)	(១៨.៣៨៥.៩២២)	១៥.៦៨២.៣៧២	៦៤.៤៤២.៧៧៨
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(៨.៩៧៦.៩៤៨)	-	(៧.០០១.២១៩)
មូលធនសរុប		១៦៤.០៣៨.៥១១	៦៥៨.២៨៦.៥៤៥	១៦៤.៥៥៧.៦៨៣	៦៦២.៣៤៤.៦៧៥
បំណុល និងមូលធនសរុប		៦៧១.៤០៨.១៦៩	២.៦៩៤.៣៦០.៩៨៣	៥៧១.២៣៩.៣៣១	២.២៩៩.២៣៨.៣០៧

កំណត់សម្គាល់ដែលមានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍លទ្ធផលលម្អិត
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	២០២៥		២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល (ដែលបានបង្ហាញឡើងវិញ - កំណត់សម្គាល់ ៣៧)
ចំណូលការប្រាក់	២៤	២៩.៧៩៨.៣៦៤	១១៩.៥២១.២៣៨	២៦.១១៧.៥១៤	១០៦.៣២៤.៣៩៩
ចំណាយការប្រាក់	២៥	(៤.៥៨៨.១៤៥)	(១៨.៤០៣.០៥០)	(៣.១៤៥.៩៩២)	(១២.៨០៧.៣៣៣)
ចំណូលការប្រាក់សុទ្ធ		២៥.២១០.២១៩	១០១.១១៨.១៨៨	២២.៩៧១.៥២២	៩៣.៥១៧.០៦៦
ចំណូលផ្សេងៗ	២៦	៤៣៩.៤៥៩	១.៧៦២.៦៧០	៨៣.៨៣៨	៣៤១.៣០៤
ចំណូលពីប្រតិបត្តិការ		២៥.៦៤៩.៦៧៨	១០២.៨៨០.៨៥៨	២៣.០៥៥.៣៦០	៩៣.៨៥៨.៣៧០
ចំណាយបុគ្គលិក	២៧	(៩.៧៨០.៣២២)	(៣៩.២២៨.៨៧២)	(៧.៧៤០.០៨៤)	(៣១.៥០៩.៨៨២)
រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី		(៤.៥១១.៣៥៥)	(១៨.០៩៥.០៤៥)	(៤.៤៣៥.៤៤៩)	(១៨.០៥៦.៧១៣)
ចំណាយប្រតិបត្តិការផ្សេងៗ	២៨	(៨.២២៣.៥៩៣)	(៣២.៩៨៤.៨៣២)	(៧.៦៨៤.១៤១)	(៣១.២៨២.១៣៨)
ចំណាយពន្ធអប្បបរមា	២៩(ក)	(២៨៧.១៩២)	(១.១៥១.៩២៧)	(២៥២.៤៩១)	(១.០២៧.៨៩១)
ចំណេញប្រតិបត្តិការមុនការខាតបង់ឱនភាពតម្លៃ		២.៨៤៧.២១៦	១១.៤២០.១៨២	២.៩៤៣.១៩៥	១១.៩៨១.៧៤៦
ការខាតបង់ឱនភាពតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ		(៤.៦០៣.៧១២)	(១៨.៤៦៥.៤៨៩)	(២.១៤០.៩២៦)	(៨.៧១៥.៧១០)
(ខាត)/ចំណេញមុនបង់ពន្ធ		(១.៧៥៦.៤៩៦)	(៧.០៤៥.៣០៧)	៨០២.២៦៩	៣.២៦៦.០៣៦
ចំណាយពន្ធលើប្រាក់ចំណូល	២៩(ក)	-	-	(២.៣៩៦.០៤៥)	(៩.៧៥៤.២៩៩)
ខាតសម្រាប់ការិយបរិច្ឆេទ		(១.៧៥៦.៤៩៦)	(៧.០៤៥.៣០៧)	(១.៥៩៣.៧៧៦)	(៦.៤៨៨.២៦៣)
ខាតលម្អិតផ្សេងៗ					
លម្អៀងពីការប្តូរូបិយប័ណ្ណ		-	(១.៩៧៥.៧២៩)	-	(៩.៩០២.៥៩៩)
ខាតលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ		(១.៧៥៦.៤៩៦)	(៩.០២១.០៣៦)	(១.៥៩៣.៧៧៦)	(១៦.៣៩០.៨៦២)

កំណត់សម្គាល់ដែលមានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍បម្រែបម្រួលមូលធន
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	ដើមទុន		ដើមទុនផ្សេងៗ		ដើមទុនបម្រុង		ទុនបម្រុងតាមបទប្បញ្ញត្តិ		ចំណេញ/(ខាត)បង្គរ		លម្អៀងពីការប្តូរប្រាក់	សរុប	
	ជុំលារអាមេរិក	ពាន់រៀល	ជុំលារអាមេរិក	ពាន់រៀល	ជុំលារអាមេរិក	ពាន់រៀល	ជុំលារអាមេរិក	ពាន់រៀល	ជុំលារអាមេរិក	ពាន់រៀល	ពាន់រៀល	ជុំលារអាមេរិក	ពាន់រៀល
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៥	១៣៧.២៣៣.៦០៦	៥៥៦.៤៧៥.៣៣០	(៤.៤២១.៧១៧)	(១៧.៤៤០.០៤៣)	៣.២៧២.០២៦	១៣.៣២៧.៧៤៦	១២.៧៩១.៣៩៦	៥២.៥៤០.០៨៣	១៥.៦៨២.៣៧២	៦៤.៤៤២.៧៧៨	(៧.០០១.២១៩)	១៦៤.៥៥៧.៦៨៣	៦៦២.៣៤៤.៦៧៥
ចំណេញលម្អិតសរុប													
ខាតសម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	-	-	(១.៧៥៦.៤៩៦)	(៧.០៤៥.៣០៧)	-	(១.៧៥៦.៤៩៦)	(៧.០៤៥.៣០៧)
ខាតលម្អិតផ្សេងៗ	-	-	-	-	-	-	-	-	-	-	(១.៩៧៥.៧២៩)	-	(១.៩៧៥.៧២៩)
ខាតលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	-	-	(១.៧៥៦.៤៩៦)	(៧.០៤៥.៣០៧)	(១.៩៧៥.៧២៩)	(១.៧៥៦.៤៩៦)	(៩.០២១.០៣៦)
ប្រតិបត្តិការដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន													
ផ្ទេរពីចំណេញបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	-	-	-	-	១៨.៨៩៣.៨៩០	៧៥.៧៨៣.៣៩៣	(១៨.៨៩៣.៨៩០)	(៧៥.៧៨៣.៣៩៣)	-	-	-
ផ្ទេរពីដើមទុនបម្រុងទៅដើមទុនផ្សេងៗ	-	-	៣៧៩.៧៨០	១.៥២៣.១៣៧	(៣៧៩.៧៨០)	(១.៥២៣.១៣៧)	-	-	-	-	-	-	-
ផ្ទេរទៅដើមទុនផ្សេងៗ	-	-	១៨១.០២១	៥៦៥.៦៣៥	-	-	-	-	-	-	-	១៨១.០២១	៥៦៥.៦៣៥
ការទូទាត់ប្រាក់ដើម	-	-	-	-	១.០៩៦.៣០៣	៤.៣៩៧.២៧១	-	-	-	-	-	១.០៩៦.៣០៣	៤.៣៩៧.២៧១
	-	-	៥២០.៧៦១	២.០៨៨.៧៧២	៧១៦.៥៦៣	២.៨៧៤.១៣៨	១៨.៨៩៣.៨៩០	៧៥.៧៨៣.៣៩៣	(១៨.៨៩៣.៨៩០)	(៧៥.៧៨៣.៣៩៣)	-	១.២៣៧.៣២៤	៤.៩៦២.៩០៦
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥	១៣៧.២៣៣.៦០៦	៥៥៦.៤៧៥.៣៣០	(៣.៩០០.៩៥៦)	(១៥.៣៥១.២៧១)	៣.៩៨៨.៥៨៩	១៦.២០១.៨៨០	៣១.៦៨៥.២៨៦	១២៨.៣២៣.៤៧៦	(៤.៩៦៨.០១៤)	(១៨.៣៨៥.៩២២)	(៨.៩៧៦.៩៤៨)	១៦៤.០៣៨.៥១១	៦៥៨.២៨៦.៥៤៥

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍បម្រែបម្រួលមូលធន
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	ដើមទុន		ដើមទុនផ្សេងៗ		ដើមទុនបម្រុងទុក		ទុនបម្រុងតាមបទប្បញ្ញត្តិ		ចំណេញបង្គរ		លម្អៀងពីការប្តូរប្រាក់បរទេស	សរុប	
	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល
នាថ្ងៃទី១ ខែមករា ឆ្នាំ២០២៤	១៣៧.២៣៣.៦០៦	៥៥៦.៨៧៥.៣៣០	(៤.៤២១.៧១៧)	(១៧.៨៤០.០៤៣)	៣.២៧២.០២៦	១៣.៣២៧.៧៨៦	៥.៨៨១.៨៧៨	២៨.២៨៨.៥៧៩	២៨.៧១៣.២៦៧	១០១.២០៧.៥៥២	២.៩០១.៣៨០	១៦៦.៦៣៩.០៥៦	៦៨០.៧២០.៥៨៨
ខាតលម្អិតសរុប													
ខាតសម្រាប់ការិយបរិច្ឆេទ (ដូចដែលបានបង្ហាញឡើងវិញ - កំណត់សម្គាល់ ៣៧)	-	-	-	-	-	-	-	-	(១.៥៩៣.៧៧៦)	(៦.៨៨៨.២៦៣)	-	(១.៥៩៣.៧៧៦)	(៦.៨៨៨.២៦៣)
ខាតលម្អិតផ្សេងៗ	-	-	-	-	-	-	-	-	-	-	(៩.៩០២.៥៩៩)	-	(៩.៩០២.៥៩៩)
ខាតលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ	-	-	-	-	-	-	-	-	(១.៥៩៣.៧៧៦)	(៦.៨៨៨.២៦៣)	(៩.៩០២.៥៩៩)	(១.៥៩៣.៧៧៦)	(១៦.៣៩០.៨៦២)
ប្រតិបត្តិការដែលត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន													
ផ្ទេរពីចំណេញបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	-	-	-	-	៦.៩៨៩.៥២២	២៨.២៩១.៥០៤	(៦.៩៨៩.៥២២)	(២៨.២៩១.៥០៤)	-	-	-
ការចែករំលែកប្រាក់ចំណេញដែលបានប្រកាស*	-	-	-	-	-	-	-	-	(៤៨៧.៥៩៧)	(១.៩៨៥.០០៧)	-	(៤៨៧.៥៩៧)	(១.៩៨៥.០០៧)
	-	-	-	-	-	-	៦.៩៨៩.៥២២	២៨.២៩១.៥០៤	(៧.៤៣៧.១៩៩)	(៣០.២៧៦.៥១១)	-	(៤៨៧.៥៩៧)	(១.៩៨៥.០០៧)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ (ដូចដែលបានបង្ហាញឡើងវិញ - កំណត់សម្គាល់ ៣៧)	១៣៧.២៣៣.៦០៦	៥៥៦.៨៧៥.៣៣០	(៤.៤២១.៧១៧)	(១៧.៨៤០.០៤៣)	៣.២៧២.០២៦	១៣.៣២៧.៧៨៦	១២.៧៩១.៣៩៦	៥២.៥៤០.០៨៣	១៥.៦៨២.៣៧២	៦៤.៤៤២.៧៧៨	(៧.០០១.២១៩)	១៦៤.៥៥៧.៦៨៣	៦៦២.៣៤៤.៦៧៥

* នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២២ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុម័តអនុស្សរណៈនៃលក្ខន្តិក: និងសមាគម ដើម្បីកាត់ការបែងចែកប្រាក់ចំណេញប្រចាំឆ្នាំសម្រាប់បុគ្គលិកដោយផ្ទាល់ពីប្រាក់ចំណេញរក្សាទុក ដោយមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២២។

កំណត់សម្គាល់ដែលមានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍លំហូរសាច់ប្រាក់
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	២០២៥		២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល (ដែលបានបង្ហាញឡើងវិញ - កំណត់សម្គាល់ ៣៧)
លំហូរសាច់ប្រាក់ពី					
សកម្មភាពប្រតិបត្តិការ					
(ខាត)/ចំណេញសម្រាប់ការិយបរិច្ឆេទ		(១.៧៥៦.៤៩៦)	(៧.០៤៥.៣០៧)	៨០២.២៦៩	៣.២៦៦.០៣៦
<u>និយ័តកម្មលើ៖</u>					
រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី		៤.៥១១.៣៥៥	១៨.០៩៥.០៤៥	៤.៤៣៥.៤៤៩	១៨.០៥៦.៧១៣
ការខាតបង់ឱនភាពតម្លៃលើទ្រព្យសម្បត្តិបានរឹបអូស	៨	-	-	២៩៦.៧៩៨	១.២០៨.២៦៥
ការខាតបង់សុទ្ធពីឱនភាពតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ		៤.៦០៣.៧១២	១៨.៤៦៥.៤៨៩	២.១៤០.៩២៦	៨.៧១៥.៧១០
ចំណូលការប្រាក់សុទ្ធ		(២៥.២១០.២១៩)	(១០១.១១៨.១៨៨)	(២២.៩៧១.៥២២)	(៩៣.៥១៧.០៦៦)
ចំណេញពីការលក់ទ្រព្យសម្បត្តិបានរឹបអូស	២៦	(៩៩.០៦០)	(៣៩៧.៣៣០)	-	-
ខាតប្រតិបត្តិការមុនបម្រែបម្រួលទុនបង្វិល		(១៧.៩៥០.៧០៨)	(៧២.០០០.២៩១)	(១៥.២៩៦.០៨០)	(៦២.២៧០.៣៤២)
<u>បម្រែបម្រួលសុទ្ធក្នុង៖</u>					
ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ		(១.៦៥៥.២១៧)	(៦.៦៣៩.០៧៥)	(១.៣៨៤.៣៥៩)	(៥.៤៧២.៨៨៥)
ឥណទាន និងបុរេប្រទានទៅអតិថិជន		(៨០.៤៦៧.៧៦២)	(៣២២.៧៥៦.១៩៣)	(៩៥.៩៧៤.៤៩៥)	(៣៩០.៧១២.១៦៩)
ទ្រព្យសកម្មផ្សេងៗ		១.៤៤៩.៣៦០	៥.៨១៣.៣៨៣	(៩២០.៣៩៨)	(៣.៧៨៦.៩៤១)
សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យសម្បត្តិបានរឹបអូស		៤០០.០០០	១.៦០៤.៤០០	-	-
ប្រាក់បញ្ញើពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ		៥២.៣៨៤.២៨៦	២០៩.៩៥២.៧៧១	៤.២៥៧.០៨៩	១៧.៣៣០.៦០៩
ប្រាក់បញ្ញើពីអតិថិជន		(៣៨.៩៥៩)	(១៥៦.២៦៥)	៥៥.៧១៣	២២៦.៨០៨
បំណុលផ្សេងៗ		៤៤៣.២២៦	១.៧៧៧.៧៧៩	(១.៤៥៦.៨៤៤)	(៥.៩៣០.៨១២)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងប្រតិបត្តិការ		(៤៥.៤៧៥.៨១៤)	(១៨២.៤០៣.៤៩១)	(១១០.៦៧៩.៣៧៤)	(៤៥០.៥៧៥.៧៣២)

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

របាយការណ៍លំហូរសាច់ប្រាក់
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

	កំណត់សម្គាល់	២០២៥		២០២៤	
		ដុល្លារអាមេរិក	ពាន់រៀល	ដុល្លារអាមេរិក	ពាន់រៀល (ដែលបានបង្ហាញឡើងវិញ - កំណត់សម្គាល់ ៣៧)
ការប្រាក់ដែលបានទទួល		២៨.៣៥៥.១៣៦	១១៣.៧៣២.៤៥០	២៦.១៣៣.៧៥០	១០៦.៣៩០.៤៩៦
ការប្រាក់ដែលបានបង់		(៣.៩១៧.៤៧០)	(១៥.៧១២.៩៧២)	(២.៩៦០.១២៩)	(១២.០៥០.៦៨៥)
ពន្ធលើប្រាក់ចំណូលដែលបានបង់		(៥១១.៦៧៤)	(២.០៥២.៣២៤)	(១.៤៥៧.៥៦២)	(៥.៩៣៣.៧៣៥)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ		(២១.៥៤៩.៨២២)	(៨៦.៤៣៦.៣៣៧)	(៨៨.៩៦៣.៣១៥)	(៣៦២.១៦៩.៦៥៦)
លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ					
ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ	១៣	(៥.៣៩៩.១៨៤)	(២១.៦៥៥.៩៦៧)	(៤.៨៩៣.៣១៦)	(១៩.៩២០.៦៨៩)
ការទិញទ្រព្យសកម្មអរូបី	១៤	(២.៥១៨.២៧៤)	(១០.១០០.៧៩៧)	(១.៩៦៥.៩៩០)	(៨.០០៣.៥៤៥)
សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ		(៧.៩១៧.៤១៨)	(៣១.៧៥៦.៧៦៤)	(៦.៨៥៩.៣០៦)	(២៧.៩២៤.២៣៤)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី	១៧	៧១.៥៧៧.៨៩៧	២៨៧.០៩៨.៩៤៥	១០១.៦៥០.៨៥៣	៤១៣.៨២០.៦២៣
ការទូទាត់ប្រាក់កម្ចី	១៧	(២៣.៦៦៧.៥៥៥)	(៩៤.៩៣០.៥៦៣)	-	-
ការទូទាត់បំណុលភតិសន្យា	១២	(១៣០.០០០)	(៥២១.៤៣០)	(១២០.៤០០)	(៤៩០.១៤៨)
សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន		៤៧.៧៨០.៣៤២	១៩១.៦៤៦.៩៥២	១០១.៥៣០.៤៥៣	៤១៣.៣៣០.៤៧៥
បម្រែបម្រួលសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ		១៨.៣១៣.១០២	៧៣.៤៥៣.៨៥១	៥.៧០៧.៨៣២	២៣.២៣៦.៥៨៥
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាដើមការិយបរិច្ឆេទ		២២.៧៩៦.៧០៣	៩១.៧៥៦.៧២៩	១៧.០៨៨.៨៧១	៦៩.៨០៨.០៣៨
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	(២៣៦.៩៣២)	-	(១.២៨៧.៨៩៤)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាចុងការិយបរិច្ឆេទ	៣១	៤១.១០៩.៨០៥	១៦៤.៩៧៣.៦៤៨	២២.៧៩៦.៧០៣	៩១.៧៥៦.៧២៩

កំណត់សម្គាល់ដែលមានភ្ជាប់មកជាមួយ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុ។

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥

១. ព័ត៌មានអំពីធនាគារ

ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ហៅកាត់ថា "ធនាគារ") គឺជាអង្គភាពដែលគ្រប់គ្រងដោយរដ្ឋាភិបាលទាំងស្រុង បង្កើតឡើងដោយអនុក្រឹត្យ (អនុក្រឹត្យលេខ ១ អនក្រ. បក) ដោយមានគោលបំណងលើកកម្ពស់សកម្មភាពសេដ្ឋកិច្ចកសិកម្ម និងជនបទ ដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារបានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្ម ក្រោមវិញ្ញាបនបត្រលេខ Co. ៣៩៤២Et/១៩៩៨ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ១៩៩៨។ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២០ ធនាគារបានចុះបញ្ជីរួចរាល់ ជាមួយវិញ្ញាបនបត្រលេខ ០៣២៧ ដែលចេញដោយក្រសួងពាណិជ្ជកម្ម។ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ ធនាគារបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីដំណើរការជាធនាគារពាណិជ្ជកម្ម។

អាសយដ្ឋានចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅ អគារលេខ ១៦៨ ផ្លូវបេតុងលេខ៧ ភូមិព្រែកលៀប សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺជាធនាគារពាណិជ្ជ និងផ្តល់សេវាកម្មហិរញ្ញវត្ថុដែលពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ពុំមានការផ្លាស់ប្តូរជាសារវន្តនៃសកម្មភាពអាជីវកម្មចម្បងទាំងនេះក្នុងអំឡុងការិយបរិច្ឆេទនេះឡើយ។

២. មូលដ្ឋាននៃការរៀបចំ

២.១ របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (ហៅកាត់ថា "ស.រ.ទ.ហ.អ.ក")។

២.២ មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងតាមវិធីសាស្ត្រថ្លៃដើម លើកលែងតែមានបង្ហាញផ្សេងពីនេះនៅក្នុងកំណត់សម្គាល់ ៣ នៃរបាយការណ៍ហិរញ្ញវត្ថុ។

២.៣ ការអនុវត្ត ស.រ.ទ.ហ.អ.ក ថ្មី និងការធ្វើវិសោធនកម្ម ឬការកែសម្រួល ស.រ.ទ.ហ.អ.ក

(ក) វិសោធនកម្ម ឬការកែសម្រួលស្តង់ដាដែលបានអនុវត្តក្នុងការិយបរិច្ឆេទ

វិសោធនកម្ម ឬការកែសម្រួលស្តង់ដាខាងក្រោមនេះ ត្រូវបានអនុវត្តដោយធនាគារ ប៉ុន្តែមិនមានផលប៉ះពាល់ជាសារវន្តទៅលើការិយបរិច្ឆេទបច្ចុប្បន្ន ឬលើការិយបរិច្ឆេទមុនៗ ហើយក៏មិនមានផលប៉ះពាល់ដល់ការិយបរិច្ឆេទនាពេលអនាគតឡើយ។

- កង្វះខាតនៃការផ្លាស់ប្តូរ - វិសោធនកម្មទៅលើ ស.គ.អ.ក ២១

២. មូលដ្ឋាននៃការរៀបចំ (ត)

២.៣ ការអនុវត្ត ស.រ.ទ.ហ.អ.ក ថ្មី និងការធ្វើវិសោធនកម្ម ឬការកែសម្រួល ស.រ.ទ.ហ.អ.ក (ត)

(ខ) ស្តង់ដា និងវិសោធនកម្ម/ការកែសម្រួលដែលបានចេញផ្សាយតែមិនទាន់ចូលជាធរមាន

		ថ្ងៃចូលជាធរមាន សម្រាប់ការិយបរិច្ឆេទ ចាប់ផ្តើម ឬបន្ទាប់
<u>ស្តង់ដាថ្មី</u>		
ស.រ.ហ.អ.ក ១៨	ការបង្ហាញ និងការលាតត្រដាងរបាយការណ៍ហិរញ្ញវត្ថុ	ថ្ងៃទី១ ខែមករា ឆ្នាំ២០២៧
<u>វិសោធនកម្ម/ការកែសម្រួល</u>		
ស.រ.ហ.អ.ក ៧ និង ស.រ.ហ.អ.ក ៩	វិសោធនកម្មលើការចាត់ថ្នាក់ និងវាស់វែងឧបករណ៍ហិរញ្ញវត្ថុ	ថ្ងៃទី១ ខែមករា ឆ្នាំ២០២៦

ធនាគារនៅមិនទាន់បានអនុវត្តនូវស្តង់ដា និងវិសោធនកម្មថ្មីទាំងនេះ មុនកាលកំណត់នៅឡើយទេ។ បច្ចុប្បន្ននេះ ធនាគារកំពុងធ្វើការវាយតម្លៃពីផលប៉ះពាល់ ថាតើស្តង់ដាទាំងនេះនឹងមានឥទ្ធិពលលើរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដែរ ឬទេ។ ដោយផ្អែកលើវិសាលភាពនៃ ស.រ.ហ.អ.ក ១៨ វាត្រូវបានរំពឹងថា មានផលប៉ះពាល់ជាសារវន្តទៅលើការបង្ហាញ និងការលាតត្រដាងនៅក្នុងរបាយការណ៍ចំណេញ ឬខាតនាពេលអនាគត។

២.៤ រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយប័ណ្ណជាតិនៃប្រទេសកម្ពុជា គឺប្រាក់រៀល។ ប៉ុន្តែដោយសារតែធនាគារមានប្រតិបត្តិការអាជីវកម្ម និងរក្សាកំណត់ត្រាបញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ក្រុមប្រឹក្សាភិបាលក៏បានកំណត់ដុល្លារអាមេរិកជារូបិយប័ណ្ណគោលរបស់ធនាគារ ក្នុងការវាស់វែង និងបង្ហាញដែលឆ្លុះបញ្ចាំងពីស្ថានភាពសេដ្ឋកិច្ចនៃព្រឹត្តិការណ៍ និងស្ថានភាពរបស់ធនាគារ។

ការប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំដោយអនុលោមទៅតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយបានប្រើប្រាស់អត្រាប្តូរប្រាក់បិទប្រចាំឆ្នាំ និងអត្រាប្តូរប្រាក់មធ្យមផ្លូវការដោយ ១ដុល្លារអាមេរិក ស្មើនឹង ៤.០១៣រៀល និង ១ដុល្លារអាមេរិក ស្មើនឹង ៤.០១១រៀល រៀងគ្នា សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ (ឆ្នាំ២០២៤៖ ៤.០២៥ រៀល និង ៤.០៧១ រៀល) ដូចដែលបានប្រកាសដោយធនាគារជាតិនៃកម្ពុជា។

ការប្តូរប្រាក់នេះ មិនគួរត្រូវបានប្រើប្រាស់ជាតំណាងឱ្យចំនួនទឹកប្រាក់ដុល្លារអាមេរិកដែលត្រូវបាន ឬអាចត្រូវបាន ឬនឹងប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ដទៃទៀតឡើយ។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត

ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត ដែលបានអនុវត្តនៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានចែងដូចខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានអនុវត្តដោយមានសង្គតិភាពគ្រប់ការិយបរិច្ឆេទ ដែលត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ លើកលែងតែមានការបង្ហាញផ្សេងពីនេះ។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

(១) ការវាស់វែងដំបូង

ធនាគារទទួលស្គាល់ជាលើកដំបូងនូវឥណទាន និងបុរេប្រទាន ប្រាក់កម្ចី និងបំណុលបន្ទាប់បន្សំនៅកាលបរិច្ឆេទដែលកើតមានប្រតិបត្តិការ។ រាល់ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (រួមបញ្ចូលទាំងវិធីសាស្ត្រក្នុងការទិញ និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ) ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទប្រតិបត្តិការ ដែលជាថ្ងៃដែលធនាគារក្លាយជាភាគីនៃសំវិធានធនកិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប បូករួមទាំងថ្លៃដើមប្រតិបត្តិការដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការទិញ ឬការចេញផ្សាយ ប្រសិនបើវត្ថុនោះមិនត្រូវបានវាស់វែងតាមតម្លៃសមរម្យតាមរយៈរបាយការណ៍ចំណេញ ឬខាត (“FVTPL”)។

(២) ការធ្វើចំណាត់ថ្នាក់

<u>ទ្រព្យសកម្មហិរញ្ញវត្ថុ</u>

នៅក្នុងការទទួលស្គាល់ដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចាត់ថ្នាក់តាមការវាស់វែង៖ តាមថ្លៃដើមរំលស់ ឬតម្លៃសមស្របតាមរយៈលទ្ធផលលម្អិតផ្សេងៗ (“FVOCI”) ឬ FVTPL ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមតាមថ្លៃដើមរំលស់ ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មត្រូវបានកាន់កាប់ក្នុងគម្រូអាជីវកម្ម ដែលមានគោលបំណងកាន់កាប់ទ្រព្យសកម្ម ដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលប្រើសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (“SPPI”) ។

បំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមតាម FVOCI ប្រសិនបើវាបំពេញទៅនឹងលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មត្រូវបានកាន់កាប់ក្នុងគម្រូអាជីវកម្ម ដែលមានគោលបំណងត្រូវបានសម្រេចតាមរយៈទាំងការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលប្រើសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ (“SPPI”) ។

ការទទួលស្គាល់ដំបូងនៃការវិនិយោគមូលធន ដែលមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ធនាគារអាចធ្វើការជ្រើសរើសដើម្បីបង្ហាញពីការផ្លាស់ប្តូរជាបន្តបន្ទាប់នៃតម្លៃសមស្របនៅក្នុងOCI។ ការជ្រើសរើសនេះត្រូវបានធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃការវិនិយោគនីមួយៗ។

រាល់ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ត្រូវបានចាត់ថ្នាក់ជាការវាស់វែងតាមតម្លៃសមស្របតាមរយៈ FVTPL។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(២) ការធ្វើចំណាត់ថ្នាក់

ការវាយតម្លៃគម្រូអាជីវកម្ម

ធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃគម្រូអាជីវកម្ម ដែលទ្រព្យសកម្មត្រូវបានកាន់កាប់នៅកម្រិតផលបត្រ ព្រោះវាឆ្លុះបញ្ចាំងយ៉ាងល្អបំផុតពីមធ្យោបាយដែលអាជីវកម្មត្រូវបានគ្រប់គ្រង និងព័ត៌មានដែលបានផ្តល់ទៅគណៈគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលការណ៍ និងគោលបំណងដែលបានបញ្ជាក់សម្រាប់កម្រិតផលបត្រ និងអនុវត្តនូវគោលការណ៍ទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់គណៈគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ភាពស៊ីសង្វាក់រវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុទៅនឹងរយៈពេលនៃបំណុល ដែលផ្តល់មូលនិធិដល់ទ្រព្យសកម្មទាំងនោះ ឬទទួលបានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- វិធីសាស្ត្រក្នុងការវាយតម្លៃលទ្ធផលនៃកម្រិតផលបត្រ និងការរាយការណ៍ទៅគណៈគ្រប់គ្រងរបស់ធនាគារ
- ហានិភ័យដែលប៉ះពាល់ដល់លទ្ធផលនៃគម្រូអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកាន់កាប់ នៅក្នុងគម្រូអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលគណៈគ្រប់គ្រងរបស់អាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ ថាតើតម្លៃតបស្នង ផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលប្រមូលបាន) និងភាពញឹកញាប់ បរិមាណ និងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់នោះ និងការរំពឹងទុកអំពីសកម្មភាពលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពនៃការលក់មិនត្រូវបានគិតដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃរួម អំពីរបៀបដែលធ្វើឱ្យសម្រេចបាននូវគោលបំណងក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានកាន់កាប់ក្នុងគោលបំណងជួញដូរ ឬត្រូវបានគ្រប់គ្រង ហើយលទ្ធផលត្រូវបានវាយតម្លៃលើមូលដ្ឋាននៃតម្លៃសមស្រប គឺត្រូវបានវាស់វែងតាមតម្លៃសមស្របតាមរយៈFVTPL ពីព្រោះទ្រព្យសកម្មទាំងនោះមិនមែនកាន់កាប់ដើម្បីប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា ហើយក៏មិនមែនកាន់កាប់ដើម្បីទាំងការប្រមូលលំហូរសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុនោះដែរ។

ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺសម្រាប់តែការទូទាត់ប្រាក់ដើម និងការប្រាក់

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុក្នុងការទទួលស្គាល់ជាលើកដំបូង។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់តម្លៃនៃពេលវេលា និងសម្រាប់ហានិភ័យឥណទានដែលពាក់ព័ន្ធនឹងសមតុល្យប្រាក់ដើម ដែលនៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ហានិភ័យក្នុងកម្ចី និងចំណាយលើប្រាក់ថ្មីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ទនីយភាព និងចំណាយរដ្ឋបាល) រួមទាំងកម្រិតប្រាក់ចំណេញ។

ដើម្បីវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យា គឺសម្រាប់តែទូទាត់ប្រាក់ដើម និងការប្រាក់ ធនាគារត្រូវពិចារណាលក្ខខណ្ឌ កិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ។ រួមបញ្ចូលការវាយតម្លៃថាតើ ទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលមិនអាចបំពេញលក្ខខណ្ឌនេះ។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(២) ការធ្វើចំណាត់ថ្នាក់

ក្នុងការវាយតម្លៃ ធនាគារពិចារណាលើ៖

- ព្រឹត្តិការណ៍យថាហេតុដែលអាចផ្លាស់ប្តូរសមតុល្យ និងរយៈពេលនៃលំហូរសាច់ប្រាក់
- លក្ខខណ្ឌអានុភាព
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌដែលកម្រិតធនាគារ ក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជាឥណទានដែលមិនអាចប្រមូលមកវិញបាន) និង
- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីតម្លៃពេលវេលានៃសាច់ប្រាក់ (ឧទាហរណ៍៖ ការកំណត់អត្រាការប្រាក់ឡើងវិញតាមកាលកំណត់)។

<u>ការធ្វើចំណាត់ថ្នាក់ឡើងវិញ</u>

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចំណាត់ថ្នាក់ឡើងវិញ បន្ទាប់ពីការទទួលស្គាល់តម្លៃដំបូងឡើយ លើកលែងតែក្នុងអំឡុងពេល ដែលធនាគារផ្លាស់ប្តូរគម្រូអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

(៣) ការឈប់ទទួលស្គាល់

<u>ទ្រព្យសកម្មហិរញ្ញវត្ថុ</u>

ធនាគារឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ ឬការផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលហានិភ័យទាំងអស់ និងអត្ថប្រយោជន៍នៃភាពជាម្ចាស់កម្មសិទ្ធិនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវរាល់ហានិភ័យ និងភាពជាម្ចាស់កម្មសិទ្ធិ ហើយវាមិនរក្សាការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

ចំពោះការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពខុសគ្នារវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i) តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលបានដកបំណុលថ្មីដែលបានសន្មត) និង (ii) ចំណេញ ឬខាតដែលបានទទួលស្គាល់ក្នុង របាយការណ៍លទ្ធផលលម្អិតផ្សេង។ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត។

<u>បំណុលហិរញ្ញវត្ថុ</u>

ធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចក្រោមកិច្ចសន្យាត្រូវបានរំលាយ ឬលុបចោល ឬផុតកំណត់។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(៤) ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះធនាគារវាយតម្លៃថាតើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះមានភាពខុសគ្នាខ្លាំង ដែរឬទេ។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាពីទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវបានចាត់ទុកថាផុតកំណត់។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើមត្រូវឈប់ទទួលស្គាល់ (សូមមើលចំណុច(៣)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប បូកនឹងថ្លៃចំណាយប្រតិបត្តិការ។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានរាប់បញ្ចូលដូចខាងក្រោម៖

- ថ្លៃសេវា ដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលទទួលបានមកវិញលើថ្លៃចំណាយប្រតិបត្តិការដែលកើតឡើង ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងដំបូងនៃទ្រព្យសកម្ម និងថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងរបាយការណ៍ចំណេញ និងខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើទ្រព្យសកម្ម ដែលឈប់ទទួលស្គាល់។
- ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅ គឺដើម្បីទទួលបានមកវិញជាអតិបរមាលើលក្ខខណ្ឌនៃកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ ទ្រព្យសកម្មនោះត្រូវបានយកមកពិចារណាជាមុន ថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជីមុនពេលធ្វើការកែប្រែ ឬទេ (សូមមើលខាងក្រោមសម្រាប់គោលការណ៍ការលុបចេញពីបញ្ជី)។ វិធីសាស្ត្រនេះជះឥទ្ធិពលដល់លទ្ធផលនៃការវាយតម្លៃបរិមាណ ហើយក្នុងករណីនេះមានន័យថា លក្ខណៈវិនិច្ឆ័យនៃការឈប់ទទួលស្គាល់ទ្រព្យ ជាទូទៅមិនអាចអនុវត្តបាននោះទេ។
- ប្រសិនបើការកែតម្រូវទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមថ្លៃដើមរំលស់ ឬ FVOCI មិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេនោះ នោះធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុនដោយប្រើអត្រាការប្រាក់ប្រសិទ្ធិភាពដើមនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវជាចំណេញ ឬខាតក្នុងរបាយការណ៍ចំណេញ និងខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាអណ្តែត អត្រាការប្រាក់ប្រសិទ្ធិភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន នៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបានដែលជាផ្នែកមួយនៃការកែតម្រូវទាក់ទងនឹងតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានធ្វើការកែតម្រូវ ត្រូវបានរំលស់ផ្នែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវនោះ។
- ប្រសិនបើការកែតម្រូវនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពតម្លៃ។ ក្នុងករណីផ្សេងទៀត វាត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធិភាព។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(៤) ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

<u>បំណុលហិរញ្ញវត្ថុ</u>

ធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែតម្រូវ ហើយលំហូរសាច់ប្រាក់នៃបំណុល ដែលបានកែតម្រូវនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មី ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពខុសគ្នារវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលមិនត្រូវបានទទួលស្គាល់ និងតម្លៃតបស្នង ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត។ តម្លៃតបស្នងរួមមានទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ ប្រសិនបើមាន និងការសន្មតបំណុល រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែតម្រូវថ្មី។

ប្រសិនបើការកែតម្រូវបំណុលហិរញ្ញវត្ថុនេះ មិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេ នោះរំលស់ថ្លៃដើមនៃបំណុលត្រូវគណនាឡើងវិញ ដោយធ្វើអប្បហារលំហូរសាច់ប្រាក់ដែលបានកែប្រែតាមអត្រាការប្រាក់ប្រសិទ្ធិភាពដំបូង ហើយលទ្ធផលនៃការចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ និងខាត។ សម្រាប់បំណុលហិរញ្ញវត្ថុមានអត្រាការប្រាក់អណ្តែត អត្រាការប្រាក់ប្រសិទ្ធិភាពដំបូងដែលប្រើដើម្បីគណនាចំណេញ ឬខាតពីការកែតម្រូវ ត្រូវបានកែប្រែដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែតម្រូវ។ រាល់ការចំណាយ និងថ្លៃសេវាដែលកើតមានត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងរំលស់តាមរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុ ដែលបានកែប្រែតម្រូវ ដោយការគណនាអត្រាការប្រាក់ប្រសិទ្ធិភាពលើឧបករណ៍។

(៥) ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ ត្រូវបានកាត់កង និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែធនាគារមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏ទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

(៦) ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាតម្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬតម្លៃដែលបានទូទាត់ចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារ នាកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលធនាគារអាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យមិនមានប្រតិបត្តិការ។

ធនាគារវាស់វែងតម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ដោយប្រើប្រាស់តម្លៃដកស្រង់នៅក្នុងទីផ្សារសកម្មរបស់ឧបករណ៍នោះ ប្រសិនបើមាន។ ទីផ្សារមួយចាត់ទុកជាទីផ្សារសកម្ម ប្រសិនបើប្រតិបត្តិការរបស់ទ្រព្យសកម្ម ឬបំណុល កើតឡើងញឹកញាប់ ហើយទំហំប្រតិបត្តិការមានភាពគ្រប់គ្រាន់ក្នុងការផ្តល់ព័ត៌មានអំពីតម្លៃតាមមូលដ្ឋាននិរន្តភាព។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(៦) ការវាស់វែងតម្លៃសមស្រប

ប្រសិនបើពុំមានការដកស្រង់តម្លៃនៅក្នុងទីផ្សារសកម្មទេ នោះធនាគារត្រូវប្រើបច្ចេកទេសវាយតម្លៃណា ដែលអាចប្រើប្រាស់ទិន្នន័យដែលអាចអង្កេតបានជាអតិបរមា និងកាត់បន្ថយនូវការប្រើប្រាស់ទិន្នន័យដែលមិនអាចអង្កេតបាន។ បច្ចេកទេសវាយតម្លៃដែលបានជ្រើសរើស ត្រូវរួមបញ្ចូលនូវកត្តាទាំងអស់ដែលអ្នកចូលរួមក្នុងទីផ្សារនឹងពិចារណានៅក្នុងការកំណត់តម្លៃ។

ភស្តុតាងដ៏ល្អបំផុត សម្រាប់តម្លៃសមស្របរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ នៅពេលទទួលស្គាល់ជាលើកដំបូង ជាទូទៅ គឺជាតម្លៃប្រតិបត្តិការ ឧទាហរណ៍ តម្លៃសមស្របនៃតម្លៃបស្នង ដែលផ្តល់ឱ្យ ឬបានទទួល។ ប្រសិនបើធនាគារកំណត់ថា តម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង ខុសពីតម្លៃប្រតិបត្តិការហើយតម្លៃសមស្របនេះ ពុំមានភស្តុតាងមកបញ្ជាក់តាមរយៈសម្រង់តម្លៃក្នុងទីផ្សារសកម្ម ចំពោះទ្រព្យសកម្ម ឬបំណុលដែលស្រដៀងគ្នា ឬក៏តាមរយៈបច្ចេកទេសវាយតម្លៃ ដែលក្នុងនោះទិន្នន័យដែលមិនអាចអង្កេតបានពាក់ព័ន្ធនឹងការវាស់វែងត្រូវបានសន្មតថាមិនសារវន្ត ដូច្នេះឧបករណ៍ហិរញ្ញវត្ថុ ត្រូវវាស់វែងជាលើកដំបូងតាមតម្លៃសមស្របដោយកែតម្រូវតាមរយៈការពន្យារនូវភាពខុសគ្នារវាងតម្លៃសមស្របនៅពេលទទួលស្គាល់ជាលើកដំបូង និងតម្លៃប្រតិបត្តិការ។ បន្ទាប់មកទៀត ភាពខុសគ្នានោះគឺត្រូវទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ផ្អែកលើអាយុកាលរបស់ឧបករណ៍នោះ ក៏ប៉ុន្តែមិនឱ្យយូរជាងការវាយតម្លៃតាមរយៈទិន្នន័យទីផ្សារដែលអាចអង្កេតបាន ឬនៅពេលបញ្ចប់ប្រតិបត្តិការនោះទេ។

ប្រសិនបើទ្រព្យសកម្ម ឬបំណុលដែលត្រូវបានវាស់វែងតាមតម្លៃសមស្របមានតម្លៃលក់ និងតម្លៃទិញ នោះធនាគារវាស់វែងទ្រព្យសកម្ម និងស្ថានភាពកាន់កាប់ទិញតាមតម្លៃលក់ ហើយវាស់វែងបំណុល និងស្ថានភាពខ្លីតាមតម្លៃទិញ។

សំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុដែលមានហានិភ័យទីផ្សារ និងហានិភ័យឥណទាន ដែលត្រូវបានចាត់ចែងដោយធនាគារ តាមមូលដ្ឋានចំនួនសុទ្ធដែលមានហានិភ័យទីផ្សារ ឬហានិភ័យឥណទាន ត្រូវបានវាស់វែងតាមមូលដ្ឋាននៃតម្លៃ ដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្មដែលមានស្ថានភាពវែង (ឬការទូទាត់សងក្នុងការផ្ទេរទ្រព្យសកម្មសុទ្ធដែលមានស្ថានភាពខ្លី) សម្រាប់ហានិភ័យជាក់លាក់។ ការកែតម្រូវក្នុងកម្រិតសំណុំទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ មានន័យថា ការកែតម្រូវតម្លៃលក់-ទិញ ឬការកែតម្រូវហានិភ័យឥណទានដែលឆ្លុះបញ្ចាំងពីការវាស់វែងតាមមូលដ្ឋានតម្លៃសុទ្ធ គឺត្រូវបានបែងចែកតាមទ្រព្យសកម្ម និងបំណុលនីមួយៗ តាមមូលដ្ឋានការកែតម្រូវហានិភ័យដែលពាក់ព័ន្ធ នៃឧបករណ៍ហិរញ្ញវត្ថុនីមួយៗនៃទ្រព្យសកម្ម និងបំណុលនោះ នៅក្នុងសំណុំទ្រព្យនោះ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈអាចទាមទារសងតាមតម្រូវការ (ឧទាហរណ៍៖ ប្រាក់បញ្ញើចរន្ត) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវបង់តាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចត្រូវបានបង់។

ធនាគារទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្រប នៅចុងការិយបរិច្ឆេទរាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(៧) ឱនភាពតម្លៃ

ធនាគារទទួលស្គាល់សំវិធានធនលើការខាតបង់ឥណទានរំពឹងទុក ("ECL") ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលជាឧបករណ៍បំណុល និង
- កិច្ចសន្យាឥណទានដែលបានព្រមព្រៀង។

ពុំមានការខាតបង់លើឱនភាពតម្លៃត្រូវបានទទួលស្គាល់នៅក្នុងការវិនិយោគមូលធនឡើយ។

ធនាគារវាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹងការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល លើកលែងតែ គណនីខាងក្រោមដែលត្រូវវាស់វែងតាម ការខាតបង់ឥណទានរំពឹងទុករយៈពេល ១២ខែ៖

- ការវិនិយោគលើមូលបត្របំណុលដែលត្រូវបានកំណត់ថា មានហានិភ័យឥណទានទាបនាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីភតិសន្យាត្រូវទទួល) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

ការខាតបង់ឥណទានរំពឹងទុក ១២ខែ គឺជាផ្នែកនៃការរំពឹងទុកលើការខាតបង់ឥណទាន ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការរំពឹងទុកលើការខាតបង់ឥណទាន ១២ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី១"។

ការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល គឺជាការខាតបង់ឥណទានរំពឹងទុក ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ ក្នុងរយៈពេលនៃអាយុកាលរំពឹងទុកនៃឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាមការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល ប៉ុន្តែមិនមែនជាឥណទានដែលមានឱនភាពនៃតម្លៃ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតនៅក្នុងដំណាក់កាលទី២"។

នៅកាលបរិច្ឆេទរាយការណ៍ ធនាគារវាយតម្លៃថាតើ ហានិភ័យឥណទាននៃឧបករណ៍ហិរញ្ញវត្ថុ បានកើនឡើងជា សារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូងដែរ ឬទេ។ នៅពេលហានិភ័យឥណទានកើតឡើងជាសារវន្ត តាំងពីពេលទទួលស្គាល់ដំបូង សំវិធានធននៃការខាតបង់ ត្រូវបានវាស់វែងស្មើនឹងការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល។

នៅពេលកំណត់ថាតើ ហានិភ័យឥណទាននៃទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង និងនៅពេលប៉ាន់ស្មានលើការខាតបង់ឥណទានរំពឹងទុកនោះ ធនាគារពិចារណាលើព័ត៌មានដែលសមហេតុផល និងព័ត៌មានគាំទ្រ ដែលពាក់ព័ន្ធ និងអាចរកបានដោយមិនចាំបាច់ចំណាយ ឬប្រឹងប្រែងខ្លាំង។ ព័ត៌មានទាំងនេះរួមបញ្ចូលបរិមាណព័ត៌មាន និងគុណភាពព័ត៌មាន និងការវិភាគ ដោយផ្អែកលើបទពិសោធន៍របស់ធនាគារ និងការវាយតម្លៃឥណទានដែលមានស្រាប់ព្រមទាំងរួមបញ្ចូលនូវព័ត៌មានពេលអនាគត។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(ឈ) ឱនភាពតម្លៃ

ប្រសិនបើហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង ឬប្រសិនបើគុណភាពឥណទាននៃឧបករណ៍ហិរញ្ញវត្ថុមានភាពប្រសើរឡើង ដែលបណ្តាលឱ្យគ្មានការកើនឡើងជាសារវន្តនៃហានិភ័យឥណទានចាប់តាំងពីការទទួលស្គាល់លើកដំបូង សំវិធានធនលើការខាតបង់ត្រូវបានវាស់វែងតាមតម្លៃស្មើនឹងការខាតបង់ឥណទានរំពឹងទុករយៈពេល ១២ខែ។

រយៈពេលអតិបរមាដែលត្រូវយកមកពិចារណា ពេលធ្វើការប៉ាន់ស្មានលើការខាតបង់ឥណទានដែលរំពឹងទុក គឺជារយៈពេលកិច្ចសន្យាអតិបរមាដែលធនាគារប្រឈមនឹងហានិភ័យឥណទាន។

<u>ការកំណត់ថាតើ ហានិភ័យឥណទានបានកើនឡើងជាសារវន្តដែរ ឬទេ</u>

ធនាគារវាយតម្លៃថាតើ ហានិភ័យឥណទានបានកើនឡើងជាសារវន្តដែរ ឬទេ ចាប់តាំងពីការទទួលស្គាល់លើកដំបូងនៅរាល់កាលបរិច្ឆេទរាយការណ៍។ ការកំណត់ថាតើការកើនឡើងនៃហានិភ័យឥណទានមានភាពជាសារវន្ត គឺផ្អែកលើលក្ខណៈនៃឧបករណ៍ហិរញ្ញវត្ថុ និងអតិថិជន និងតំបន់ភូមិសាស្ត្រ។

ធនាគារពិចារណាថាការកើនឡើងនៃហានិភ័យឥណទានមានភាពជាសារវន្ត បានកើនឡើងនៅពេលទ្រព្យសកម្មនោះមានការយឺតយ៉ាវក្នុងការសងមិនតិចជាងរយៈពេល៣០ថ្ងៃ។ ចំនួនថ្ងៃយឺតយ៉ាវក្នុងការសងត្រូវបានកំណត់ដោយរាប់ចាប់តាំងពីកាលបរិច្ឆេទផុតកំណត់ដំបូងបង្អស់ នៅពេលដែលការទូទាត់ទាំងស្រុងនៅមិនទាន់បានទទួលដោយធនាគារនៅឡើយ។ កាលបរិច្ឆេទផុតកំណត់សង ត្រូវបានកំណត់ដោយមិនពិចារណាទៅលើរយៈពេលអនុគ្រោះណាមួយដែលអាចមានសម្រាប់អតិថិជននោះឡើយ។

ប្រសិនបើមានភស្តុតាងបញ្ជាក់ថាមិនមានការកើនឡើងលើហានិភ័យឥណទានជាសារវន្តទាក់ទងនឹងការទទួលស្គាល់លើកដំបូងទេនោះ សំវិធានធននៃការបាត់បង់លើឧបករណ៍ហិរញ្ញវត្ថុនឹងត្រូវវាស់វែងតាមការខាតបង់ឥណទានរំពឹងទុក ១២ខែ។

<u>និយមន័យនៃការខកខានសង</u>

ធនាគារចាត់ទុកទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការខកខានសងនៅពេលដែល៖

- អ្នកខ្ចីមិនមានលទ្ធភាពសងចំពោះកាតព្វកិច្ចឥណទានរបស់ខ្លួនទាំងស្រុង ដោយមិនពឹងផ្អែកទៅលើការលក់ទ្រព្យដាក់ធានាដើម្បីទូទាត់សង (ប្រសិនបើមានទ្រព្យដាក់ធានា) ឬ
- ធនាគារពិចារណាថាការកើនឡើងគួរអោយកត់សម្គាល់នូវ ហានីភ័យឥណទានកើតឡើងនិងលើសពីពេលដែលទ្រព្យសកម្មលើស ឬស្មើ ៣០ថ្ងៃ ដែលហួសកំណត់សងសម្រាប់កម្ចីរយៈពេលវែង ឬច្រើនជាងឬស្មើ ១៨ថ្ងៃដែលហួសកាលកំណត់សងសម្រាប់កម្ចីរយៈពេលខ្លី។
- នៅពេលអ្នកខ្ចីនឹងរៀបចំឡើងវិញនូវទ្រព្យសកម្ម ដែលជាលទ្ធផលនៃការក្ស័យធន ដោយសារតែអសមត្ថភាពសងក្នុងកាតព្វកិច្ចឥណទាន។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(៧) ឱនភាពតម្លៃ

ការវាស់វែងការខាតបង់ឥណទានរំពឹងទុក

ការខាតបង់ឥណទានរំពឹងទុក គឺជាការប៉ាន់ស្មានប្រូបាបមធ្យមនៃការបាត់បង់ឥណទាន។ ការខាតបង់ឥណទានរំពឹងទុកត្រូវបានវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះសាច់ប្រាក់ទាំងអស់ (ឧទាហរណ៍៖ ភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់ធនាគារស្របតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលធនាគាររំពឹងទុកថានឹងទទួលបាន)
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងសមតុល្យយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលរំពឹងទុកនាពេលអនាគត
- កិច្ចសន្យាឥណទានដែលមិនបានដក៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជំពាក់ធនាគារ ប្រសិនបើអ្នកកាន់កាប់កិច្ចសន្យាឥណទានបានដកឥណទានប្រើ និងលំហូរសាច់ប្រាក់ដែលធនាគារំពឹងទុកថានឹងទទួលបាន។
- កិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ការទូទាត់ដែលរំពឹងទុកដើម្បីសងប្រាក់ជូនអ្នកកាន់បំណុលដោយដកសមតុល្យណាមួយដែលធនាគារំពឹងថានឹងទទួលបានមកវិញ។

នៅពេលធ្វើអប្បហារលំហូរសាច់ប្រាក់នាពេលអនាគត អត្រាអប្បហារត្រូវបានប្រើប្រាស់ដូចខាងក្រោម ៖

- កិច្ចសន្យាឥណទានដែលមិនបានដក៖ អត្រាការប្រាក់ប្រសិទ្ធភាព ឬតម្លៃប្រហាក់ប្រហែលនឹងអត្រានោះត្រូវអនុវត្តទៅលើទ្រព្យសកម្មហិរញ្ញវត្ថុដែលជាលទ្ធផលពីកិច្ចសន្យាឥណទាន និង
- កិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានចេញ៖ អត្រាដែលឆ្លុះបញ្ចាំងពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលា និងហានិភ័យដែលជាក់លាក់ចំពោះលំហូរសាច់ប្រាក់។

ធាតុចូល ការសន្មត និងបច្ចេកទេសដែលត្រូវបានប្រើសម្រាប់ការប៉ាន់ស្មានឱនភាពតម្លៃ

ធាតុចូលសំខាន់ៗ ក្នុងការវាស់វែងលើការខាតបង់ឥណទានរំពឹងទុក គឺបានមកពីអញ្ញត្រដូចខាងក្រោម៖

- ប្រូបាបនៃការខកខាន ទូទាត់សង (“PD”);
- ការខាតបង់ក្នុងការផ្តល់ឥណទានដែលខកខានទូទាត់សង (“LGD”) និង
- ទំហំនៃការខកខានទូទាត់សង (“EAD”)។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(ឈ) ឱនភាពតម្លៃ

ការខាតបង់ឥណទានរំពឹងទុក សម្រាប់ការបង្ហាញនៅដំណាក់កាលទី១ ត្រូវបានគណនាដោយផលគុណនៃ PD ១២ខែ ដោយ LGD និងEAD។ ការខាតបង់ឥណទានរំពឹងទុកពេញមួយអាយុកាល ត្រូវបានគណនាដោយផលគុណនៃ PD ពេញមួយអាយុកាលដោយ LGD និងEAD។

គម្រូស្ថិតិត្រូវបានប្រើប្រាស់ ដើម្បីវិភាគទិន្នន័យដែលបានប្រមូល និងបង្កើតការប៉ាន់ប្រមាណនៃលទ្ធភាពនៃការខកខានសងបំណុល (“PD”) ក្នុងអំឡុងពេលនៅសល់នៃអាយុកាលរបស់កម្ចី ហើយថាតើការប៉ាន់ប្រមាណទាំងនេះនឹងមានការប្រែប្រួលយ៉ាងដូចម្តេចតាមកាលវេលា។

LGD គឺជាកម្រិតនៃការខាតបង់ដែលទំនងជានឹងកើតឡើង ប្រសិនបើមានការខកខានសង។ ធនាគារធ្វើការប៉ាន់ប្រមាណប៉ារ៉ាម៉ែត្រ LGD ដោយផ្អែកលើប្រវត្តិអត្រានៃការទាមទារសងត្រឡប់មកវិញពីភាគីដៃគូដែលបានខកខានសងបំណុល។ គម្រូ LGD ពិចារណាលើរចនាសម្ព័ន្ធ ប្រាក់បញ្ញើធានា លំដាប់អាទិភាពនៃការទាមទារសងស័យរបស់ភាគីដៃគូ និងថ្លៃដើមនៃការទារយកទ្រព្យបញ្ចាំណាមួយដែលជាផ្នែកសំខាន់នៃទ្រព្យសកម្មហិរញ្ញវត្ថុនោះ។ ចំពោះកម្ចីដែលមានទ្រព្យបញ្ចាំជាអចលនទ្រព្យលំនៅឋាន អនុបាត LTV គឺជាប៉ារ៉ាម៉ែត្រគន្លឹះក្នុងការកំណត់ LGD។ ការប៉ាន់ប្រមាណ LGD ត្រូវបានធ្វើការកែសម្រួលឡើងវិញសម្រាប់ស្ថានភាពសេដ្ឋកិច្ចផ្សេងៗគ្នា ហើយសម្រាប់កម្ចីអចលនទ្រព្យ គឺដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលអាចកើតមាននៃថ្លៃអចលនទ្រព្យ។ ការប៉ាន់ប្រមាណទាំងនេះត្រូវបានគណនាលើមូលដ្ឋានលំហូរសាច់ប្រាក់អប្បហារ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពជាកត្តាអប្បហារ។

EAD តំណាងឱ្យកម្រិតនៃការប្រឈមហានិភ័យដែលរំពឹងទុក ក្នុងករណីមានការខកខានសងបំណុល។ ធនាគារទាញយកទិន្នន័យ EAD ពីកម្រិតនៃការប្រឈមហានិភ័យបច្ចុប្បន្នចំពោះភាគីដៃគូ និងការផ្លាស់ប្តូរដែលអាចកើតមានចំពោះចំនួនទឹកប្រាក់បច្ចុប្បន្នដែលបានអនុញ្ញាតក្រោមលក្ខខណ្ឌនៃកិច្ចសន្យា និងកើតចេញពីការរំលស់។ EAD នៃទ្រព្យសកម្មហិរញ្ញវត្ថុមួយ គឺជាសមតុល្យយោងដុល នៅពេលមានការខកខានសង។ ចំពោះកិច្ចសន្យាផ្តល់ឥណទាន EAD គឺជាសមតុល្យអនាគតដែលអាចនឹងត្រូវដកយកទៅប្រើប្រាស់ក្រោមលក្ខខណ្ឌនៃកិច្ចសន្យា ដែលត្រូវបានប៉ាន់ប្រមាណដោយផ្អែកលើទិន្នន័យសង្កេតការណ៍ប្រវត្តិសាស្ត្រ និងការព្យាករណ៍ទៅថ្ងៃអនាគត។ ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុមួយចំនួន EAD ត្រូវបានកំណត់ដោយយកគម្រូតាមកម្រិតលទ្ធផលនៃការប្រឈមហានិភ័យដែលអាចកើតមាន នៅតាមពេលវេលាផ្សេងៗគ្នា ដោយប្រើសេណារីយ៉ូ និងបច្ចេកទេសស្ថិតិ។

ដូចបានពិពណ៌នាខាងលើ និងស្ថិតក្រោមលក្ខខណ្ឌនៃការប្រើប្រាស់អត្រា PD អតិបរមា ១២ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដំណាក់កាលទី ១ ធនាគារធ្វើការវាស់វែង ECL ដោយពិចារណាលើហានិភ័យនៃការខកខានសង ក្នុងរយៈពេលតាមកិច្ចសន្យាអតិបរមា ដែលធនាគារត្រូវ (រួមទាំងជម្រើសនៃការបន្តរយៈពេលរបស់កូនបំណុល) ប្រឈមនឹងហានិភ័យឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទាន ធនាគារពិចារណាលើរយៈពេលវែងជាងនេះក៏ដោយ។ រយៈពេលតាមកិច្ចសន្យាអតិបរមា គឺពង្រីកទៅដល់កាលបរិច្ឆេទដែលធនាគារមានសិទ្ធិទាមទារឱ្យមានការសងត្រឡប់មកវិញនូវប្រាក់កម្ចី ឬបញ្ចប់ការប្តេជ្ញាផ្តល់កម្ចី ឬការធានា។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(ល) ឱនភាពតម្លៃ

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែតម្រូវ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ត្រូវបានជំនួសដោយ ទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន នោះការវាយតម្លៃត្រូវបានធ្វើឡើងដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ ឬទេ ហើយការខាតបង់ឥណទានរំពឹងទុក ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនការរៀបចំឡើងវិញដែលបានរំពឹងទុក មិននាំឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរសាច់ប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែតម្រូវ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញដែលបានរំពឹងទុក នាំឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់នោះ តម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរសាច់ប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ននៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធិភាពដើម្បីនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាន

នៅកាលបរិច្ឆេទរាយការណ៍ ធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមថ្លៃដើមរំលស់ និងបំណុលទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានកត់ត្រាតាម FVOCI មានឱនភាពឥណទាន ឬទេ (សំដៅដល់ "កម្រិតទី ៣")។ ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពឥណទាន នៅពេលព្រឹត្តិការណ៍មួយ ឬច្រើន មានផលប៉ះពាល់យ៉ាងខ្លាំងលើលំហូរសាច់ប្រាក់នាពេលអនាគតរបស់ទ្រព្យសកម្មហិរញ្ញវត្ថុបានកើតឡើង។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពឥណទាន រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំងរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានមិនបានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃការផ្តល់ឥណទាន ឬបុរេប្រទានដោយធនាគារ ដែលធនាគារមិនយល់ស្រប
- អតិថិជនទំនងនឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុឡើងវិញជាថ្មី
- ការបាត់បង់ទីផ្សារសកម្មសម្រាប់មូលបត្រដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(ឈ) ឱនភាពតម្លៃ

តំណាទានដែលត្រូវបានរៀបចំឡើងវិញ ដោយសារតែភាពមិនប្រក្រតីនៅក្នុងលក្ខខណ្ឌរបស់អតិថិជន ត្រូវបានចាត់ទុកជាតំណាទានមានឱនភាពតម្លៃ លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានការចង្អុលបង្ហាញផ្សេងទៀតដែលនាំឱ្យមានឱនភាពតម្លៃ។ បន្ថែមលើនេះ តំណាទានដែលហួសកាលកំណត់សង ៩០ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកជាតំណាទានមានឱនភាពតម្លៃ ទោះបីជានិយមន័យនៃការហួសកាលកំណត់សងដែលច្បាប់បានកំណត់ផ្សេងគ្នាក៏ដោយ។

<u>ការបង្ហាញសំវិធានធនសម្រាប់ការខាតបង់តំណាទានរំពឹងទុកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ</u>

សំវិធានធនលើការខាតបង់តំណាទានរំពឹងទុក ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុសម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមរំលស់ថ្លៃដើមដោយធ្វើការកាត់កងពីតម្លៃយោងដុលនៃទ្រព្យសកម្ម។

<u>ការលុបចោល</u>

តំណាទាន និងបុរេប្រទានត្រូវបានលុបចេញពីបញ្ជី (មួយផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកថាអាចប្រមូលបានមកវិញនូវ ទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង។ ករណីនេះមានជាទូទៅ នៅពេលធនាគារកំណត់ថាអតិថិជនពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមកម្រិតទ្រព្យសកម្មដាច់ដោយឡែក។

ទឹកប្រាក់ប្រមូលបានមកវិញលើចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលទៅក្នុង "ការខាតបង់ពីឱនភាពតម្លៃលើឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិត។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានលុបចេញពីបញ្ជីនៅតែត្រូវឱ្យមានសកម្មភាពទាមទារសងមកវិញ ដើម្បីអនុលោមទៅតាមនីតិវិធីរបស់ធនាគារក្នុងការប្រមូលទឹកប្រាក់ដែលនៅជំពាក់។

(ញ) ការកែទម្រង់អត្រាការប្រាក់យោងគោល

ប្រសិនបើមូលដ្ឋាននៃការកំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដែលវាស់វែងតាមថ្លៃដើមរំលស់ មានការផ្លាស់ប្តូរដោយសារការកែទម្រង់អត្រាការប្រាក់យោងគោល នោះធនាគារនឹងធ្វើបច្ចុប្បន្នភាពអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុនោះ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលតម្រូវដោយការកែទម្រង់អត្រាការប្រាក់យោងគោល។
ការផ្លាស់ប្តូរមូលដ្ឋាននៃការកំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យា ត្រូវបានចាត់ទុកថាជាការតម្រូវដោយការកែទម្រង់គោលអត្រាការប្រាក់យោង ប្រសិនបើលក្ខខណ្ឌខាងក្រោមត្រូវបានបំពេញ៖

- ការផ្លាស់ប្តូរនេះគឺចាំបាច់ក្នុងនាមជាផលវិបាកដោយផ្ទាល់នៃការកែទម្រង់; និង
- មូលដ្ឋានថ្មីសម្រាប់កំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យា មានតម្លៃសមមូលខាងសេដ្ឋកិច្ចទៅនឹងមូលដ្ឋានពីមុន – ពោលគឺមូលដ្ឋានដែលបានប្រើភ្លាមៗមុនពេលមានការផ្លាស់ប្តូរ។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.១ ឧបករណ៍ហិរញ្ញវត្ថុ (ត)

(ជ) ការកែទម្រង់អត្រាការប្រាក់យោងគោល

ប្រសិនបើមានការកែប្រែទៅលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ បន្ថែមពីលើការផ្លាស់ប្តូរមូលដ្ឋាននៃការកំណត់លំហូរសាច់ប្រាក់តាមកិច្ចសន្យា ដែលតម្រូវដោយការកែទម្រង់គោលអត្រាការប្រាក់យោងគោល នោះធនាគារនឹងត្រូវធ្វើបច្ចុប្បន្នភាពអត្រាការប្រាក់ប្រសិទ្ធភាពនៃទ្រព្យសកម្ម ឬបំណុលហិរញ្ញវត្ថុនោះជាមុនសិន ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរដែលតម្រូវដោយការកែទម្រង់អត្រាការប្រាក់យោងគោល។ បន្ទាប់មក ធនាគារនឹងអនុវត្តគោលការណ៍គណនេយ្យសម្រាប់ការដែលបានរៀបរាប់ខាងលើ ទៅលើការផ្លាស់ប្តូរបន្ថែមទាំងនោះ។

៣.២ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់គោលបំណងនៃការបង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់នៅក្នុងដៃ ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ និងនៅធនាគារជាតិនៃកម្ពុជា ដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ និងត្រូវបានទិញក្នុងអំឡុងពេល បីខែនៃកាលកំណត់។

៣.៣ ដើមទុន

(ឈ) ដើមទុន

ភាគហ៊ុនធម្មតា គឺជាឧបករណ៍មូលធន។ ឧបករណ៍មូលធន គឺជាកិច្ចសន្យាមួយដែលបង្ហាញពីភស្តុតាងតម្លៃនៅសល់នៃទ្រព្យសកម្មរបស់ធនាគារ បន្ទាប់ពីកាត់កងបំណុលទាំងអស់។ ភាគហ៊ុនធម្មតាត្រូវបាន គេកត់ត្រាពេលដែលសាច់ប្រាក់ទទួលបាន ដោយដកចំណាយប្រតិបត្តិការកើតឡើងដោយផ្ទាល់។

(ញ) ដើមទុនផ្សេងៗ និងដើមទុនបម្រុងទុក

ដើមទុនផ្សេងៗ និងដើមទុនបម្រុងទុកត្រូវបានចាត់ថ្នាក់ជាមូលធន។ យោងតាមលិខិតលេខ ៥៣៦ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១៦ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានដាក់ជូនទៅនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងភ្ជាប់មកជាមួយនឹងចំណារពន្យល់ ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៦ ធនាគារត្រូវបានផ្តល់ការយល់ព្រមតាមការស្នើសុំដើម្បីចាត់វិធានការលើឥណទាន និងបុរេប្រទានមិនដំណើរការដែលមានសមតុល ១៨.២៦៩.៥៦៧ ដុល្លារអាមេរិក។ ឥណទាន និងបុរេប្រទានមិនដំណើរការទាំងនេះ ត្រូវបានកាត់កងពីមូលធនដោយចេញពីតារាងតុល្យការ ហើយត្រូតពិនិត្យដោយឡែកពីគ្នា។ លទ្ធភាពស្តារបានមកវិញជាបន្តបន្ទាប់នៃឥណទាន និងបុរេប្រទានមិនមានដំណើរការទាំងនេះ និងការប្រាក់ដែលពាក់ព័ន្ធនឹងត្រូវបានទទួលស្គាល់ដោយផ្ទាល់ក្នុងគណនីដើមទុនផ្សេងៗ និងទុនបម្រុងរបស់ធនាគារពបន្ទាប់ពីទទួលបានការអនុម័តពីធនាគារជាតិនៃកម្ពុជា។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.៤ ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នានៃសំវិធានធន រវាងឱនភាពតម្លៃនៃឥណទានដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក និងសំវិធានធនស្របតាមបទប្បញ្ញត្តិ ដោយអនុលោមទៅតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើឱនភាពតម្លៃសម្រាប់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ។

យោងតាមប្រកាសនេះ ធនាគារគួរធ្វើការប្រៀបធៀបសំវិធានធនដែលបានគណនាដោយអនុលោមទៅតាមតម្រូវការខាងលើ និងការកត់ត្រារបស់ធនាគារស្របទៅតាម ស.រ.ទ.ហ.អ.ក៖

ក. ក្នុងករណីដែលសំវិធានធនតាមបទប្បញ្ញត្តិ ទាបជាងសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក ធនាគារធ្វើការកត់ត្រាសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក និង

ខ. ក្នុងករណីសំវិធានធនតាមបទប្បញ្ញត្តិ ខ្ពស់ជាងសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក ធនាគារធ្វើការកត់ត្រាសំវិធានធនដែលគណនាតាម ស.រ.ទ.ហ.អ.ក ហើយផ្ទេរតម្លៃដែលខុសគ្នាពីចំណេញរក្សាទុក ឬខាតបង្គរទៅទុនបម្រុងតាមបទប្បញ្ញត្តិ នៅក្នុងគណនីមូលធនរបស់ម្ចាស់ភាគហ៊ុននៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ទុនបម្រុងតាមបទប្បញ្ញត្តិមិនត្រូវបានបញ្ចូលក្នុងការគណនាមូលធនថ្នាល់សុទ្ធរបស់ធនាគារឡើយ។

៣.៥ ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ

ប្រាក់បញ្ញើតាមបទប្បញ្ញត្តិ ត្រូវបានបង្ហាញនៅតម្លៃដើម។ ប្រាក់បញ្ញើតាមបទប្បញ្ញត្តិតំណាងឱ្យទុនបម្រុងកាតព្វកិច្ច និងសាច់ប្រាក់ ដែលត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជា ស្របតាមបទប្បញ្ញត្តិស្តីពីស្ថាប័នធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា (“LBFI”) និងមិនត្រូវបានប្រើប្រាស់សម្រាប់ផ្គត់ផ្គង់ប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារ ដូច្នេះវាមិនត្រូវបានចាត់ទុកជាចំណែកនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល សម្រាប់គោលបំណងក្នុងរបាយការណ៍លំហូរសាច់ប្រាក់នោះទេ។

៣.៦ ទ្រព្យសម្បត្តិ និងបរិក្ខារ

គ្រប់សមាសធាតុរបស់ទ្រព្យសម្បត្តិ និងបរិក្ខារទាំងអស់ ត្រូវបានទទួលស្គាល់ដំបូង តាមតម្លៃដើម និងបន្ទាប់មកតាមតម្លៃដើម ដករំលស់បង្គរ និងឱនភាពតម្លៃបង្គរ។ ថ្លៃដើមរបស់ទ្រព្យសម្បត្តិ និងបរិក្ខារដែលត្រូវបានទទួលស្គាល់ដំបូង រួមបញ្ចូលទាំងតម្លៃទិញចូលនៃទ្រព្យសម្បត្តិ និងថ្លៃដើមពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការនាំយកទ្រព្យសកម្មទៅកាន់ទីតាំង និងនៅក្នុងលក្ខខណ្ឌសមស្របក្នុងការធ្វើប្រតិបត្តិការអាជីវកម្មតាមការកំណត់របស់គណៈគ្រប់គ្រង។

ទ្រព្យសកម្មមិនទាន់បញ្ចប់ការសាងសង់ ដែលរួមបញ្ចូលទៅក្នុងទ្រព្យសម្បត្តិ និងបរិក្ខារ មិនត្រូវបានធ្វើរំលស់ឡើយ ព្រោះទ្រព្យសកម្មទាំងនេះ មិនទាន់អាចប្រើប្រាស់បាន។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.៦ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

ការរំលស់ត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងរបាយការណ៍ចំណេញ ឬខាតតាមវិធីសាស្ត្រសមតុល្យថយចុះលំដាប់លើកលែងតែការកែលម្អដីធ្លី អគារ និងការកែលម្អអគារ ដែលត្រូវបានរំលស់ដោយវិធីសាស្ត្ររំលស់ថេរតាមអត្រាដូចខាងក្រោម៖

	អាយុកាលប្រើប្រាស់
ការកែលម្អដីធ្លី	៥% រំលស់ថេរ
អគារ	៥% រំលស់ថេរ
ការកែលម្អអគារ	៥% រំលស់ថេរ
យានយន្ត	២៥% សមតុល្យថយចុះលំដាប់
បរិក្ខារព័ត៌មានវិទ្យា	៥0% សមតុល្យថយចុះលំដាប់
បរិក្ខារការិយាល័យ និងគ្រឿងសង្ហារឹម	៥0% សមតុល្យថយចុះលំដាប់

តម្លៃដែលនៅសល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់នៃទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើនិយ័តកម្មតាមការសមស្រប នៅរៀងរាល់ចុងកាលបរិច្ឆេទរាយការណ៍នីមួយៗ។ ផលប៉ះពាល់នៃការកែតម្រូវ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតនៅពេលការផ្លាស់ប្តូរបានកើតមានឡើង។

ដីធ្លីមិនត្រូវបានរំលស់នោះទេ។

៣.៧ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីដែលបានទិញដោយធនាគារ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាមថ្លៃដើមដកការលស់បង្គរ (នៅពេលដែលអាយុកាលប្រើប្រាស់ប៉ាន់ស្មានមានភាពជាក់លាក់) និងការខាតបង់លើឱនភាពតម្លៃ។

ទ្រព្យសកម្មអរូបីត្រូវបានធ្វើរំលស់តាមវិធីសាស្ត្រសមតុល្យថយចុះលំដាប់ក្នុងអត្រា ២0% ក្នុងមួយឆ្នាំ។

ទ្រព្យសកម្មកំពុងដំណើរការតំណាងឱ្យការទូទាត់សម្រាប់ការដំឡើងកម្មវិធី និងប្រព័ន្ធកុំព្យូទ័រ។ ទ្រព្យសកម្មកំពុងដំណើរការ នឹងចាប់ផ្តើមត្រូវបានរំលស់នៅពេលដែលវារួចរាល់សម្រាប់ដាក់ឱ្យប្រើប្រាស់។

ទាំងរយៈពេល និងវិធីសាស្ត្ររំលស់ ត្រូវបានត្រួតពិនិត្យជាប្រចាំឆ្នាំ។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.៨ ភតិសន្យា

ធនាគារក្នុងនាមជាភតិក:

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានទទួលស្គាល់ដំបូងតាមថ្លៃដើម ដែលរួមមានចំនួនទឹកប្រាក់ដំបូងនៃបំណុលភតិសន្យា ដែលបានធ្វើនិយ័តកម្មសម្រាប់ការទូទាត់ភតិសន្យាណាមួយដែលបានធ្វើឡើងនៅកាលបរិច្ឆេទ ឬមុនកាលបរិច្ឆេទនៃការចាប់ផ្តើមភតិសន្យា បូកថ្លៃដើមដែលបានកើតឡើងដោយផ្ទាល់ ប្រសិនបើមាន។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានរំលស់ជាបន្តបន្ទាប់ ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ ដោយគិតចាប់ពីកាលបរិច្ឆេទនៃការចាប់ផ្តើមភតិសន្យា រហូតដល់ចុងបញ្ចប់នៃភតិសន្យា។

បំណុលភតិសន្យា ត្រូវបានវាស់វែងដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនបានទូទាត់នាកាលបរិច្ឆេទនៃការចាប់ផ្តើមភតិសន្យា ហើយត្រូវបានធ្វើអប្បហារដោយប្រើប្រាស់អត្រាការប្រាក់ជាក់ស្តែងដែលមានក្នុងភតិសន្យា ឬប្រសិនបើអត្រានេះមិនអាចកំណត់បាននោះទេ ធនាគារប្រើអត្រាប្រាក់កម្ចីបន្ថែម។ ជាទូទៅ ធនាគារប្រើអត្រាប្រាក់កម្ចីបន្ថែមរបស់ខ្លួន ជាអត្រាអប្បហារ។

ការទូទាត់ភតិសន្យារួមបញ្ចូលទាំងការវាស់វែងបំណុលភតិសន្យា មានដូចខាងក្រោម៖

- ការទូទាត់ភតិសន្យាថេរ (រួមទាំងការទូទាត់ជារូបធាតុថេរ) ដកប្រាក់លើកទឹកចិត្តភតិសន្យាដែលត្រូវទទួល
- ការទូទាត់ភតិសន្យាអថេរដែលពឹងផ្អែកលើសន្ទស្សន៍ ឬអត្រា ការវាស់ដំបូងដោយប្រើសន្ទស្សន៍ ឬអត្រានៅកាលបរិច្ឆេទចាប់ផ្តើមនៃភតិសន្យា
- សមតុល្យដែលរំពឹងថានឹងត្រូវបង់ក្នុងនាមជាភតិក:ក្រោមការធានាតម្លៃនៅសល់
- ការអនុវត្តជម្រើសតម្លៃនៃការទិញ ប្រសិនបើភតិក:ក្នុងការអនុវត្តដ៏សមហេតុផលនៃជម្រើសនោះ និង
- ការបង់ប្រាក់ពិន័យសម្រាប់ការបញ្ចប់ភតិសន្យា ប្រសិនបើលក្ខខណ្ឌកំណត់ភតិសន្យានោះឆ្លុះបញ្ចាំងពីការអនុវត្តជម្រើសដើម្បីបញ្ចប់ភតិសន្យា។

បំណុលភតិសន្យា ត្រូវបានបង្ហាញនៅដាច់ដោយឡែកនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

បំណុលភតិសន្យា ត្រូវបានវាស់វែងជាបន្តបន្ទាប់តាមរយៈការកើនឡើងនៃសមតុល្យយោង ដើម្បីបង្ហាញពីភាពសមស្របនៃការប្រាក់លើបំណុលភតិសន្យា (ដោយប្រើប្រាស់វិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធិភាព) និងតាមរយៈការបន្ថយសមតុល្យយោងដើម្បីឆ្លុះបញ្ចាំងពីការទូទាត់បំណុលភតិសន្យាដែលបានធ្វើឡើង។

ភតិសន្យារយៈពេលខ្លី និងភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប

ធនាគារ បានជ្រើសរើសមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាសម្រាប់ភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប និងភតិសន្យារយៈពេលខ្លី។ ធនាគារទទួលស្គាល់ការទូទាត់ភតិសន្យា ជាចំណាយប្រតិបត្តិការដោយផ្អែកលើមូលដ្ឋានថេរទៅតាមរយៈពេលនៃភតិសន្យា។

៣. ព័ត៌មានគោលការណ៍គណនេយ្យជាសារវន្ត (ត)

៣.៩ ទ្រព្យសម្បត្តិបានរឹបអូស

ទ្រព្យសម្បត្តិបានរឹបអូស ដែលមានទ្រព្យចលនវត្ថុ និងទ្រព្យអចលនវត្ថុដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មរយៈពេលវែងកាន់កាប់សម្រាប់លក់ ទ្រព្យសកម្មត្រូវបានវាស់វែងតាមតម្លៃទាបជាងនៃតម្លៃយោង និងតម្លៃសមស្របដកថ្លៃដើមលក់ ដកឱនភាពតម្លៃ ប្រសិនបើមាន។

តម្លៃយោងនៃទ្រព្យសម្បត្តិបានរឹបអូស ដកថ្លៃដើមលក់ គឺទាបជាងតម្លៃយោង ការខាតបង់ឱនភាពតម្លៃត្រូវបានទទួលស្គាល់។ នេះឆ្លុះបញ្ចាំងពីការធ្លាក់ចុះនៃតម្លៃទ្រព្យសកម្ម ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬការខាតបង់ដូចដែលបានកើតឡើង។

៣.១០ ឱនភាពតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលបានរំលស់ត្រូវបានកំណត់ឡើងវិញ នៅរាល់ចុងបញ្ចប់នៃកាលបរិច្ឆេទរបាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានការចង្អុលបង្ហាញពីឱនភាពតម្លៃ ដែរឬទេ។ ប្រសិនបើមានការចង្អុលបង្ហាញបែបនេះ ទ្រព្យសកម្មអាចត្រូវបានធ្វើឱនភាពតម្លៃ តម្លៃយោងនៃទ្រព្យសកម្ម (ឬឯកតាបង្កើតសាច់ប្រាក់ "CGU" ដែលទ្រព្យសកម្មត្រូវបានបែងចែក) ត្រូវបានធ្វើតេស្តឱនភាពតម្លៃ។

ការខាតបង់លើឱនភាពតម្លៃនឹងត្រូវបានទទួលស្គាល់ តាមតម្លៃដែលយោងនៃទ្រព្យសកម្ម ធំជាងតម្លៃដែលអាចទទួលបានមកវិញបាន។ តម្លៃដែលអាចទទួលបានមកវិញបាន គឺភាពធំជាង(ឬ "CGU") នៃតម្លៃសមស្របដកតម្លៃដែលត្រូវលក់ និងតម្លៃដែលត្រូវប្រើប្រាស់របស់ទ្រព្យសកម្ម។ សម្រាប់គោលបំណងនៃការវាយតម្លៃឱនភាពតម្លៃទ្រព្យសកម្ម ត្រូវបានបែងចែកជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ("CGUs")។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលមានឱនភាពត្រូវតម្លៃបានត្រួតពិនិត្យ សម្រាប់ការកត់ត្រាបញ្ច្រាសដែលអាចមាននៅការិយបរិច្ឆេទនៃរាយការណ៍នីមួយៗ។

៣.១១ បំណុលបន្ទាប់បន្សំ

